# បណ្ណសន្យារ៉ាប់រង AIA ComCare

## តារាងមាតិកា


**បណ្ណសន្យារ៉ាប់រង** .......... 1
I. **និយមន័យ** .......... 1
II. **កម្មវត្ថុនៃការធានា** .......... 7
1. ការចូលរួមជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង .......... 8
2. ការបញ្ចប់ភាពជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង .......... 8
3. ភស្តុតាងបញ្ជាក់អំពីសុខភាព .......... 9
III. **វិសាលភាពធានារ៉ាប់រង** .......... 9
1. អត្ថប្រយោជន៍ការពារគ្រួសារ .......... 10
2. អត្ថប្រយោជន៍លើការស្លាប់ឬពិការភាពអចិន្ត្រៃយ៍ .......... 10
3. អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ .......... 10
4. អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ .......... 11
5. អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ .......... 12
IV. **អត្ថប្រយោជន៍ធានារ៉ាប់រង** .......... 14
V. **ការបង់បុព្វលាភធានារ៉ាប់រង** .......... 16
1. វិធីសាស្ត្រនៃការបង់បុព្វលាភធានារ៉ាប់រង .......... 16
2. អត្រាបុព្វលាភធានារ៉ាប់រង .......... 16
3. ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រង .......... 17
4. រយៈពេលអនុគ្រោះ .......... 17
5. រូបិយប័ណ្ណ និងមធ្យោបាយបង់ប្រាក់ .......... 17
6. បន្ទុកថ្លៃចំណាយនានាដែលកំណត់ដោយបទប្បញ្ញត្តិ ឬច្បាប់ .......... 17
VI. **ករណីមិនធានា** .......... 18
1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍ការពារគ្រួសារ .......... 18
2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើការស្លាប់ឬពិការភាពអចិន្ត្រៃយ៍ .......... 18
3. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ .......... 19
4. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺធ្ងន់ធ្ងរ .......... 19
5. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ .......... 20
6. ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ .......... 24
VII. **ទីតាំងភូមិសាស្ត្រនៃការធានា** .......... 24
VIII. **លក្ខណៈសម្បត្តិរបស់អ្នកទទួលផល** .......... 25
IX. **ការកែប្រែកិច្ចសន្យាធានារ៉ាប់រង** .......... 25
X. **ការបន្តកិច្ចសន្យាធានារ៉ាប់រង** .......... 25
XI. **ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង** .......... 25
1. សិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រង .......... 25
2. រយៈពេលពិចារណាចុងក្រោយ .......... 26

XII. **ការលុបចោលកិច្ចសន្យាធានារ៉ាប់រង** ........ 26
1. សិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង ........ 26
2. ករណីមិនអាចជំទាស់បាន ........ 27
3. ការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និង/ឬ ភេទ ........ 27

XIII. **ការទាមទារសំណង** ........ 27
1. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង ........ 27
2. និតិវិធីនៃការផ្តល់ព័ត៌មាន ........ 27
3. ការផ្តល់ឯកសារ ឬភស្តុតាងក្នុងការដោះស្រាយសំណង ........ 28
4. រយៈពេលអតិបរមានៃការទូទាត់សំណងជូនអតិថិជន ........ 29
5. របៀបទូទាត់សំណង ........ 30
6. ករណីកុមារជាអ្នកត្រូវបានធានារ៉ាប់រង ........ 30

XIV. **ការរក្សាការព័ត៌មានសម្ងាត់** ........ 30

XV. **ការផ្សះផ្សាវិវាទ** ........ 30
1. នីតិវិធីដោះស្រាយបណ្តឹងអតិថិជន ........ 30
2. នីតិវិធីនៃការផ្សះផ្សាវិវាទ ........ 31

XVI. **ដែនយុត្តាធិការ** ........ 31

XVII. **ខ និងលក្ខខណ្ឌផ្សេងៗ** ........ 31

**ឧបសម្ព័ន្ធ I – តារាង Lund និង Browder** ........ 33

**ឧបសម្ព័ន្ធ II – តារាងជំងឺធ្ងន់ធ្ងរ** ........ 34

# បណ្ណសន្យារ៉ាប់រង

## AIA ComCare

## I. និយមន័យ

នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ពេលណាដែលបរិបទតម្រូវវាក្យស័ព្ទមានភេទប្រុស ត្រូវអនុវត្តចំពោះវាក្យស័ព្ទភេទស្រីផងដែរ ហើយវាក្យស័ព្ទជាឯកវចនៈ ត្រូវរាប់បញ្ចូលទាំងវាក្យស័ព្ទជាពហុវចនៈដែរ ហើយវាក្យស័ព្ទខាងក្រោមត្រូវមានអត្ថន័យដូចតទៅ៖

1. **គ្រោះថ្នាក់ចៃដន្យ** មានន័យថាហេតុការណ៍ដែលកើតឡើងភ្លាមៗ ដោយអចេតនា ដោយចៃដន្យ ខុសធម្មតា និងជាព្រឹត្តិការណ៍ជាក់លាក់មួយដែលបានកើតឡើងនៅពេលវេលា និងទីកន្លែងមួយដែលអាចកំណត់បាន និងមិនពាក់ព័ន្ធនឹងមូលហេតុដទៃផ្សេងទៀត ដែលជាមូលហេតុតែមួយគត់ដែលបង្កឱ្យមានរបួសរូបរាងកាយនេះ។
2. **ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃ៖
   - (i) ជើង ឬដៃម្ខាង ឬ
   - (ii) ភ្នែកម្ខាង ឬ
   - (iii) មេដៃទាំងសងខាង (2 សន្លាក់ ឬថ្នាំងនៃមេដៃនីមួយៗ) ឬ
   - (iv) មេជើងទាំងសងខាង (2 សន្លាក់ ឬថ្នាំងនៃមេជើងនីមួយៗ) ឬ
   - (v) ម្រាមដៃទាំងបួន (3 សន្លាក់ ឬថ្នាំង នៃម្រាមដៃនីមួយៗ) និងមេដៃមួយ (2 សន្លាក់ ឬថ្នាំងនៃមេដៃ) នៃដៃតែម្ខាង ឬ
   - (vi) ម្រាមជើងទាំងបួន (យ៉ាងតិចណាស់ 1 សន្លាក់ ឬថ្នាំងនៃម្រាមជើងនីមួយៗ) និងមេជើងមួយ (2 សន្លាក់ ឬថ្នាំងនៃមេជើង) នៃជើងតែម្ខាង ឬ
   - (vii) ការស្តាប់លឺនៃត្រចៀកម្ខាង ឬ
   - (viii) មេដៃទាំងមូល (2 សន្លាក់ ឬថ្នាំងនៃមេដៃ) ឬ
   - (ix) ម្រាមដៃចង្អុល (3 សន្លាក់ ឬថ្នាំង) ឬ
   - (x) ម្រាមដៃកណ្តាលទាំងមូល (3 សន្លាក់ ឬថ្នាំង) ឬ
   - (xi) ម្រាមដៃនាងទាំងមូល (3 សន្លាក់ ឬថ្នាំង) ឬ
   - (xii) ម្រាមកូនដៃទាំងមូល (3 សន្លាក់ ឬថ្នាំង)។
3. **ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 2** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃ៖
   - (i) ជើង ឬដៃទាំងសងខាង ឬ
   - (ii) ភ្នែកទាំងសងខាង ឬ
   - (iii) ជើង ឬដៃម្ខាងភ្នែកម្ខាង ឬ
   - (iv) សមត្ថភាពក្នុងការនិយាយ ឬ

(v) ការស្តាប់លឺនៃត្រចៀកទាំងសងខាង។

4. **របួសបង្កដោយគ្រោះថ្នាក់ចៃដន្យ** សំដៅដល់មរណភាព ឬរបួសដែលបណ្តាលដោយផ្ទាល់មកពីរបួសរូបរាងកាយ និងដែលកើតឡើងក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃគ្រោះថ្នាក់។
5. **កំពុងបំពេញការងារជាសមាជិកនៃស្ថាប័ន** មានន័យថាសមាជិកអ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ដែលកំពុងបំពេញការងារជាសមាជិកនៃស្ថាប័ន ហើយមិនបានកំពុងបំពេញការងារផ្ទុយពីការណែនាំតាមផ្នែកវេជ្ជសាស្ត្រ និងត្រូវ៖
   (i) បំពេញការងារតាមមុខតំណែងធម្មតារបស់គាត់ និង
   (ii) បំពេញការងារតាមចំនួនម៉ោងការងារធម្មតារបស់គាត់ និង
   (iii) បំពេញការងារនៅទីកន្លែងធ្វើការធម្មតារបស់គាត់ ឬទីតាំងដែលតម្រូវឱ្យគាត់ធ្វើដំណើរទៅ និង
   (iv) មិនគួរសុំច្បាប់សម្រាកដោយជំងឺ លើសពី 2 សប្តាហ៍ក្នុងកំឡុងពេលមួយឆ្នាំចុងក្រោយ។
6. **ទឹកប្រាក់ធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់នៃការធានារ៉ាប់រងដែលបានទិញ ដូចដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ឬដូចដែលបានកែសម្រួលនៅលើបង្កាន់ដៃលេខណាមួយ។
7. **រយៈពេលវាយតម្លៃ** គឺជារយៈពេលមួយដែលក្រុមហ៊ុននឹងវាយតម្លៃលើលក្ខខណ្ឌមួយ មុនពេលសម្រេចថាតើលក្ខខណ្ឌនោះ មានលក្ខណៈគ្រប់គ្រាន់ដែលត្រូវចាត់ទុកថាមានលក្ខណៈអចិន្ត្រៃយ៍ដែរ ឬទេ។ រយៈពេលវាយតម្លៃនឹងត្រូវមានរយៈពេលអប្បបរមាដែលបានកំណត់ក្នុងនិយមន័យពាក់ព័ន្ធ និងមិនត្រូវមានរយៈពេលលើសពី 12 (ដប់ពីរ) ខែឡើយ (ប្រសិនបើតស្តុតាងតម្រូវទាំងអស់ត្រូវបានដាក់ជូនរួចរាល់)។
8. **អ្នកទទួលផល** សំដៅដល់តតិយជនម្នាក់ ឬលើសពីនេះនៃកិច្ចសន្យាធានារ៉ាប់រង ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលអត្ថប្រយោជន៍ពីបណ្ណសន្យារ៉ាប់រងនេះ។
9. **របួសរូបរាងកាយ** មានន័យថាលក្ខណៈមិនប្រក្រតីនៃរូបរាងកាយដែលកើតមានឡើងក្នុងកំឡុងពេលដែលបណ្ណសន្យារ៉ាប់រងនេះមានសុពលភាព និងបានកើតឡើងដោយផ្ទាល់ និងឯករាជ្យពីមូលហេតុទាំងឡាយដូចជា ដោយអំពើហិង្សា ពីខាងក្រៅ អាចមើលឃើញ និងដោយចៃដន្យតែប៉ុណ្ណោះ ហើយមិនមែនបណ្តាលមកពីជំងឺ ឬមេរោគណាមួយឡើយ។
10. **ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា** សំដៅដល់ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ដែលមាន និងត្រូវបានអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា និង/ឬ រាល់វិសោធនកម្មដែលពាក់ព័ន្ធ។
11. **វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុន ដើម្បីបញ្ជាក់ថាម្ចាស់បណ្ណសន្យារ៉ាប់រងបានទិញការធានារ៉ាប់រងពីក្រុមហ៊ុន។
12. **ក្រុមហ៊ុន** សំដៅដល់ក្រុមហ៊ុន អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក។
13. **ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូត** មានន័យថាការបាត់បង់ភ្នែកម្ខាង ឬទាំងពីរ សំដៅដល់ការបាត់បង់ផ្នែកអវៈយវៈនៃភ្នែក ឬពិការភ្នែកទាំងស្រុង ការបាត់បង់ដៃម្ខាង ឬទាំងសងខាង សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកដៃឡើងទៅ ការបាត់បង់ជើងម្ខាង ឬទាំងសងខាង សំដៅដល់ការបាត់បង់ចាប់ពីផ្នែកខាងលើនៃកជើងឡើងទៅ ការបាត់បង់ការស្តាប់លឺ ឬសមត្ថភាពក្នុងការនិយាយ មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃការស្តាប់លឺ ឬសមត្ថភាពក្នុងការនិយាយ។

ក្រោមនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតក៏មានន័យថាការបាត់បង់សមត្ថភាពប្រើប្រាស់អវៈយវៈដូចជាដៃម្ខាង ឬដៃទាំងសងខាង ជើងម្ខាង ឬជើងទាំងសងខាង ដែលមានការបញ្ជាក់ត្រឹមត្រូវពីមន្ទីរពេទ្យ ដែលបានចុះបញ្ជីការយ៉ាងហោចណាស់ត្រឹមថ្នាក់ខេត្តថា ស្ថានភាពពិការនេះមានរយៈពេលយ៉ាងហោចណាស់ 6 (ប្រាំមួយ) ខែ។ ការបញ្ជាក់អំពីការបាត់បង់នេះ អាចត្រូវបានធ្វើឡើងនៅពេលណាក៏បាន ក្នុងកំឡុងរយៈពេលនៃបណ្ណសន្យារ៉ាប់រង និងនាពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព។

14. **ការវះកាត់ដែលត្រូវបានធានារ៉ាប់រង** មានន័យថាជាការវះកាត់ផ្សេងៗ ដែលបានកំណត់ ឬបញ្ជាក់ក្នុងតារាងជំងឺធ្ងន់ធ្ងរ (ឧបសម្ព័ន្ធ II) ។
15. **ប្រភេទជំងឺធ្ងន់ធ្ងរ** មានន័យថាជាប្រភេទនៃអាការៈជំងឺធ្ងន់ធ្ងរ ដូចមានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ (ឧបសម្ព័ន្ធ II) ។
16. **អាការៈជំងឺធ្ងន់ធ្ងរ** គឺជាពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង បានធ្វើរោគវិនិច្ឆ័យរកឃើញថាទទួលការរងគ្រោះពីជំងឺធ្ងន់ធ្ងរមួយ ឬបានឆ្លងកាត់ការវះកាត់ដែលត្រូវបានធានារ៉ាប់រងសម្រាប់ជំងឺធ្ងន់ធ្ងរមួយដូចដែលមានកំណត់នៅក្នុងតារាងជំងឺធ្ងន់ធ្ងរ (ឧបសម្ព័ន្ធ II) ។
17. **ការធ្វើរោគវិនិច្ឆ័យ** មានន័យថាការធ្វើរោគវិនិច្ឆ័យជាក់លាក់មួយដោយវេជ្ជបណ្ឌិតជំងឺទូទៅ ផ្អែកទៅលើភស្តុតាងដែលដូចគ្នាទៅនឹងនិយមន័យនៃអាការៈជំងឺធ្ងន់ធ្ងរ ឬប្រសិនបើគ្មានភស្តុតាងជាក់លាក់ រោគវិនិច្ឆ័យត្រូវផ្អែកលើភស្តុតាងនៃវិទ្យុសាស្ត្រ គ្លីនិក ជាលិកាសាស្ត្រ ឬមន្ទីរពិសោធន៍ដែលបានទទួលស្គាល់ដោយក្រុមហ៊ុន។ រោគវិនិច្ឆ័យនេះ ត្រូវតែទទួលស្គាល់ដោយនាយកផ្នែកវេជ្ជសាស្ត្ររបស់ក្រុមហ៊ុនដែលសម្អាងលើភស្តុតាងវេជ្ជសាស្ត្រ ដែលបានផ្តល់ដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ភស្តុតាងបន្ថែមណាមួយដែលគាត់អាចនឹងត្រូវការ។

    ក្នុងករណីដែលមានជម្លោះ ឬភាពមិនយល់ស្របគ្នាពាក់ព័ន្ធនឹងភាពសមស្រប ឬភាពត្រឹមត្រូវនៃរោគវិនិច្ឆ័យនេះ ក្រុមហ៊ុនត្រូវមានសិទ្ធិទាមទារឱ្យមានការពិនិត្យលើសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬលើភស្តុតាងដែលត្រូវបានប្រើសម្រាប់រោគវិនិច្ឆ័យនេះ ដោយអ្នកជំនាញឯករាជ្យក្នុងវិស័យសុខាភិបាលដែលពាក់ព័ន្ធហើយដែលត្រូវបានជ្រើសរើសដោយក្រុមហ៊ុន។ ហើយសមាជិកអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចគោរពតាមគំនិតយោបល់របស់អ្នកជំនាញទៅលើរោគវិនិច្ឆ័យនោះ ។
18. **ការអនុញ្ញាតចេញពីមន្ទីរពេទ្យ** មានន័យថាសមាជិកអ្នកត្រូវបានធានារ៉ាប់រងចាកចេញពីមន្ទីរពេទ្យ បន្ទាប់ពីការបំពេញគ្រប់លក្ខខណ្ឌព្យាបាលក្នុងមន្ទីរពេទ្យដើម្បីបញ្ចប់ការសម្រាកក្នុងមន្ទីរពេទ្យ និងការទូទាត់ថ្លៃចំណាយដែលនៅសល់ ដោយមិនតម្រូវឱ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រង ត្រូវសម្រាកក្នុងមន្ទីរពេទ្យទៀតនោះទេ។
19. **កាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង** មានន័យថាកាលបរិច្ឆេទសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងដែលមាននៅលើរបាយការណ៍ទូទាត់បុព្វលាភធានារ៉ាប់រង ឬការជូនដំណឹងពីក្រុមហ៊ុន។
20. **កាលបរិច្ឆេទនៃការទទួលបានសិទ្ធិជាសមាជិក** មានន័យថាកាលបរិច្ឆេទដែលបុគ្គលណាម្នាក់បានក្លាយជាសមាជិកដូចដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិកដែលបានធ្វើបច្ចុប្បន្នភាព។
21. **បដ្ឋិលេខ** មានន័យថាការប្រែប្រួល ឬកែប្រែលើបណ្ណសន្យារ៉ាប់រងនេះ។
22. **រយៈពេលអនុគ្រោះ** មានន័យថារយៈពេល 30 (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងនឹងត្រូវបានអនុញ្ញាតសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងបន្ទាប់។ បណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបន្តសុពលភាពអនុវត្តក្នុងកំឡុងពេលរយៈពេលអនុគ្រោះនេះ។

23. **អាការៈជំងឺ ឬការវះកាត់ក្រុមទី 1** មានន័យថាជាអាការៈជំងឺធ្ងន់ធ្ងរមានស្ថានភាព ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ (ឧបសម្ព័ន្ធ II)។
24. **អាការៈជំងឺ ឬការវះកាត់ក្រុមទី 2** មានន័យថាអាការៈជំងឺធ្ងន់ធ្ងរមានស្ថានភាពធ្ងន់ធ្ងរ ដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ (ឧបសម្ព័ន្ធ II)។
25. **មន្ទីរពេទ្យ** សំដៅទៅស្ថាប័នវេជ្ជសាស្ត្រដែលមាននៅក្នុងបញ្ជី ដែលក្រុមហ៊ុនអាចនឹងធ្វើបច្ចុប្បន្នភាពនៅថ្ងៃអនាគត ឬជាស្ថាប័នវេជ្ជសាស្ត្រដែលបានបង្កើតនិងចុះបញ្ជី សម្រាប់ការថែរក្សានិងព្យាបាលជំងឺ និងអ្នករងរបួសដែលត្រូវបង់ថ្លៃសម្រាប់ព្យាបាល ដែលត្រូវ៖
    (i) មានគ្រឿងបរិក្ខារសម្រាប់ការធ្វើរោគវិនិច្ឆ័យ និងការវះកាត់ធំៗ ឬ
    (ii) ផ្តល់សេវាថែទាំ 24 ម៉ោងក្នុងមួយថ្ងៃដោយគិលានុបដ្ឋាយិកាដែលចុះបញ្ជីការ និងបានបញ្ចប់ការសិក្សា ឬ
    (iii) ក្រោមការគ្រប់គ្រងរបស់វេជ្ជបណ្ឌិតជំនាញឯកទេស ហើយ
    (iv) មិនមែនគ្រាន់តែជាគ្លីនិកឯកទេសដូចជា កន្លែងសម្រាប់អ្នកញៀនថ្នាំ និងស្រា កន្លែងមើលថែទាំ កន្លែងសម្រាក កន្លែងថែទាំអ្នកជំងឺ កន្លែងថែទាំចាស់ជរា ឬប្រភេទកន្លែងស្រដៀងគ្នា។
26. **ការសម្រាកក្នុងមន្ទីរពេទ្យ** សំដៅទៅការសម្រាកក្នុងមន្ទីរពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ រយៈពេលចាប់ពី 6 (ប្រាំមួយ) ម៉ោងជាប់គ្នាឡើងទៅ ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់ពីការគិតថ្លៃបន្ទប់ និងការសម្រាក ដោយការសម្រាកនេះត្រូវសមហេតុផល។
27. **ការរងរបួស** មានន័យថាការរងរបួសលើរូបរាងកាយបង្កដោយគ្រោះថ្នាក់ចៃដន្យតែមួយគត់។
28. **កិច្ចសន្យាធានារ៉ាប់រង** សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយ ដោយទទួលមកនូវការបង់បុព្វលាភធានារ៉ាប់រងពីម្ចាស់បណ្ណសន្យារ៉ាប់រង។
29. **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុន ដោយមានកំណត់ពីខ្លឹមសារសំខាន់ និងចែងពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រងនៅក្នុងកិច្ចសន្យារ៉ាប់រង។
30. **សមាជិកអ្នកត្រូវបានធានារ៉ាប់រង** សំដៅទៅដល់សមាជិកនៃស្ថាប័នរបស់អ្នក ដែលបានចូលរួមនៅក្រោមបណ្ណសន្យារ៉ាប់រងនេះ ដូចដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។
31. **ការបាត់បង់ការស្តាប់លឺ** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃការស្តាប់លឺ ដែលការបាត់បង់នេះមានកម្រិតហួសពី 80 ដេស៊ីបែល ចំពោះគ្រប់ប្រេកង់នៃការស្តាប់លឺនៃត្រចៀកទាំងសងខាងឬម្ខាង។ ភស្តុតាងតាមផ្នែកវេជ្ជសាស្ត្រក្នុងទម្រង់នៃការធ្វើតេស្តការស្តាប់លឺ និងកម្រិតសម្លេងដែលអាចស្តាប់លឺ ត្រូវផ្តល់ជូន និងបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញខាងផ្នែកត្រចៀក ច្រមុះ និងបំពង់ក (ENT) ដែលក្រុមហ៊ុនទទួលស្គាល់។
32. **ការបាត់បង់សមត្ថភាពក្នុងការនិយាយ** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃសមត្ថភាពក្នុងការនិយាយ ដោយតម្រូវឱ្យអនុវត្តរយៈពេលវាយតម្លៃចំនួន 6 (ប្រាំមួយ) ខែ។ ភស្តុតាងតាមផ្នែកវេជ្ជសាស្ត្រដែលបង្ហាញអំពីបញ្ហាបំពង់សម្លេងដើម្បីបញ្ជាក់ពីពិការភាពនេះ ត្រូវផ្តល់ជូនដោយវេជ្ជបណ្ឌិតជំនាញខាងផ្នែកត្រចៀក ច្រមុះ និងបំពង់ក (ENT) ដែលក្រុមហ៊ុនទទួលស្គាល់។

33. **ភាពចាំបាច់ក្នុងការព្យាបាល** មានន័យថាការព្យាបាល សេវាកម្ម ឬដំណើរការដែលវេជ្ជបណ្ឌិតជំនាញឯកទេសគិតថាសាកសម ស្របនឹងរោគវិនិច្ឆ័យ និងបទដ្ឋានទូទៅ។

34. **វេជ្ជបណ្ឌិតជំនាញឯកទេស** សំដៅដល់បុគ្គល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការព្យាបាលតាមវេជ្ជសាស្ត្រលោកខាងលិច ដែលត្រូវបានចុះបញ្ជីការជាមួយគណកម្មការវេជ្ជសាស្ត្រក្នុងប្រទេសដែលគាត់ផ្តល់សេវាវេជ្ជសាស្ត្រ ឬវះកាត់នោះ និងជាអ្នកដែលប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណ និងការបណ្តុះបណ្តាលក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ប៉ុន្តែមិនរាប់បញ្ចូលខ្លួនអ្នក សមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។
35. **សមាជិក** សំដៅដល់បុគ្គលដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។
36. **ចំណាត់ថ្នាក់សមាជិក** សំដៅដល់លំដាប់កម្រិតអត្ថប្រយោជន៍របស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ដូចដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។
37. **ចំនួនយប់** ត្រូវបានរាប់ដោយរយៈពេលខុសគ្នានៃកាលបរិច្ឆេទចូលក្នុងមន្ទីរពេទ្យ និងកាលបរិច្ឆេទចាកចេញពីមន្ទីរពេទ្យ ដោយអនុលោមតាម និយមន័យនៃការសម្រាកក្នុងមន្ទីរពេទ្យ។
38. **ក្រៅប្រទេស** សំដៅលើតំបន់ដែលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។
39. **ការខូចខាតប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងការបន្តនៃរោគសញ្ញាគ្លីនិក** គឺជារោគសញ្ញានៃដំណើរការមិនប្រក្រតីនៃប្រព័ន្ធប្រសាទដែលកើតមាននៅពេលពិនិត្យ និងរំពឹងថាអាចបន្តកើតមានពេញមួយជីវិតរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។ រោគសញ្ញាដែលត្រូវបានធានារ៉ាប់រងរួមមាន ការស្ពឹក ពិការផ្នែកណាមួយនៃរូបរាងកាយ ការចុះខ្សោយតាមកន្លែងណាមួយ និយាយមិនច្បាស់ (ការលំបាកក្នុងការនិយាយ) និយាយមិនរួច (មិនអាចនិយាយបាន) ការពិបាកលេប (ការលំបាកក្នុងការលេប) ការចុះខ្សោយនៃភ្នែក ការលំបាកក្នុងការដើរ ខ្វះលទ្ធភាពក្នុងការប្រើប្រាស់ផ្នែកណាមួយនៃរូបរាងកាយឱ្យបានស្រួល ការញ័រ ប្រកាច់ វង្វេង វង្វេង វើរវាយ និងសន្លប់ (ការលែងដឹងខ្លួនរយៈពេលវែង)។
40. **វេជ្ជបណ្ឌិតជំងឺទូទៅ** មានន័យថាអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រដែលបានចុះបញ្ជីត្រឹមត្រូវ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវបានផ្តល់អាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈពេទ្យតាមបែបបស្ចឹមប្រទេស និងអ្នកដែលប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណ និងការបណ្តុះបណ្តាលក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ប៉ុន្តែមិនរាប់បញ្ចូលខ្លួនអ្នកសមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។
41. **ខួបនៃបណ្ណសន្យារ៉ាប់រង** សំដៅទៅកាលបរិច្ឆេទដដែលៗ ជារៀងរាល់ឆ្នាំ ដូចនឹងកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។
42. **កាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង** គឺជាកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងនេះមានសុពលភាព។ កាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងត្រូវបានបង្ហាញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ហើយជាកាលបរិច្ឆេទនៃខួបនៃបណ្ណសន្យារ៉ាប់រង កាលបរិច្ឆេទនៃការបន្តបណ្ណសន្យារ៉ាប់រង និងកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង។ កាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង គឺជាកាលបរិច្ឆេទនៃការចេញបង្កាន់ដៃលេខនានា ដែលមាន

បង្ហាញក្នុងបង្អិលេខនីមួយៗរាល់ពេលដែលខសន្យា និងការធានារ៉ាប់រងដើមរបស់បណ្ណសន្យារ៉ាប់រងនេះត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់។

43. **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណសន្យារ៉ាប់រង ហើយអាចអនុវត្តបាននូវសិទ្ធិ និងជម្រើសគ្រប់យ៉ាងដែលមាននៅក្រោមបណ្ណសន្យារ៉ាប់រងនេះ។

44. **ស្ថានភាពមុនពេលធានារ៉ាប់រង** មានន័យថាជំងឺដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកបានដឹងអំពីវា។ សមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នក អាចត្រូវបានចាត់ទុកថាបានដឹងអំពីស្ថានភាពមុនពេលធានារ៉ាប់រង ដែលស្ថានភាពនេះជាស្ថានភាពមួយដែល៖
    (i) សមាជិកអ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលបានការព្យាបាល ឬ
    (ii) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំជូនអ្នក ឬ
    (iii) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
    (iv) វត្តមាននៃស្ថានភាពនោះ អាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈមួយ។

45. **ចំណាយមុនពេលធ្វើការវះកាត់** មានន័យថាសំណងនៃកម្រៃសេវាកម្មយ៉ាងសមហេតុផលសម្រាប់ការធ្វើតេស្តពិសោធន៍ ការធ្វើតេស្ត ECG ឬកាំរស្មីអ៊ិច ដែលមានភាពចាំបាច់ក្នុងការព្យាបាលនៅមន្ទីរពេទ្យ ហើយបានធ្វើឡើងដើម្បីធ្វើរោគវិនិច្ឆ័យក្នុងរយៈពេលអតិបរមានៃចំនួនថ្ងៃ និងទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង ហើយដែលត្រូវបានណែនាំដោយវេជ្ជបណ្ឌិតជំនាញឯកទេសដែលមានវិជ្ជាជីវៈច្បាស់លាស់។ នឹងមិនមានសំណងណាមួយត្រូវបានផ្តល់ជូន ប្រសិនបើចំណាយលើការធ្វើរោគវិនិច្ឆ័យនោះមិនបានតម្រូវឱ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវធ្វើការវះកាត់។

46. **ចំណាយក្រោយពេលធ្វើការវះកាត់** មានន័យថាសំណងនៃកម្រៃសេវាកម្មយ៉ាងសមហេតុផលសម្រាប់ការតាមដានស្ថានភាពក្រោយពេលធ្វើការវះកាត់ ដែលមានភាពចាំបាច់ក្នុងការព្យាបាលដោយវេជ្ជបណ្ឌិតជំនាញឯកទេសដែលមានវិជ្ជាជីវៈច្បាស់លាស់ ភ្លាមៗបន្ទាប់ពីបានទទួលការអនុញ្ញាតចេញពីមន្ទីរពេទ្យ ក្នុងរយៈពេលចំនួនថ្ងៃអតិបរមា និងទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង។ ចំណាយនេះ រួមទៅដល់ឱសថតាមវេជ្ជបញ្ជាក្នុងកំឡុងពេលការតាមដានស្ថានភាពក្រោយពេលធ្វើការវះកាត់។

47. **អ្នកផ្តល់សេវា** សំដៅទៅអ្នកផ្តល់សេវាដែលត្រូវបានភ្ជាប់ទំនាក់ទំនងដោយក្រុមហ៊ុនដើម្បីផ្តល់សេវាកម្មក្រោមសេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេសនេះ។

48. **សមហេតុផល** នឹងមិនមានការផ្តល់ជូនសម្រាប់ការចំណាយលើការស្នាក់នៅដែលលើសពីកម្រិតទូទៅបើធៀបទៅនឹងអ្នកផ្តល់សេវាដទៃទៀតក្នុងតំបន់ដែលផ្តល់ការព្យាបាល សេវាកម្ម ឬការផ្គត់ផ្គង់ដូចគ្នា ឬប្រហែលគ្នាសម្រាប់របួសដូចគ្នា។ ក្រុមហ៊ុននឹងកំណត់កម្រិតនោះ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនសម្រាប់ករណីស្រដៀងគ្នា និងសម្រង់តម្លៃដែលក្រុមហ៊ុនទទួលបានពីមន្ទីរពេទ្យដែលមានស្តង់ដាស្រដៀងគ្នាក្នុងតំបន់។

49. **កាលបរិច្ឆេទនៃការបន្តបណ្ណសន្យារ៉ាប់រង** សំដៅដល់ខួបនៃបណ្ណសន្យារ៉ាប់រង ដោយចាប់ផ្តើមពី 1 (មួយ) ឆ្នាំក្រោយ កាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។ ការបន្តបណ្ណសន្យារ៉ាប់រងនេះមានសុពលភាពផ្អែកទៅលើលក្ខខណ្ឌដែលមានចែងនៅក្រោម "ខសន្យាស្តីពីការបន្តបណ្ណសន្យារ៉ាប់រង"។

50. **ជំងឺ** មានន័យថាស្ថានភាពរូបរាងកាយ ដែលប្រែប្រួលពីស្ថានភាពសុខភាពធម្មតាដោយរោគសាស្ត្រ។

51. **ការវះកាត់** គឺជាផ្នែកមួយនៃការព្យាបាលតាមបែបវេជ្ជសាស្ត្រ ទៅលើជំងឺ និងលក្ខខណ្ឌណាមួយដែលតម្រូវឱ្យមានប្រតិបត្តិការវះកាត់ ឬការវះកាត់កែសម្រួល ឬប្រតិបត្តិការអនុវត្តដោយដៃណាមួយ ដែលត្រូវបានធ្វើឡើងនៅក្នុងបន្ទប់វះកាត់ ណាមួយដូចលក្ខខណ្ឌខាងក្រោមនេះ៖
    (i) ការវះ ឬកាត់យកចេញដោយប្រើកាំបិតវះកាត់ ឬដោយវិធី electrocautery ទៅលើសិរីរាង្គ ឬផ្នែកណាមួយនៃរូបរាងកាយ លើកលែងតែផ្នែកទន្តសាស្ត្រ
    (ii) វិធីព្យាបាលដោយការវះកាត់ ការស្តារឡើងវិញនូវសរីរាង្គ ឬផ្នែកណាមួយនៃរាង្គកាយ តាមរយៈវិធី invasive technique
    (iii) កាត់បន្ថយដោយកែសម្រួលការបាក់ឆ្អឹង ឬការប្លោះគ្រេចឆ្អឹង ឬ
    (iv) ការប្រើប្រាស់វិធី endoscopy ដើម្បីយកដុំគ្រួស ឬវត្ថុផ្សេងៗចេញពីបំពង់សម្លេង ទងសួត បំពង់ខ្យល់ បំពង់អាហារ ក្រពះពោះវៀន តម្រងនោម ឬបំពង់បង្ហូរនោម។
52. **បន្ទប់វះកាត់** គឺជាកន្លែងមួយដែលស្ថិតនៅក្នុងមន្ទីរពេទ្យ ដែលត្រូវបានរចនា និងរៀបចំឡើងដើម្បីសម្លាប់ មេរោគ សម្រាប់គោលបំណងតែមួយគត់គឺសម្រាប់ធ្វើការវះកាត់ ។
53. **ពិការភាពដោយផ្នែក** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃជើង ឬដៃម្ខាង ឬភ្នែកម្ខាង។
54. **ពិការភាពទាំងស្រុង** មានន័យថាការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយបានជារៀងរហូតនៃ៖
    (i) ជើង ឬដៃទាំងសងខាង ឬ
    (ii) ភ្នែកទាំងសងខាង ឬ
    (iii) ជើង ឬដៃម្ខាងភ្នែកម្ខាង។
55. **ការរលាកកម្រិតទីពីរ** មានន័យថាការរលាកមួយផ្នែកនៃកម្រាស់ស្បែកនៃរូបរាងកាយ ហើយគ្របដណ្តប់យ៉ាងតិចណាស់ 20% នៃរូបរាងកាយរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលបណ្តាលមកពីគ្រោះថ្នាក់។ ការរលាកស្បែកនេះ ត្រូវតែបានកំណត់ថាចាំបាច់ត្រូវការព្យាបាលក្នុងមន្ទីរពេទ្យដែលបានចុះបញ្ជីការ ហើយតម្រូវឱ្យមានការវះកាត់យកជាលិកាដែលស្លាប់ចេញ (ឧបសម្ព័ន្ធ I)។
56. **ការរលាកកម្រិតទីបី** មានន័យថាការរលាកកម្រាស់ស្បែកទាំងស្រុងនៃរូបរាងកាយ ហើយគ្របដណ្តប់យ៉ាងតិចណាស់ 20% នៃរូបរាងកាយរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលបណ្តាលមកពីគ្រោះថ្នាក់។ ការរលាកស្បែកនេះត្រូវតែបានកំណត់ថាចាំបាច់ត្រូវការព្យាបាលក្នុងមន្ទីរពេទ្យដែលបានចុះបញ្ជីការ ហើយតម្រូវឱ្យមានការវះកាត់យកជាលិកាដែលស្លាប់ចេញ (ឧបសម្ព័ន្ធ I)។
57. **ដំណើរ** មានន័យថារយៈពេលនៃការធ្វើដំណើរ ឬដំណើរចាប់ផ្តើមពីពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងចាកចេញពីព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបញ្ចប់នៅពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ។
58. **អ្នក ឬ របស់អ្នក** មានន័យថាម្ចាស់បណ្ណសន្យារ៉ាប់រងនេះ ដូចមានបង្ហាញក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

## II. កម្មវត្ថុនៃការធានា

**AIA ComCare** ជាផលិតផលធានារ៉ាប់រងអាយុជីវិតជាក្រុម ដែលមានកម្មវត្ថុនៃការធានាលើអាយុជីវិត និងរូបរាងកាយ។

**1. ការចូលរួមជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង**

(i) បុគ្គលដែលមានសិទ្ធិទទួលបានការធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ គឺជាសមាជិកអ្នកត្រូវបានធានារ៉ាប់រងបច្ចុប្បន្នរបស់អ្នក ដែលមានអាយុចាប់ពី 30 (សាមសិប) ថ្ងៃ ដល់ 69 (ហុកសិបប្រាំបួន) ឆ្នាំ នៅកាលបរិច្ឆេទនៃសុពលភាពធានារ៉ាប់រងរបស់ពួកគាត់។

(ii) សមាជិកអ្នកត្រូវបានធានារ៉ាប់រងនឹងមានសិទ្ធិទទួលបានការធានារ៉ាប់រង ចាប់ពីកាលបរិច្ឆេទនៃសុពលភាពធានារ៉ាប់រងរបស់ពួកគេ ដូចដែលបានចែងនៅក្នុងបញ្ជីសមាជិក។

(iii) សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលបានបញ្ចប់ភាពជាសមាជិក ហើយស្នើសុំចូលរួមជាសមាជិកជាថ្មី នឹងត្រូវចាត់ទុកជាសមាជិកអ្នកត្រូវបានធានារ៉ាប់រងថ្មី។

(iv) ដើម្បីបង្កើត និងបន្តបណ្ណសន្យារ៉ាប់រងនេះ សមាជិកអ្នកត្រូវបានធានារ៉ាប់រងទាំងអស់ ដែលបានបំពេញលក្ខខណ្ឌចាំបាច់ដើម្បីចូលរួមជាសមាជិក ដូចដែលបានចែងក្នុងផ្នែកទី II.1.i ខាងលើ និងបានផ្តល់ភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីភាពដែលអាចមានសិទ្ធិទទួលការធានារ៉ាប់រង ដែលតម្រូវឱ្យមានដើម្បីទទួលបានការធានាក្រោមបណ្ណសន្យារ៉ាប់រងនេះ។

(v) អ្នកត្រូវជូនដំណឹងដល់ក្រុមហ៊ុន នៅពេលដែលមានការផ្លាស់ប្តូរសមាជិកអ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ តាមរយៈការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិក និងភ្ជាប់មកជាមួយទម្រង់ជូនដំណឹងដែលបានកំណត់ដោយក្រុមហ៊ុន។ កាលបរិច្ឆេទនៃសុពលភាពធានារ៉ាប់រងសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រងអនាគតត្រូវមានសុពលភាព នៅកាលបរិច្ឆេទនៃការទទួលបានសិទ្ធិជាសមាជិក ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីភាពដែលអាចទទួលការធានារ៉ាប់រងបាន ហើយការជូនដំណឹងដល់ក្រុមហ៊ុន បានធ្វើឡើងនៅក្នុងកំឡុងពេល 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសិទ្ធិជាសមាជិក និងបានបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើក្រុមហ៊ុន ត្រូវបានជូនដំណឹងក្រោយរយៈពេល 30 (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសិទ្ធិជាសមាជិក ការធានារ៉ាប់រងនេះនឹងមានសុពលភាពនៅកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានការជូនដំណឹងនេះ ក្នុងលក្ខខណ្ឌដែលក្រុមហ៊ុនទទួលបានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីភាពដែលអាចទទួលបានការធានារ៉ាប់រង បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ និងការយល់ព្រមពីក្រុមហ៊ុន ។

(vi) ការផ្លាស់ប្តូរចំណាត់ថ្នាក់សមាជិកដែលបានបញ្ជាក់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង នឹងចូលជាធរមានតែនៅខួបនៃបណ្ណសន្យារ៉ាប់រង ឬប្រសិនបើគូភាគីព្រមព្រៀងគ្នាលើកាលបរិច្ឆេទផ្សេងទៀត ហើយនឹងផ្អែកទៅលើភស្តុតាងបញ្ជាក់អំពីសុខភាពដែលមានចែងនៅក្នុងផ្នែកភស្តុតាងបញ្ជាក់អំពីសុខភាព។

**2. ការបញ្ចប់ភាពជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង**

ការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង នឹងត្រូវបញ្ចប់នៅពេលដែលព្រឹត្តិការណ៍ណាមួយខាងក្រោមកើតឡើងមុន៖

(i) នៅពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានបញ្ចប់ភាពជាសមាជិកជាមួយអ្នក កាលបរិច្ឆេទនៃការបញ្ចប់ភាពជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង នឹងត្រូវជាកាលបរិច្ឆេទនៃការបញ្ចប់ភាពជាសមាជិកជាមួយអ្នក ឬកាលបរិច្ឆេទជូនដំណឹងនៃការបញ្ចប់ភាពជាសមាជិកជាមួយអ្នក ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ ឬ

(ii) ប្រសិនបើវិញ្ញាបនបត្រធានារ៉ាប់រងបានចែងថា សមាជិកត្រូវជាសមាជិកដែលកំពុងបំពេញការងារជាសមាជិកនៃស្ថាប័ន អវត្តមាននៃសមាជិកអ្នកត្រូវបានធានារ៉ាប់រងពីការកំពុងបំពេញការងារជាសមាជិកនៃស្ថាប័ន ដោយសារពិការភាព ឬការឈប់សម្រាក ឬការបញ្ឈប់ជាបណ្តោះអាសន្ន នឹងមិនត្រូវរាប់បញ្ចូលជាការបញ្ចប់ភាពជាសមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះទេ លុះត្រាតែអ្នកបានជូនដំណឹងដល់ក្រុមហ៊ុន អំពីការបញ្ចប់បែបនេះជាមុន ឬក្នុងកំឡុងពេល 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់ ឬការបញ្ឈប់ការទូទាត់បុព្វលាភធានារ៉ាប់រងសម្រាប់ការធានារ៉ាប់រងនៃសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬ

(iii) នៅកាលបរិច្ឆេទទូទាត់បុព្វលាភធានារ៉ាប់រង ត្រូវបានបញ្ចប់សម្រាប់ការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយក្រុមហ៊ុនទទួលបានការជូនដំណឹងពីអ្នកថាការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះត្រូវបានបញ្ចប់ ឬ

(iv) នៅកាលបរិច្ឆេទដែលក្រុមហ៊ុន ឬអ្នកបានបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ឬ

(v) សមាជិកអ្នកត្រូវបានធានារ៉ាប់រងមានអាយុដល់ 70 ឆ្នាំ ឬ

(vi) ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងណាមួយ នៅពេលដែលចំនួនសរុបនៃសមាជិកអ្នកត្រូវបានធានារ៉ាប់រង តិចជាងចំនួនអប្បបរមានៃសមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលមានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ឬ

(vii) កាលបរិច្ឆេទដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ចូលបម្រើសេវាយោធា កងទ័ពជើងទឹក ឬអាកាស ឬ

(viii) កាលបរិច្ឆេទដែលក្រុមហ៊ុនបានទំនាក់ទំនងជាមួយអ្នកថា បណ្ណសន្យារ៉ាប់រងនេះ ត្រូវបញ្ឈប់ដោយសារសង្គ្រាម ឬសកម្មភាពនៃសង្គ្រាម ដែលត្រូវបានកំណត់ដោយឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុន។

### 3. ភស្តុតាងបញ្ជាក់អំពីសុខភាព

ក្រុមហ៊ុនអាចតម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីសុខភាព មុនពេលក្រុមហ៊ុនយល់ព្រមផ្តល់ការធានាដល់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ក្នុងករណី

(i) អាយុសមាជិកអ្នកត្រូវបានធានារ៉ាប់រង នៅកាលបរិច្ឆេទនៃការបន្តបណ្ណសន្យារ៉ាប់រង ដល់ ឬលើសពី 65 ឆ្នាំ ឬ

(ii) ទឹកប្រាក់ធានារ៉ាប់រង ដែលលើសពីកម្រិតដែលមិនត្រូវការភស្តុតាងដូចដែលបានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង ឬ

(iii) មានការបន្ថែមចំនួនទឹកប្រាក់ធានារ៉ាប់រងសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។

នៅពេលដែលភស្តុតាងបញ្ជាក់អំពីសុខភាព មិនជាទីគាប់ចិត្តដល់ក្រុមហ៊ុន នោះអត្ថប្រយោជន៍ទាំងមូល (សម្រាប់អ្នកដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ) ឬផ្នែកនៃអត្ថប្រយោជន៍ដែលលើសពីកម្រិតដែលមិនតម្រូវឱ្យមានភស្តុតាង (សម្រាប់អ្នកដែលមានអាយុក្រោម 65 ឆ្នាំ) នឹងមិនត្រូវបានផ្តល់ជូន ឬត្រូវបានផ្តល់ជូន ផ្អែកទៅលើលក្ខខណ្ឌពិសេស និង/ឬ បុព្វលាភធានារ៉ាប់រងបន្ថែមដែលក្រុមហ៊ុនអាចនឹងកំណត់ដោយឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុន។

## III. វិសាលភាពធានារ៉ាប់រង

សមាជិកអ្នកត្រូវបានធានារ៉ាប់រង នឹងមិនត្រូវបានធានា សម្រាប់ការទិញអត្ថប្រយោជន៍ណាមួយ បន្ទាប់ពីខួបកំណើតអាយុ 70 ឆ្នាំរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះ។

1. **អត្ថប្រយោជន៍ការពារគ្រួសារ**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព នៅពេលដែលបណ្ណសន្យារ៉ាប់រងនេះកំពុងមានសុពលភាព ក្រុមហ៊ុននឹងផ្តល់ទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ជូនអ្នកទាមទារសំណងដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រងនេះ ដកអត្ថប្រយោជន៍ដែលបានផ្តល់ជូនក្នុងករណីទទួលពិការភាពដោយផ្នែក និងពិការភាពទាំងស្រុង ទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងរូបនោះ យោងតាម ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ។

2. **អត្ថប្រយោជន៍លើការស្តារនីតិសម្បទា**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលពិការភាពដោយផ្នែក (ដូចដែលបានកំណត់និយមន័យខាងលើ) នៅពេលដែលអត្ថប្រយោជន៍នេះកំពុងមានសុពលភាព ក្រុមហ៊ុននឹងផ្តល់ជូនឱ្យអ្នកទាមទារសំណងនូវទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក រហូតដល់កម្រិតដែលបានកំណត់សម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនីមួយៗ ដូចដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រងនេះ។ បន្ទាប់ពីនោះ នឹងមិនមានអត្ថប្រយោជន៍សម្រាប់ពិការភាពដោយផ្នែកណាមួយ អាចផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះទៀតឡើយ។

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលពិការភាពទាំងស្រុង (ដូចដែលបានកំណត់និយមន័យខាងលើ) នៅពេលដែលអត្ថប្រយោជន៍នេះកំពុងមានសុពលភាព ក្រុមហ៊ុននឹងផ្តល់ជូនឱ្យអ្នកទាមទារសំណងនូវទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រងនេះ ដកអត្ថប្រយោជន៍ដែលបង់ជូនរួចសម្រាប់ពិការភាពដោយផ្នែកណាមួយ។ បន្ទាប់ពីនោះ នឹងមិនមានអត្ថប្រយោជន៍សម្រាប់ពិការភាពដោយផ្នែក ឬពិការភាពទាំងស្រុងណាមួយ អាចផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះទៀតឡើយ។

ចំនួនទឹកប្រាក់សរុបអតិបរមាដែលនឹងបង់ជូននៅក្រោមអត្ថប្រយោជន៍នេះ មិនត្រូវលើសពី 100% (មួយរយភាគរយ) នៃទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិកក្រោមអត្ថប្រយោជន៍លើការស្តារនីតិសម្បទាឡើយ។

ចំនួនទឹកប្រាក់សរុប ដែលនឹងបង់ជូននៅក្រោមអត្ថប្រយោជន៍លើការស្តារនីតិសម្បទា មិនត្រូវលើសពី 100% (មួយរយភាគរយ) នៃទឹកប្រាក់ធានារ៉ាប់រងក្រោមអត្ថប្រយោជន៍ការពារគ្រួសារឡើយ។

3. **អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ (ដូចដែលបានកំណត់និយមន័យខាងលើ) ហើយបណ្តាលឱ្យមានពិការភាព ដូចដែលមានកំណត់ក្រោមពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យក្រុមទី 1 ឬទទួលរងការរលាកកម្រិតទី 2 ក្រុមហ៊ុននឹងបង់ជូនអ្នកទាមទារសំណង នូវទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានា

នៃក្នុងបណ្ណសន្យារ៉ាប់រងនេះ។ បន្ទាប់ពីនោះ នឹងមិនមានអត្ថប្រយោជន៍សម្រាប់ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1 ឬទទួលរងការរលាកកម្រិតទី 2 ណាមួយ អាចផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះទៀតឡើយ។

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ (ដូចដែលបានកំណត់និយមន័យខាងលើ) ហើយបណ្តាលឱ្យទទួលមរណភាព ឬមានពិការភាព ដូចដែលមានកំណត់ក្រោមពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 2 ឬទទួលរងការរលាកកម្រិតទី 3 ក្រុមហ៊ុននឹងបង់ជូនអ្នកទាមទារសំណង នូវទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខលក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រងនេះ ដកអត្ថប្រយោជន៍ដែលបានបង់រួចសម្រាប់ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1 ឬទទួលរងការរលាកកម្រិតទី 2 ណាមួយ ដែលបានផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងរូបនោះ។ បន្ទាប់ពីនោះ នឹងមិនមានអត្ថប្រយោជន៍មរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ អាចផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងនោះទៀតឡើយ។

ចំនួនទឹកប្រាក់សរុបអតិបរមា ដែលនឹងបង់ជូននៅក្រោមអត្ថប្រយោជន៍នេះ មិនត្រូវលើសពី 100% (មួយរយភាគរយ) នៃទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក សម្រាប់អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ របស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងឡើយ ។

## 4. អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺធ្ងន់ធ្ងរណាមួយ (ដូចដែលបានកំណត់និយមន័យខាងលើ) ក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងមានសុពលភាព និងបានរស់រានមានជីវិត 30 ថ្ងៃ រាប់ចាប់ពីកាលបរិច្ឆេទនៃការធ្វើរោគវិនិច្ឆ័យ នោះក្រុមហ៊ុននឹងផ្តល់អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺដល់អ្នកទាមទារសំណង ដោយអនុលោមតាម ខ លក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រង ។

ការផ្តល់ជូនអត្ថប្រយោជន៍ត្រូវធ្វើឡើងដោយអនុលោមតាម ខ និងលក្ខខណ្ឌដូចខាងក្រោម៖

**(i) អត្ថប្រយោជន៍សម្រាប់ការព្យាបាល អាការៈជំងឺ ឬការវះកាត់ក្រុមទី 1**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា មានអាការៈជំងឺធ្ងន់ធ្ងរ ដូចដែលបានកំណត់ជាអាការៈជំងឺ ឬការវះកាត់ក្រុមទី 1 ដែលបានកំណត់ក្នុងអត្ថប្រយោជន៍នេះ ក្រុមហ៊ុននឹងផ្តល់ជូនអ្នកទាមទារសំណងនូវទឹកប្រាក់ធានារ៉ាប់រង ដែលបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក រហូតដល់កម្រិតទឹកប្រាក់ធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រងនិងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានាដែលបានចែងក្រោមបណ្ណសន្យារ៉ាប់រងនេះ។ បន្ទាប់ពីនេះ ពុំមានអត្ថប្រយោជន៍ណាមួយនឹងត្រូវបង់ជូនសម្រាប់អាការៈជំងឺ ឬការវះកាត់ក្រុមទី 1 ទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងរូបនោះទៀតឡើយ។

**(ii) អត្ថប្រយោជន៍ព្យាបាលសម្រាប់អាការៈជំងឺ ឬការវះកាត់ក្រុមទី 2**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រង ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា បានទទួលរងអាការៈជំងឺ ឬការវះកាត់ក្រុមទី 2 ដែលបានកំណត់ក្នុងអត្ថប្រយោជន៍នេះ ក្រុមហ៊ុននឹងផ្តល់ជូនអ្នកទាមទារសំណងនូវទឹកប្រាក់ធានារ៉ាប់រង ដែលបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ដកអត្ថប្រយោជន៍បង់ជូនសម្រាប់អាការៈជំងឺ ឬការវះ

កាត់ក្រុមទី 1 សម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។ បន្ទាប់ពីនេះ ពុំមានអត្ថប្រយោជន៍ណាមួយនឹងត្រូវបង់ជូនសម្រាប់អាការៈជំងឺ ឬការវះកាត់ក្រុមទី 2 ទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងរូបនោះទៀតឡើយ។

ចំនួនទឹកប្រាក់សរុប ដែលនឹងបង់ជូននៅក្រោមអត្ថប្រយោជន៍សម្រាប់ការព្យាបាលអាការៈជំងឺ ឬការវះកាត់ក្រុមទី 1 និង 2 មិនត្រូវលើស 100% (មួយរយភាគរយ) នៃទឹកប្រាក់ធានារ៉ាប់រងនៃអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ ដូចដែលមានចែងនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។

### 5. អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ

អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ផ្ដល់ការធានាលើចំណាយផ្សេងៗ ដែលបណ្ដាលមកពីរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ ដូចបានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ ប្រសិនបើអ្នកបានជ្រើសរើសជម្រើសពេញលេញ អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ផ្ដល់ការធានាចំណាយផ្សេងៗដែលបណ្ដាលមកពីជំងឺ ដូចបានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

#### (i) ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ

នៅពេលដែលអត្ថប្រយោជន៍នេះមានសុពលភាព ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវតម្រូវឱ្យសម្រាកក្នុងមន្ទីរពេទ្យតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតជំនាញឯកទេស ហើយការសម្រាកនេះសមហេតុផល ក្រុមហ៊ុននឹងផ្ដល់ជូនអត្ថប្រយោជន៍សម្រាប់ចំណាយសម្រាកក្នុងមន្ទីរពេទ្យ តាមចំនួនដែលបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង គុណនឹងចំនួនយប់នៃការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង រហូតដល់ចំនួនកំណត់របស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានាដែលបានកំណត់។

ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យនេះ អាចផ្ដល់ជូនសម្រាប់ការសម្រាកទាំងក្នុងមន្ទីរពេទ្យក្នុងស្រុក និងក្រៅស្រុក។

#### (ii) ចំណាយលើការវះកាត់

នៅពេលដែលអត្ថប្រយោជន៍នេះមានសុពលភាព ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវតម្រូវឱ្យធ្វើការវះកាត់ ដែលតម្រូវដោយវេជ្ជបណ្ឌិតជំនាញឯកទេស ហើយការវះកាត់នេះសមហេតុផល ក្រុមហ៊ុននឹងផ្ដល់ជូនអត្ថប្រយោជន៍សម្រាប់ចំណាយលើការវះកាត់ តាមចំនួនទឹកប្រាក់ធានារ៉ាប់រងដែលបានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ អត្ថប្រយោជន៍នេះ ផ្ដល់ការធានាលើការវះកាត់ ចំណាយមុនការវះកាត់ និងចំណាយក្រោយការវះកាត់ រហូតដល់កម្រិតទឹកប្រាក់ធានារ៉ាប់រង ដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានាដែលបានកំណត់។

#### (iii) សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស

នៅពេលដែលអត្ថប្រយោជន៍នេះនៅមានសុពលភាព ក្រុមហ៊ុននឹងផ្ដល់ជូនការធានាដូចខាងក្រោម ដែលនឹងត្រូវបានរៀបចំ និងអនុវត្តដោយអ្នកផ្ដល់សេវា ដែលនឹងប្រើប្រាស់មធ្យោបាយ និងសេវាកម្មដែលសាកសមបំផុតចំពោះលក្ខខណ្ឌរាងកាយរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង រហូតដល់កម្រិតទឹកប្រាក់ធានារ៉ាប់រង ដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ដោយផ្អែកទៅតាម ខ លក្ខខណ្ឌ និងករណីមិនធានាដែលបានកំណត់។

អ្នកផ្តល់សេវា នឹងត្រូវផ្តល់សេវាកម្មទាំងនេះ នៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទូរស័ព្ទទៅកាន់អ្នកផ្តល់សេវានៅពេលគាត់ធ្វើដំណើរនៅក្រៅព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេលមិនលើសពី 90 ថ្ងៃនៃដំណើររបស់ខ្លួន។

សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេសមានសេវាបីធំៗ៖

a. **ការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់**

នៅពេលធ្វើដំណើរនៅក្រៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ដែលត្រូវបានកំណត់ថាមានភាពចាំបាច់ក្នុងការព្យាបាល ដោយក្រុមហ៊ុន ឬអ្នកផ្តល់សេវា នោះអ្នកផ្តល់សេវានឹងធ្វើការរៀបចំការជម្លៀសនេះ ដោយប្រើប្រាស់មធ្យោបាយសមស្របផ្អែកទៅលើស្ថានភាពសមាជិកអ្នកត្រូវបានធានារ៉ាប់រង។

រាល់ការជ្រើសរើសមធ្យោបាយដឹកជញ្ជូន និងទិសដៅនៃការជម្លៀសសមាជិកអ្នកត្រូវបានធានារ៉ាប់រង ត្រូវសម្រេចដោយក្រុមហ៊ុន ឬអ្នកផ្តល់សេវា ដោយផ្អែកលើភាពចាំបាច់នៃការព្យាបាលតាមវេជ្ជសាស្ត្រ។

រាល់ការចំណាយក្នុងការផ្តល់សេវានេះនឹងត្រូវជាចំណាយសម្រាប់សេវាកម្មដែលផ្តល់ និង/ឬ រៀបចំដោយក្រុមហ៊ុន ឬអ្នកផ្តល់សេវាសម្រាប់មធ្យោបាយដឹកជញ្ជូនដែលចាំបាច់ក្នុងការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់។ ក្រុមហ៊ុននឹងទូទាត់ជូនអ្នកផ្តល់សេវា ឬភាគីទីបីណាមួយដោយផ្ទាល់។

ការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ សំដៅទៅលើ (ក) ស្ថានភាពសមាជិកអ្នកត្រូវបានធានារ៉ាប់រងតម្រូវឱ្យមានការជម្លៀសភ្លាមៗ ទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត ដែលអាចទទួលបានការព្យាបាលវេជ្ជសាស្ត្រសមស្រប តាមការកំណត់ដោយឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុន ឬអ្នកផ្តល់សេវា ឬ (ខ) ក្រោយពីការព្យាបាលនៅក្នុងមន្ទីរពេទ្យក្នុងតំបន់កើតហេតុ ស្ថានភាពសមាជិកអ្នកត្រូវបានធានារ៉ាប់រងទាមទារឱ្យមានការជម្លៀសមកព្រះរាជាណាចក្រកម្ពុជាវិញដើម្បីព្យាបាលបន្ត។

b. **ការដឹកសាកសពត្រលប់មកវិញ**

ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ខណៈដែលធ្វើដំណើរនៅក្រៅព្រះរាជាណាចក្រកម្ពុជា ហើយទទួលមរណភាពដោយគ្រោះថ្នាក់ចៃដន្យ ក្នុងកំឡុងពេល 365 ថ្ងៃ ពីកាលបរិច្ឆេទគ្រោះថ្នាក់ ក្រុមហ៊ុន ឬអ្នកផ្តល់សេវានឹងរៀបចំមធ្យោបាយដឹកជញ្ជូនយកសាកសពសមាជិកអ្នកត្រូវបានធានារ៉ាប់រងមកព្រះរាជាណាចក្រកម្ពុជាវិញ។

អត្ថប្រយោជន៍នេះនឹងធានាលើការចំណាយសម្រាប់សេវាកម្មដែលផ្តល់ជូន ឬរៀបចំដោយក្រុមហ៊ុន ឬអ្នកផ្តល់សេវាសម្រាប់ថ្លៃចំណាយការដឹកជញ្ជូនចាំបាច់ ដែលកើតឡើងពេលដឹកសាកសពសមាជិកអ្នកត្រូវបានធានារ៉ាប់រងមកព្រះរាជាណាចក្រកម្ពុជាវិញ។ ក្រុមហ៊ុននឹងទូទាត់ជូនអ្នកផ្តល់សេវា ឬភាគីទីបីណាមួយដោយផ្ទាល់។

c. **សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោង**

នៅពេលដែលអត្ថប្រយោជន៍នេះមានសុពលភាព សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោងនឹងផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងមុនពេល ឬក្នុងកំឡុងពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងធ្វើដំណើរ។

សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោង ត្រូវបានកំណត់ត្រឹមសេវាកម្មសាកសួរតាមទូរស័ព្ទពាក់ព័ន្ធនឹងការធ្វើដំណើរ។ ក្រុមហ៊ុននឹងមិនទទួលខុសត្រូវលើចំណាយណាមួយ (រួមមានថ្លៃថ្នាំពេទ្យ ឬសេវាកម្មច្បាប់ និងថ្លៃសម្រាប់សេវាផ្សេងៗ) ដែលបង្កដោយអ្នកត្រូវបានធានារ៉ាប់រង និង/ឬអ្នកដែលពាក់ព័ន្ធក្នុងការអនុវត្តតាមដំបូន្មាន ឬការណែនាំដែលផ្តល់ចេញពីសេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោង។

សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោង ត្រូវបានផ្តល់តាមលទ្ធភាពដែលអាចទៅរួច ហើយ សេវានេះអាចនឹងមិនអាចផ្តល់ជូនដោយសារតែបញ្ហាភស្តុភារ ដូចជាពេលវេលា ចំងាយ ទីកន្លែង ឬកត្តាផ្សេងៗ ដែលមិនឋិតក្នុងការគ្រប់គ្រងរបស់អ្នកផ្តល់សេវា។ ដោយមិនបំពានលើលក្ខខណ្ឌទូទៅនៃអត្ថប្រយោជន៍នេះ ក្រុមហ៊ុន ឬអ្នកផ្តល់សេវានឹងមិនត្រូវទទួលខុសត្រូវសម្រាប់ការខូចខាត ឬបាត់បង់ណាដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងរងគ្រោះពីការខកខាន យឺតយ៉ាវ ឬលុបចោលការផ្តល់សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក 24 ម៉ោងឡើយ។

**ខ និងលក្ខខណ្ឌទូទៅនៃសេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស**

a. ក្នុងករណីមានការបង់ប្រាក់ដោយក្រុមហ៊ុន ឬអ្នកផ្តល់សេវា ឬតំណាងពេញសិទ្ធិរបស់អ្នកផ្តល់សេវាសម្រាប់ការទាមទារសំណងសេវាជំនួយសង្គ្រោះបន្ទាន់ ដែលមិនត្រូវបានធានាក្រោមអត្ថប្រយោជន៍នេះ ក្រុមហ៊ុន ឬអ្នកផ្តល់សេវា ឬតំណាងពេញសិទ្ធិរបស់អ្នកផ្តល់សេវារក្សាសិទ្ធិទាមទារសំណងដែលបង់ជូននោះពីសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រលប់មកវិញ។

b. ក្រុមហ៊ុន ឬអ្នកផ្តល់សេវាមិនអាចទទួលខុសត្រូវសម្រាប់ការខកខាន ឬការយឺតយ៉ាវក្នុងការបំពេញសេវាកម្ម នៅពេលដែលមាន កូដកម្ម កុបកម្ម ឬសកម្មភាពបំផ្លិចបំផ្លាញដោយចេតនា ឬភេរវកម្ម សង្គ្រាមស៊ីវិល ឬសង្គ្រាមជាមួយបរទេស ការបញ្ចេញកំដៅពីជាតិនុយក្លេអ៊ែរ វិទ្យុសកម្ម គ្រោះថ្នាក់ ឬគ្រោះធម្មជាតិផ្សេងៗ។

   ការអន្តរាគមន៍ដោយអ្នកផ្តល់សេវាត្រូវបានធ្វើឡើងក្នុងបរិបទច្បាប់ និងបញ្ញត្តិ ជាតិ និងអន្តរជាតិ ហើយផ្អែកលើការផ្តល់សិទ្ធិចាំបាច់ដែលទទួលបានពីអាជ្ញាធរដែលពាក់ព័ន្ធ។

c. ការធានារ៉ាប់រងក្រោមអត្ថប្រយោជន៍នេះ នឹងត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ ក្នុងករណីខាងក្រោមណាមួយដែលកើតមុន៖
   - ការបញ្ចប់បណ្ណសន្យារ៉ាប់រង ឬការបញ្ចប់ភាពជាសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬ
   - ការបាត់បង់ជាក់លាក់ណាមួយ ដែលតម្រូវឱ្យមានសំណងការដឹកសាកសពត្រលប់មកវិញក្រោមអត្ថប្រយោជន៍នេះ
   - អ្នកផ្តល់សេវា ឬតំណាងពេញសិទ្ធិរបស់អ្នកផ្តល់សេវា មិនមែនជាភ្នាក់ងាររបស់ក្រុមហ៊ុន ហើយក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវសម្រាប់សកម្មភាព ឬការលុបចោលការផ្តល់សេវាកម្មរបស់អ្នកផ្តល់សេវានោះទេ។

## IV. អត្ថប្រយោជន៍ធានារ៉ាប់រង

អត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងនេះ រួមមាន៖

| ល.រ | ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | ទឹកប្រាក់ធានារ៉ាប់រង |
|---|---|---|
| **1.** | អត្ថប្រយោជន៍ការពារគ្រួសារ | **% នៃអត្ថប្រយោជន៍ ការពារគ្រួសារ** |
| | មរណភាព | **100%** |
| **2.** | អត្ថប្រយោជន៍លើការស្ថានីតិសម្បទា | **% នៃអត្ថប្រយោជន៍ លើការស្តារនីតិសម្បទា** |
| 2.1 | ពិការភាពទាំងស្រុង៖ | |
| | ការបាត់បង់ជើង ឬដៃទាំងសងខាង | 100% |
| | ការបាត់បង់ភ្នែកទាំងសងខាង | 100% |
| | ការបាត់បង់ជើង ឬដៃម្ខាងភ្នែកម្ខាង | 100% |
| 2.2 | ពិការភាពដោយផ្នែក៖ | |
| | ការបាត់បង់ជើង ឬដៃម្ខាង | រហូតដល់ 50% |
| | ការបាត់បង់ភ្នែកម្ខាង | រហូតដល់ 50% |
| **3** | អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ | **% នៃអត្ថប្រយោជន៍លើ មរណភាព និងការរងរបួស ដោយគ្រោះថ្នាក់ចៃដន្យ** |
| 3.1 | មរណភាពដោយគ្រោះថ្នាក់ចៃដន្យ | 100% |
| 3.2 | ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 2 ឬការរលាកកម្រិតទី 3 | |
| | ការរលាកកម្រិតទី 3 | 100% |
| | ការបាត់បង់ជើង ឬដៃទាំងសងខាង ឬ | 100% |
| | ការបាត់បង់ភ្នែកទាំងសងខាង ឬ | 100% |
| | ការបាត់បង់ជើង ឬដៃម្ខាងភ្នែកម្ខាង។ | 100% |
| | ការបាត់បង់សមត្ថភាពក្នុងការនិយាយ ឬ | 100% |
| | ការបាត់បង់ការស្តាប់លឺនៃត្រចៀកទាំងសងខាង | 100% |
| 3.3 | ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1 ឬការរលាកកម្រិតទី 2 | |
| | ការរលាកកម្រិតទី 2 | រហូតដល់ 50% |
| | ការបាត់បង់ជើង ឬដៃម្ខាង | រហូតដល់ 50% |
| | ការបាត់បង់ភ្នែកម្ខាង | រហូតដល់ 50% |
| | ការបាត់បង់មេដៃទាំងសងខាង (2 សន្លាក់ ឬថ្នាំងនៃមេដៃនីមួយៗ) | រហូតដល់ 30% |
| | ការបាត់បង់មេជើងទាំងសងខាង (2 សន្លាក់ ឬថ្នាំងនៃមេជើងនីមួយៗ) | រហូតដល់ 30% |
| | ការបាត់បង់ម្រាមដៃទាំងបួន (3 សន្លាក់ ឬថ្នាំង នៃម្រាមដៃនីមួយៗ) និង មេដៃមួយ (2 សន្លាក់ ឬថ្នាំងនៃមេដៃ) នៃដៃតែម្ខាង | រហូតដល់ 30% |

| | | |
|---|---|---|
| | ការបាត់បង់ម្រាមជើងទាំងបួន (យ៉ាងតិចណាស់ 1 សន្លាក់ ឬថ្នាំងនៃម្រាមជើងនីមួយៗ) និងមេជើងមួយ (2 សន្លាក់ ឬថ្នាំងនៃមេជើង) នៃជើងតែម្ខាង | រហូតដល់ 30% |
| | ការបាត់បង់ការស្តាប់លឺនៃត្រចៀកម្ខាង | រហូតដល់ 15% |
| | ការបាត់បង់មេដៃទាំងមូល (2 សន្លាក់ ឬថ្នាំងនៃមេដៃ) | រហូតដល់ 10% |
| | ការបាត់បង់ម្រាមដៃចង្អុលទាំងមូល (3 សន្លាក់ ឬថ្នាំង) | រហូតដល់ 8% |
| | ការបាត់បង់ម្រាមដៃកណ្តាលទាំងមូល (3 សន្លាក់ ឬថ្នាំង) | រហូតដល់ 6% |
| | ការបាត់បង់ម្រាមដៃនាងទាំងមូល (3 សន្លាក់ ឬថ្នាំង) | រហូតដល់ 5% |
| | ការបាត់បង់ម្រាមកូនដៃទាំងមូល (3 សន្លាក់ ឬថ្នាំង) | រហូតដល់ 4% |
| **4** | **អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ** | **% នៃអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ** |
| 4.1 | អាការៈជំងឺ ឬការវះកាត់ក្រុមទី 2 | 100% |
| 4.2 | អាការៈជំងឺ ឬការវះកាត់ក្រុមទី 1 | រហូតដល់ 25% |
| **5** | **អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ** | **% នៃអត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ** |
| 5.1 | ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ | ដូចដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង |
| 5.2 | ចំណាយលើការវះកាត់ | ដូចដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង |
| 5.3 | សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស | ដូចដែលបានកំណត់នៅលើវិញ្ញាបនបត្រធានារ៉ាប់រង |

# V. ការបង់បុព្វលាភធានារ៉ាប់រង

## 1. វិធីសាស្ត្រនៃការបង់បុព្វលាភធានារ៉ាប់រង

ដោយអនុលោមតាមលក្ខខណ្ឌអប្បបរមានៃបុព្វលាភធានារ៉ាប់រងរបស់ក្រុមហ៊ុន ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងជាប្រចាំឆ្នាំ តាមអត្រាដែលត្រូវអនុវត្តនៅកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។

ម្ចាស់បណ្ណសន្យារ៉ាប់រងអាចបង់បុព្វលាភធានារ៉ាប់រង តាមមធ្យោបាយផ្សេងៗដែលបានកំណត់ដោយក្រុមហ៊ុន។ លិខិតតម្កល់ប្រាក់ដែលមានសុពលភាព ឬការកាត់បុព្វលាភធានារ៉ាប់រងចេញពីគណនីដែលបង្ហាញក្នុងរបាយការណ៍គណនីរបស់អ្នកត្រូវបានចាត់ទុកថាជាភស្តុតាងនៃការបានបង់ប្រាក់រួច។

## 2. អត្រាបុព្វលាភធានារ៉ាប់រង

ក្រុមហ៊ុនមានសិទ្ធិផ្លាស់ប្តូរអត្រាបុព្វលាភធានារ៉ាប់រងដែលនឹងត្រូវបានគណនា (ក) នៅខួបនៃបណ្ណសន្យារ៉ាប់រងណាមួយ ឬ (ខ) នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងណាមួយ ក្នុងករណីដែលអត្រាបុព្វលាភធានារ៉ាប់រងត្រូវបានគិតនៅពេលនោះមានសុពលភាពយ៉ាងហោចណាស់ 12 (ដប់ពីរ) ខែ ឬ (គ) នៅពេលដែលហានិភ័យ

ដែលបានជានាក្រោមបណ្ណសន្យារ៉ាប់រងនេះ បានកើនឡើង ឬ (ឃ) នៅពេលមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះសមាជិកភាព ដែលប៉ះពាល់ដល់បុព្វលាភធានារ៉ាប់រង ហើយដែលក្រុមហ៊ុនបានជូនដំណឹងដល់អ្នក យ៉ាងហោចណាស់ 30 (សាមសិប) ថ្ងៃ មុនដល់កាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង។

ការកែសម្រួលបុព្វលាភធានារ៉ាប់រង ដែលពាក់ព័ន្ធជាមួយនឹងការប្រគល់បុព្វលាភធានារ៉ាប់រងដែលមិនទាន់ទទួលស្គាល់ជាចំណូលរបស់ក្រុមហ៊ុន ទៅម្ចាស់បណ្ណសន្យារ៉ាប់រង នឹងត្រូវបានកំណត់ត្រឹមរយៈពេលចាប់ផ្តើមខួបនៃបណ្ណសន្យារ៉ាប់រងចុងក្រោយ ដែលមានមុនកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានភស្តុតាង ដែលបញ្ជាក់ថាត្រូវមានការកែសម្រួលនេះ។

3. **ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រង**

បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី 1 (មួយ) ការមិនបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅ ឬមុនកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងនឹងត្រូវចាត់ទុកជាការខកខានបង់បុព្វលាភធានារ៉ាប់រង។

4. **រយៈពេលអនុគ្រោះ**

រយៈពេលអនុគ្រោះចំនួន 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង នឹងត្រូវបានអនុញ្ញាតឱ្យអ្នក សម្រាប់ការបង់បុព្វលាភធានារ៉ាប់រងណាមួយ បន្ទាប់ពីការបង់លើកដំបូងនៅក្នុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។ ប្រសិនបើបុព្វលាភធានារ៉ាប់រងណាមួយ មិនបានបង់មុនរយៈពេលអនុគ្រោះផុតកំណត់នោះ បណ្ណសន្យារ៉ាប់រងនេះ នឹងបានបញ្ចប់ដោយស្វ័យប្រវត្តិ នៅកាលបរិច្ឆេទការអស់សុពលភាពនៃរយៈពេលអនុគ្រោះនោះ។ បណ្ណសន្យារ៉ាប់រងនេះ នឹងបន្តមានសុពលភាពអនុវត្តក្នុងកំឡុងរយៈពេលពន្យារបន្ថែមនេះ។ អ្នកត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុន សម្រាប់បុព្វលាភធានារ៉ាប់រង ខណៈពេលដែលបណ្ណសន្យារ៉ាប់រងមានសុពលភាពក្នុងរយៈពេលអនុគ្រោះ។

5. **រូបិយប័ណ្ណ និងមធ្យោបាយបង់ប្រាក់**

រាល់ទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន ឬដោយក្រុមហ៊ុន ត្រូវជារូបិយប័ណ្ណដែលមានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង ឬបដ្ឋិលេខបន្តបន្ទាប់ទៀត។ រាល់ទឹកប្រាក់ដែលក្រុមហ៊ុនត្រូវបង់ត្រូវធ្វើឡើងតាមមធ្យោបាយដែលកំណត់ដោយក្រុមហ៊ុន។

6. **បន្ទុកថ្លៃចំណាយនានាដែលកំណត់ដោយបទប្បញ្ញត្តិ ឬច្បាប់**

បុព្វលាភធានារ៉ាប់រងដែលត្រូវបង់ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ក្រោមបណ្ណសន្យារ៉ាប់រងនេះ គឺមិនបូកបញ្ចូលពន្ធណាមួយឡើយ ហើយក្នុងករណីដែលច្បាប់តម្រូវឱ្យក្រុមហ៊ុនបង់ពន្ធលើបុព្វលាភធានារ៉ាប់រងដែលបង់ដោយម្ចាស់បណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុននឹងគណនា ហើយប្រមូលពីម្ចាស់បណ្ណសន្យារ៉ាប់រងនូវចំនួនទឹកប្រាក់ដែលបានបង់ ឬត្រូវបង់ ដោយបូកបញ្ចូលពន្ធដែលត្រូវបង់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។ ចំនួនដែលបានគណនាដោយក្រុមហ៊ុននេះ ត្រូវបង់ដោយម្ចាស់បណ្ណសន្យារ៉ាប់រងជាថ្លៃបន្ថែម និងដោយមិនមានការដក ឬកាត់កងពីចំនួនបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ក្រោមបណ្ណសន្យារ៉ាប់រងនេះនោះទេ។ ពន្ធមានន័យថា ពន្ធក្នុងពេលបច្ចុប្បន្ន ឬអនាគត ដោយ

ផ្ទាល់ ឬដោយប្រយោល រាប់បញ្ចូលទាំងពន្ធលើទំនិញ និងសេវាកម្ម ពន្ធ អាករ បន្ទុក កម្រៃ ការដកហូត ឬការកាត់ទុក ទោះក្នុងទម្រង់ណាមួយក៏ដោយ និងរាល់ការប្រាក់ ព្រមទាំងការពិន័យនានាពាក់ព័ន្ធនឹងចំណុចទាំងនេះ។

## VI. ករណីមិនធានា

### 1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍ការពារគ្រួសារ

អត្ថប្រយោជន៍ការពារគ្រួសារមិនធានាលើមរណភាពដែលបណ្តាលមកពី៖

(i) ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីថ្ងៃចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាន ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(ii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(iii) វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(iv) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### 2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា

អត្ថប្រយោជន៍លើការស្លាប់នីតិសម្បទា នឹងមិនធានាលើពិការភាពណាដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលទាំងស្រុង ឬដោយផ្នែក ដោយហេតុការណ៍ណាមួយដូចខាងក្រោមឡើយ៖

(i) ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

(ii) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្លាវសណ្តាប់ធ្នាប់សាធារណៈ ឬ

(iii) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(iv) ពិការភាព ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ

(v) ការប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ ប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(vi) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**3. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ**

រាល់របួសស្នាម ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល របួសទាំងស្រុង ឬផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះ នឹងមិនត្រូវចាត់ចូលជារបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ៖

(i) ហិង្សាលើរូបរាងកាយ ឬឃាតកម្ម ឬ

(ii) កូដកម្ម កុបកម្ម ចលាចលសង្គម ការបះបោរ ឬសកម្មភាពភេរវជន ឬ

(iii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(iv) ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

(v) សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ

(vi) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ

(vii) ការចូលរួមប្រតិបត្តិចុះចាប់ខ្លួនក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ ឬ

(viii) ការរំលោភបំពាន ឬប៉ុនប៉ងរំលោភបំពានច្បាប់ ឬបដិសេធនឹងការចាប់ខ្លួន ឬ

(ix) ការចូលរួមក្នុងអំពើហិង្សា ឬការវាយតប់គ្នានៅក្នុងកន្លែងសាធារណៈ ឬ

(x) ការប្រណាំងសេះ ឬយានយន្ត ឬ

(xi) ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារសមាជិកអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ

(xii) រោគក្លន ការបង្ករោគដោយផ្សិត ឬបាក់តេរី (លើកលែងតែការកើតខ្ទុះដែលកើតចេញពីមុខរបួស ឬដំបៅដែលបង្កដោយគ្រោះថ្នាក់) ឬ

(xiii) ការស្រូប ឬការប្រើប្រាស់ថ្នាំពុល ផ្សែងពុល ឬឧស្ម័នមានជាតិពុល ដោយចេតនា ឬដោយធ្វេសប្រហែស ឬ

(xiv) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(xv) ពិការភាព ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

**4. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺធ្ងន់ធ្ងរ**

អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺធ្ងន់ធ្ងរ មិនធានាលើ៖

(i) ជំងឺ ឬការវះកាត់ណាមួយក្រៅពីការធ្វើរោគវិនិច្ឆ័យនៃ ឬការវះកាត់សម្រាប់អាការៈជំងឺធ្ងន់ធ្ងរដូចបានកំណត់ក្នុងអត្ថប្រយោជន៍នេះ ឬ

(ii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថា ជាដំណាក់កាលចុងក្រោយត្រូវបានបង្ហាញឱ្យឃើញមុន ឬក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង់ ឬចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(iii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ជាដំណាក់កាលដំបូងបានកើតឡើងមុន ឬក្នុងកំឡុងពេល 120 (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(iv) អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬប្រយោលពីស្ថានភាពមុនពេលជានារ៉ាប់រងដូចបានកំណត់ ដែលកើតមានមុនកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្តើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(v) តាមយោបល់របស់ក្រុមហ៊ុន អាការៈជំងឺធ្ងន់ធ្ងរកើតមានដោយផ្ទាល់ ឬដោយប្រយោលដោយសារមានផ្ទុកមេរោគអេដស៍ ឬដោយមានការឆ្លងមេរោគអេដស៍។ ក្រុមហ៊ុនសូមរក្សាសិទ្ធិដើម្បីតម្រូវឱ្យសមាជិកអ្នកត្រូវបានជានារ៉ាប់រងទៅពិនិត្យឈាមរកមេរោគអេដស៍ ដែលជាលក្ខខណ្ឌដំបូងបង្អស់ក្នុងការទទួលយកការទាមទារសំណងណាមួយ។ ករណីលើកលែង គឺនៅពេលដែលការឆ្លងមេរោគអេដស៍ កើតឡើងដោយសារការបញ្ចូលឈាម ដូចបានកំណត់ក្នុងអត្ថប្រយោជន៍នេះ។ ចំពោះគោលបំណងនៃអត្ថប្រយោជន៍នេះ
   a. និយមន័យនៃជំងឺអេដស៍ (AIDS) ត្រូវតែជានិយមន័យដែលត្រូវបានប្រើដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ 1987 ឬការកែប្រែណាមួយក្រោយមកទៀត ទៅលើនិយមន័យនោះដោយអង្គការសុខភាពពិភពលោក។
   b. ការឆ្លងមេរោគនេះ ត្រូវចាត់ទុកថាបានកើតឡើងនៅពេលដែលការពិនិត្យឈាម ឬការពិនិត្យផ្សេងៗដែលពាក់ព័ន្ធ ហើយដែលតាមយោបល់របស់ក្រុមហ៊ុន បង្ហាញថាមានផ្ទុកមេរោគអេដស៍ ឬអង់ទីករប្រឆាំងមេរោគនេះ។

(vi) អាការៈជំងឺធ្ងន់ធ្ងរមានកម្រិតដូចគ្នា ឬទាបជាងអាការៈជំងឺធ្ងន់ធ្ងរដែលបានទាមទារសំណងពីមុន ឬ

(vii) រាល់ការធ្វើរោគវិនិច្ឆ័យលើអាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលបណ្តាលមកពីជំងឺ ឬការឆ្លងមេរោគពីកំណើត ទោះដោយផ្ទាល់ ឬដោយប្រយោល ដែលត្រូវបានពិនិត្យឃើញ ឬធ្វើរោគវិនិច្ឆ័យមុនពេលសមាជិកអ្នកត្រូវបានជានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ ឬ

(viii) រាល់អាការៈជំងឺធ្ងន់ធ្ងរដែលបណ្តាលមកពីការធ្វើឱ្យរបួសខ្លួនឯង ឬ

(ix) រាល់អាការៈជំងឺធ្ងន់ធ្ងរ ដែលស្ថិតនៅក្រោមដំណាក់កាលដំបូងកើតឡើងដោយផ្ទាល់ពីការពិសារគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសហេតុ ឬ

(x) អាការៈជំងឺធ្ងន់ធ្ងរណាមួយដែលបណ្តាលមកពីស្ថានភាពផ្លូវកាយ ឬផ្លូវចិត្តដែលបានកើតមានមុនកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំធានារ៉ាប់រង ឬរបាយការណ៍សុខភាព ឬ

(xi) ការបរិច្ចាគផ្នែកណាមួយនៃរូបរាងកាយរបស់អ្នកដែលត្រូវបានជានារ៉ាប់រង។

**5. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ**

- **ករណីមិនធានាសម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ឬចំណាយលើការវះកាត់**

អត្ថប្រយោជន៍នេះ មិនធានាចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ឬចំណាយលើការវះកាត់ណាមួយដែលបង្កឡើងដោយផ្ទាល់ ឬ ដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយហេតុការណ៍ណាមួយខាងក្រោមឡើយ៖

(i) ចំណាយដែលបណ្តាលមកពីស្ថានភាពមុនពេលជានារ៉ាប់រង ឬ

(ii) ចំណាយដែលបណ្តាលមកពីការព្យាបាលមិនឱ្យមានកូន ការបង្កកំណើតសិប្បនិម្មិត ការស៊ើបអង្កេត ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺអារ រួមទាំងវិធានការពន្យារកំណើត ការធ្វើតេស្ត ឬការប្រឹក្សាយោបល់អំពីហ្សែន ការព្យាបាលដែលកើតឡើងដោយ ឬលទ្ធផលពីការពរពោះ ការសម្រាលកូន ឬការរំលូតកូន ឬ

(iii) ចំណាយណាដែលកើតឡើងសម្រាប់ជំនួយកែតម្រូវកែវភ្នែក ជំនួយការស្តាប់ និងការព្យាបាលនៃកំហុសឆ្លុំឆ្លងលើកលែងតែមានការចាំបាច់ពីវេជ្ជបណ្ឌិតជំងឺទូទៅ ឬ

(iv) ចំណាយណាមួយដែលកើតឡើងសម្រាប់ការព្យាបាលពីការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀន ឬផលវិបាកណាមួយផ្សេងទៀតដែលកើតឡើងពីគ្រឿងស្រវឹង ឬគ្រឿងញៀន ការទទួលទានឱសថដែលមិនមានវេជ្ជបញ្ជា ការប្រើឱសថលើសកម្រិតដោយចៃដន្យ ឬដោយចេតនា ឬ

(v) ចំណាយណាមួយដែលកើតឡើងពីគ្រប់ទម្រង់នៃការថែទាំទន្តសាស្ត្រ ឬការវះកាត់ណាមួយលើកលែងតែវេជ្ជបណ្ឌិតជំងឺទូទៅតម្រូវឱ្យធ្វើ និងបានបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ (មិនរាប់បញ្ចូលការចំណាយទាក់ទងនឹងការដាំបង្គោលធ្មេញឡើយ) ឬ

(vi) ការចំណាយណាមួយកើតឡើងសម្រាប់ការវះកាត់កែសម្ផស្ស ឬការវះកាត់ដែលជ្រើសរើសបាន លើកលែងតែវេជ្ជបណ្ឌិតជំងឺទូទៅតម្រូវឱ្យធ្វើ ឬ

(vii) ចំណាយណាមួយដែលកើតឡើងសម្រាប់ការត្រួតពិនិត្យសុខភាពប្រចាំឆ្នាំ ឬថែទាំនៅមជ្ឈមណ្ឌល ការថែទាំផ្សេងៗ ឬ

(viii) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការព្យាបាល ឬការវះកាត់សម្រាប់ សាច់ដុះក្នុងបំពង់ក ឬសាច់ដុះក្នុងច្រមុះ រោគក្លូន ជំងឺរលាកក្រពេញប្រូស្តាត ជំងឺ hydrocele ការរលាកភ្នាសរន្ធឆ្អឹង ការកាត់ស្បែក ឬជំងឺនៃប្រព័ន្ធបន្តពូជរបស់ស្ត្រី ឬ

(ix) ចំណាយណាមួយដែលទាក់ទងនឹងវីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(x) ចំណាយណាមួយដែលកើតឡើងសម្រាប់សេវាវេជ្ជសាស្ត្រ ឬការព្យាបាលក្រៅពីវេជ្ជសាស្ត្ររបស់លោកខាងលិច រួមមានការចាក់ម្ជុលវិទ្យាសាស្ត្រ ការព្យាបាល acupressure ការព្យាបាលឆ្អឹង ការព្យាបាលដោយប្រើថ្នាំផ្សំពីរុក្ខជាតិ ការសណ្តំ ការព្យាបាលដោយការម៉ាស្សា ការព្យាបាលដោយប្រើក្លិនក្រអូប និងទម្រង់ផ្សេងទៀតនៃការព្យាបាល ការពិសោធន៍ ការស៊ើបអង្កេត ឬសេវាកម្មដែលមិនមានការបញ្ជាក់ច្បាស់ លើកលែងតែមានការយល់ព្រមពីក្រុមហ៊ុន ឬ

(xi) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការឃុំឃាំងនៅក្នុងមន្ទីរពេទ្យណាមួយ ដែលជាកន្លែងសម្រាក ឬមជ្ឈមណ្ឌលថែទាំអ្នកជំងឺ ឬគ្រឹះស្ថានសម្រាប់ការស្តារនីតិសម្បទា ឬគ្រឹះស្ថានស្រដៀងគ្នា ឬកន្លែងដែលពាក់ព័ន្ធនឹងការថែទាំពីគ្រឿងស្រវឹង ឬគ្រឿងញៀន ឬ

(xii) ចំណាយណាមួយកើតឡើងសម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យ ដែលមិនសមហេតុផល ឬ

(xiii) ចំណាយណាមួយសម្រាប់សេវាកម្មលើការអប់រំផ្សេងៗ ដូចជាការព្យាបាលលើការនិយាយស្តី ការធ្វើអប់រំផ្នែកជំងឺទឹកនោមផ្អែម និងសេវាអាហារូបត្ថម្ភ ឬសេវាកម្មគាំទ្រជាក្រុម ឬ

(xiv) ចំណាយណាមួយដែលបានកើតឡើងសម្រាប់បទល្មើសព្រហ្មទណ្ឌរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងសមាជិកអ្នកត្រូវបានជានារ៉ាប់រង ឬអ្នកទទួលផល លើការរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ឬប្រសិនបើបទល្មើសព្រហ្មទណ្ឌ កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាដោយការរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនោះ ឬការគេចពីដីកាចាប់ខ្លួន ឬ

(xv) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការស៊ើបអង្កេត ការព្យាបាល ឬការវះកាត់ណាមួយសម្រាប់ជំងឺពីកំណើត ដែលបានផ្តល់ជាសញ្ញា ឬរោគសញ្ញា ឬត្រូវបានធ្វើរោគវិនិច្ឆ័យមុនពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ ឬ

(xvi) ចំណាយណាមួយដែលកើតឡើងពីសេវាសុខភាព ដែលមិនមានភាពចាំបាច់ក្នុងការព្យាបាល តាមការយល់ឃើញរបស់វេជ្ជបណ្ឌិតជំងឺទូទៅ ឬ

(xvii) ចំណាយណាមួយដែលកើតឡើងចំពោះសេវាកម្ម និងការផ្គត់ផ្គង់ សម្រាប់ការបញ្ឈប់ការជក់បារី និងការព្យាបាលនៃការញៀនជាតិនីកូទីន ឬ

(xviii) ចំណាយណាមួយដែលបានកើតឡើងសម្រាប់សេវាកម្ម ដែលផ្តល់ជូនដោយវេជ្ជបណ្ឌិតជំងឺទូទៅដែលមានទីលំនៅស្របច្បាប់ដូចគ្នានឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬដែលជាសមាជិកក្រុមគ្រួសាររបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង រួមមាន ប្តីប្រពន្ធ បងប្អូនប្រុសស្រី ឪពុកម្តាយ ឬកូន ឬសេវាកម្មដែលផ្តល់ជូនដោយភ្នាក់ងាររបស់ក្រុមហ៊ុន ឬ

(xix) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការថែទាំតាមគ្លីនិក ការថែទាំប្រភេទណាមួយ ដូចជាមជ្ឈមណ្ឌលថែទាំក្មេង កន្លែងថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ ការថែទាំដោយគិលានុប្បដ្ឋាយិកាឯកជន ការថែទាំតាមផ្ទះ លុះត្រាតែមានការយល់ព្រមជាមុនពីវេជ្ជបណ្ឌិតជំងឺទូទៅនៃបណ្តាញរបស់ក្រុមហ៊ុន ឬ

(xx) ចំណាយណាមួយដែលបានកើតឡើងសម្រាប់សេវាកម្ម និងការផ្គត់ផ្គង់ដែលបានផ្តល់ដោយអ្នករកស៊ីរៀបចំសព ឬអ្នករកស៊ីរៀបចំបុណ្យសព រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ថ្លៃក្តារមឈូស ការរក្សាទុកសាកសព និង/ឬការបូជាសព ឬ

(xxi) ចំណាយណាមួយដែលបង្កឡើងពីមូលហេតុផ្សេងៗ ក្រៅពីការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមិនបានជ្រើសរើសជម្រើសពេញលេញ នៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ឬ

(xxii) ចំណាយណាមួយដែលដូចនឹងករណីមិនធានាណាមួយនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

- **ករណីមិនធានាសម្រាប់សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស**

ការព្យាបាល លក្ខខណ្ឌ ឬសកម្មភាព និងចំណាយផ្សេងៗ ដែលពាក់ព័ន្ធ និងបណ្តាលពីចំណុចទាំងនេះ នឹងមិនត្រូវបានធានានោះទេ៖

(i) ចំណាយណាមួយដែលកើតពីស្ថានភាពមុនពេលធានារ៉ាប់រង ឬ

(ii) ករណីធ្វើការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ សម្រាប់លក្ខខណ្ឌសុខភាពតែមួយរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេលមួយឆ្នាំនៃរយៈពេលធានារបស់បណ្ណសន្យារ៉ាប់រង ឬ

(iii) ចំណាយណាមួយដែលមិនត្រូវបានធានាដោយអត្ថប្រយោជន៍នេះ ហើយមិនត្រូវបានអនុម័តដោយអ្នកផ្តល់សេវាមុនជាលាយលក្ខណ៍អក្សរ ឬមិនបានរៀបចំដោយអ្នកផ្តល់សេវា។ ករណីមិនធានានេះ នឹងមិនត្រូវអនុវត្តលើការជម្លៀសទៅកាន់មន្ទីរពេទ្យសង្គ្រោះបន្ទាន់ពីតំបន់ដាច់ស្រយាល នៅពេលដែលមិនអាចទាក់ទងអ្នកផ្តល់សេវាបានជាមុន ហើយការយឺតយ៉ាវអាចបង្កឱ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬរងគ្រោះថ្នាក់ ឬ

(iv) ករណីណាដែលកើតឡើងនៅពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឋិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

(v) ចំណាយណាមួយដែលកើតមានសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលធ្វើដំណើរទៅក្រៅព្រះរាជាណាចក្រកម្ពុជាមិនស្របតាមដំបូន្មានរបស់វេជ្ជបណ្ឌិតជំនាញឯកទេស ឬក្នុងគោលបំណងទទួលការព្យាបាល

វេជ្ជសាស្ត្រ ឬសម្រាកដើម្បីជាសះស្បើយក្រោយពីបានទទួលគ្រោះថ្នាក់ ជំងឺ ឬស្ថានភាពមុនពេលជានារ៉ាប់រង ឬ

(vi) ការចំណាយណាមួយសម្រាប់ការជម្លៀសទៅមន្ទីពេទ្រសង្គ្រោះបន្ទាន់ ប្រសិនបើសមាជិកអ្នកត្រូវបានជានារ៉ាប់រងមិនមានលក្ខខណ្ឌវេជ្ជសាស្ត្រធ្ងន់ធ្ងរ និង/ឬវេជ្ជបណ្ឌិតជំនាញឯកទេសរបស់អ្នកផ្តល់សេវាគិតថាសមាជិកអ្នកត្រូវបានជានារ៉ាប់រងអាចទទួលបានការព្យាបាលក្នុងប្រទេសកើតហេតុ ឬអាចរងចាំទទួលការព្យាបាលនៅពេលត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ ឬ

(vii) ចំណាយណាមួយសម្រាប់ការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ដែលវេជ្ជបណ្ឌិតជំនាញឯកទេសរបស់អ្នកផ្តល់សេវាគិតថាសមាជិកអ្នកត្រូវបានជានារ៉ាប់រងអាចធ្វើដំណើរជាលក្ខណៈអ្នកធ្វើដំណើរធម្មតា ដោយមិនត្រូវការសេវាវេជ្ជសាស្ត្រភ្ជាប់ជាមួយ ឬ

(viii) ការព្យាបាល ឬចំណាយណាមួយពាក់ព័ន្ធនឹងការសម្រាលកូន ការរលូតកូន ឬការមានផ្ទៃពោះ។ ការលើកលែងនេះនឹងមិនអនុវត្តលើការមានផ្ទៃពោះខុសប្រក្រតី ឬផលវិបាកស្ថានភាពផ្ទៃពោះធ្ងន់ធ្ងរដែលបង្កគ្រោះថ្នាក់ដល់ម្តាយ និង/ឬកូនដែលមិនទាន់កើតក្នុងរយៈពេល 24 (ម្ភៃបួន) សប្តាហ៍ដំបូងនៃការមានផ្ទៃពោះ ឬ

(ix) ចំណាយណាមួយដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬរបួសដែលកើតឡើងខណៈដែលសមាជិកអ្នកត្រូវបានជានារ៉ាប់រងបានចូលរួមសកម្មភាពដូចជា ចូលមើលជ្រលងភ្នំ ឡើងភ្នំ ឡើងលើភ្នំតាមជញ្ជាំងថ្មភ្នំ ដែលទាមទារឱ្យប្រើគន្លងផ្លូវច្បាស់លាស់ ឬខ្សែពួរ មើលជ្រលងភ្នំ ហោះលោតពីទីអាកាសខ្ពស់ លោតឆាត់យោង លោតពីទីខ្ពស់ដោយប្រើខ្សែពួរ ជិះបាឡុង ជិះឧបករណ៍សំកាំងលើអាកាស ការជ្រមុជជ្រៅក្នុងសមុទ្រដោយប្រើមួកការពារ និងភ្ជាប់ទុយោដកដង្ហើម ការហ្វឹកហាត់ក្បាច់គុណ ការប្រកួតប្រជែង ប្រណាំងផ្សេងដែលក្រៅពីការប្រណាំងដោយប្រើជើង ឬសកម្មភាពកីឡាផ្សេងដែលជាលក្ខខណៈអាជីព ឬមានការឧបត្ថម្ភ ឬ

(x) ចំណាយណាមួយដែលកើតឡើងសម្រាប់ជំងឺផ្នែកសតិអារម្មណ៍ ផ្លូវចិត្ត និងផ្នែកប្រសាទ ឬ

(xi) ចំណាយណាមួយដែលកើតឡើងដោយលទ្ធផលនៃការបង្ករបួសខ្លួនឯង អត្តឃាត ការប្រើប្រាស់ថ្នាំញៀន ការប្រើប្រាស់គ្រឿងស្រវឹង ឬជំងឺកាមរោគ ឬ

(xii) ចំណាយណាមួយដែលកើតឡើងដោយជំងឺអេដស៍ ឬលក្ខខណ្ឌដែលពាក់ព័ន្ធនឹងជំងឺនេះ ឬ

(xiii) ចំណាយណាមួយដែលទាក់ទងនឹងសមាជិកអ្នកត្រូវបានជានារ៉ាប់រងធ្វើការធ្វើដំណើរផ្លូវអាកាស តាមទម្រង់ផ្សេងៗ លើកលែងតែជាអ្នកធ្វើដំណើរតាមអាកាសដែលមានជើងហោះហើរត្រឹមត្រូវ ឬតាមយន្តហោះដែលធ្វើដំណើរតាមផ្លូវអាកាសមានចុះបញ្ជីការត្រឹមត្រូវ ឬ

(xiv) ចំណាយណាមួយដែលសមាជិកអ្នកត្រូវបានជានារ៉ាប់រងពាក់ព័ន្ធនឹងការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬ

(xv) ការចំណាយណាមួយដែលពាក់ព័ន្ធនឹងការព្យាបាលដែលធ្វើដោយ ឬបញ្ជាដោយវេជ្ជបណ្ឌិតជំងឺទូទៅដែលមិនបានចុះបញ្ជីការទៅតាមបទដ្ឋានការអនុវត្តវេជ្ជសាស្ត្រ ក្នុងប្រទេសដែលធ្វើការព្យាបាល ឬ

(xvi) ចំណាយណាមួយដែលកើតឡើងដោយសារតែសមាជិកអ្នកត្រូវបានជានារ៉ាប់រង បានចូលរួមបំពេញសេវាកងទ័ព ឬនគរបាលនៃប្រទេសណាមួយ ការចូលរួមសង្គ្រាមយ៉ាងសកម្ម (ប្រកាស ឬមិនប្រកាសក្តី) ការឈ្លានពាន សកម្មភាពសត្រូវនឹងជនបរទេស ភាពជាសត្រូវ សង្គ្រាមស៊ីវិល ការបះបោល កុបកម្ម បដិវត្តន៍ ឬចលាចល ឬ

(xvii) ចំណាយណាមួយដែលកើតពីប្រតិកម្ម ឬចំហាយសាយភាពជាតិវិទ្យុសកម្ម ឬ

(xviii) ចំណាយណាមួយដែលកើតឡើងសម្រាប់ ឬមកពីលទ្ធផលនៃសកម្មភាពដែលតម្រូវលើនាវា ឬវេទិការោងចក្រប្រេង ឬនៅទីតាំងប្រាំងស្រដៀងគ្នា ឬ

(xix) ចំណាយណាមួយដែលសមាជិកអ្នកត្រូវបានជានារ៉ាប់រងមានអាយុច្រើនជាង 70 (ចិតសិប) ឆ្នាំ ឬ

(xx) ចំណាយណាមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬបញ្ចេញ ឬការគម្រាមកំហែងពីអាវុធនុយក្លេអ៊ែរ ឬសារធាតុគីមី ឬជីវ ដែលរួមមានតែមិនកម្រិតត្រឹមចំណាយដែលបង្កដោយ ឬបង្កឱ្យមានដោយសកម្មភាពភេរវកម្ម ឬសង្គ្រាម ដោយមិនគិតពីហេតុបង្កណាមួយ ឬ

(xxi) ចំណាយណាមួយដែលបង្កឡើងពីមូលហេតុផ្សេងៗ ក្រៅពីការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមិនបានជ្រើសរើសជម្រើសពេញលេញ នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។

**6. ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ**

(i) ក្រុមហ៊ុនអាចបញ្ចប់បណ្ណសន្យារ៉ាប់រងនេះនៅពេលណាមួយក៏បាន (ដោយបញ្ចប់សុពលភាពគិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬផ្សេងពីនេះ) តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពណាមួយដែលពាក់ព័ន្ធនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ តាមការយល់ឃើញរបស់ក្រុមហ៊ុន ត្រូវបានរកឃើញថាបានបង្ក ឬអាចនឹងបង្កហានិភ័យផ្នែកទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងមកដល់ក្រុមហ៊ុនតាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬតាមការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្រុមហ៊ុននឹងមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយម្ចាស់បណ្ណសន្យារ៉ាប់រងពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះនោះទេ ដោយរួមបញ្ចូលទាំង និងមិនកំណត់ត្រឹមតែការផ្តល់ ឬទទួលទូទាត់ទឹកប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។

(ii) ដោយមិនមានការប៉ះពាល់ដល់សុពលភាពកថាខណ្ឌ (i) ខាងលើនៃប្រការនេះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថា មិនត្រូវផ្តល់ការធានាណាមួយឡើយ ហើយក្រុមហ៊ុនក៏មិនទទួលខុសត្រូវក្នុងការទូទាត់សំណង ឬផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្នុងទំហំដែលការផ្តល់ការការពារ ការទូទាត់សំណង ឬការផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗទាំងនោះ អាចនាំឱ្យក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនានាពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។

(iii) ជាកាតព្វកិច្ចដែលត្រូវអនុវត្តបន្តជាប្រចាំ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រុមហ៊ុនប្រសិនបើមានករណីផ្លាស់ប្តូរអត្តសញ្ញាណ ស្ថានភាព (មុខដំណែង) លក្ខន្តិកៈ (ក្នុងករណីជាក្រុមហ៊ុន) ក្រុមហ៊ុនពាក់ព័ន្ធនឹងម្ចាស់បណ្ណសន្យារ៉ាប់រងក្រោមខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងនេះ ព័ត៌មានលម្អិត និងឯកសារអត្តសញ្ញាណកម្មរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពនានាដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះ។

## VII. ទីតាំងភូមិសាស្ត្រនៃការធានា

បណ្ណសន្យារ៉ាប់រងនេះ ផ្តល់ការការពារដល់អ្នកត្រូវបានធានារ៉ាប់រងទូទាំងពិភពលោក។

## VIII. លក្ខណៈសម្បត្តិរបស់អ្នកទទួលផល

1. សមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ត្រូវកំណត់បុគ្គលជាអ្នកទទួលផលជាលាយលក្ខណ៍អក្សរ ដែលនឹងទទួលបានអត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ ក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយការកំណត់ នេះត្រូវរក្សាទុកជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង។
2. ក្នុងករណីនៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយពុំមានអ្នកទទួលផលណាម្នាក់ត្រូវបានតែងតាំង ឬអ្នកទទួលផលនោះស្លាប់ ទឹកប្រាក់ទាំងនោះអាចនឹងត្រូវបង់ជូនសាច់ញាតិរបស់អ្នកទទួលផលនោះ។ ករណីនេះ នឹងត្រូវអនុវត្តតាមច្បាប់ជាធរមាននាពេលនោះ។
3. ក្នុងកំឡុងពេលនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង គាត់មានសិទ្ធិផ្លាស់ប្តូរអ្នកទទួលផលដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង។ ការផ្លាស់ប្តូរបែបនេះ នឹងចាប់ផ្តើមមានសុពលភាពនៅពេលម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួលសេចក្តីជូនដំណឹង។
4. ក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព អ្នកទាមទារសំណងត្រូវផ្តល់នូវឈ្មោះអ្នកទទួលផលដែលនឹងត្រូវទទួលបានអត្ថប្រយោជន៍មកឱ្យក្រុមហ៊ុន។ ការទូទាត់អត្ថប្រយោជន៍ដល់អ្នកទទួលផលបែបនេះ នឹងធ្វើឱ្យក្រុមហ៊ុនរួចផុតពីការទទួលខុសត្រូវទាំងអស់សម្រាប់ការទាមទារសំណងនៃអត្ថប្រយោជន៍នោះ។

## IX. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើអ្នកមានបំណងចង់ធ្វើការកែប្រែណាមួយ ឬបោះបង់ ខ និងលក្ខខណ្ឌណាមួយ ដែលមានក្នុងបណ្ណសន្យារ៉ាប់រងនេះ ការកែប្រែ ឬការបោះបង់នោះ ត្រូវធ្វើឡើងដោយការយល់ព្រមរបស់គូភាគីតាមរយៈបដិលេខ។ រាល់បដិលេខទាំងអស់ដែលធ្វើចំពោះបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវចងភ្ជាប់ជាមួយគ្រប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង មុន ឬនៅកាលបរិច្ឆេទនៃសុពលភាពរបស់បដិលេខ។ បដិលេខនេះត្រូវចុះហត្ថលេខាដោយបុគ្គលដែលក្រុមហ៊ុនបានផ្តល់សិទ្ធិ។

## X. ការបន្តកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះត្រូវបានធ្វើឡើងដោយមានរយៈពេលសុពលភាពមួយឆ្នាំ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបន្តសុពលភាពជាថ្មីដោយស្វ័យប្រវត្តិនៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ តាមការកំណត់បុព្វលាភធានារ៉ាប់រងដោយក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនចេញបង្កាន់ដៃជាផ្លូវការទទួលបានការបង់បុព្វលាភធានារ៉ាប់រងពីអ្នក នៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រង។ ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការកែប្រែ ឬកែតម្រូវអត្រាបុព្វលាភធានារ៉ាប់រង ខ និងលក្ខខណ្ឌ នៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រងណាមួយ ដោយជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ យ៉ាងហោចណាស់ 30 (សាមសិប) ថ្ងៃ មុនដល់ខួបនៃបណ្ណសន្យារ៉ាប់រង។

## XI. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

**1. សិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រង**

បណ្ណសន្យារ៉ាប់រងនេះ អាចត្រូវបានបញ្ចប់សុពលភាពនៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងណាមួយដោយអ្នក តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបញ្ចប់មកកាន់ក្រុមហ៊ុន មិនតិចជាង 31 (សាមសិបមួយ) ថ្ងៃ មុនកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើអ្នកស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង នៅកាលបរិច្ឆេទផ្សេងក្រៅពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង នោះនឹងមិនមានការបង្វិលសង

បុព្វលាភជានារ៉ាប់រង (ប្រសិនបើមាន) ត្រូវអនុវត្តឡើយ។ ការបញ្ចប់បណ្ណសន្យារ៉ាប់រងត្រូវធ្វើឡើង ដោយមិនត្រូវប៉ះពាល់ដល់ ការទាមទារសំណងណាមួយ ដែលកើតមានមុនកាលបរិច្ឆេទនៃការបញ្ចប់សុពលភាពនេះ។

2. **រយៈពេលពិចារណាចុងក្រោយ**

អ្នកមានសិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុន ហើយផ្ញើបណ្ណសន្យារ៉ាប់រងនេះត្រឡប់មកឱ្យក្រុមហ៊ុនវិញ។ ក្រុមហ៊ុន នឹងបង់សងជូនអ្នកវិញនូវបុព្វលាភជានារ៉ាប់រង ដែលអ្នកបានបង់ហើយ បន្ទាប់ពីធ្វើការទូទាត់ជាមួយនឹងចំណាយនានាពាក់ព័ន្ធនឹងការពិនិត្យសុខភាព។ ការជូនដំណឹងនេះ ត្រូវធ្វើឡើងដោយអ្នក នៅក្នុងទម្រង់ដែលក្រុមហ៊ុនបានកំណត់ជូន ហើយត្រូវទទួលដោយផ្ទាល់ដោយក្រុមហ៊ុន ក្នុងកំឡុងពេល 21 (ម្ភៃមួយ) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។

## XII. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

1. **សិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង**

(i) ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រងនេះ នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភជានារ៉ាប់រងណាមួយ នៅពេលដែលចំនួនសរុបនៃសមាជិកអ្នកត្រូវបានជានារ៉ាប់រង តិចជាងចំនួនអប្បបរមានៃសមាជិកអ្នកត្រូវបានជានារ៉ាប់រង ដែលមានកំណត់នៅលើវិញ្ញាបនបត្រជានារ៉ាប់រង។

(ii) ក្រុមហ៊ុន អាចលុបចោលបណ្ណសន្យារ៉ាប់រងនេះ នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភជានារ៉ាប់រងណាមួយ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការលុបចោលទៅកាន់ម្ចាស់បណ្ណសន្យារ៉ាប់រង មិនតិចជាង 31 (សាមសិបមួយ) ថ្ងៃ មុនកាលបរិច្ឆេទនៃការទូទាត់បុព្វលាភជានារ៉ាប់រង។ ការលុបចោលបណ្ណសន្យារ៉ាប់រងត្រូវធ្វើឡើង ដោយមិនត្រូវប៉ះពាល់ដល់ការទាមទារសំណងណាមួយ ដែលកើតមានមុនកាលបរិច្ឆេទនៃការលុបចោលបណ្ណសន្យារ៉ាប់រងនេះ។

(iii) បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវលុបចោលដោយក្រុមហ៊ុន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នក ដោយសារតែអ្នកបានរំលោភបំពានលើវិធាននៃការចូលរួមជាសមាជិក ឬខ្លឹមសារនៃបណ្ណសន្យារ៉ាប់រង។

(iv) បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវលុបចោលដោយក្រុមហ៊ុន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នក ប្រសិនបើ អ្នកបានផ្តល់ព័ត៌មានមិនពិតដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្ត ខ និងលក្ខខណ្ឌនៃអត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ។

(v) ក្នុងកាលៈទេសៈដូចពិពណ៌នានៅក្នុងករណីទាំងពីរខាងលើនេះ (ចំណុច 3 និង ចំណុច 4 ខាងលើនេះ) ក្រុមហ៊ុនមានសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រងនេះ ដោយការលុបចោលនេះ ត្រូវមានសុពលភាពប្រតិសកម្ម គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ហើយក្រុមហ៊ុនមានសិទ្ធិក្នុងការទាមទារសំណងពីអ្នកសម្រាប់សំណងជានារ៉ាប់រងទាំងអស់ដែលបានទូទាត់រួចក្រោមបណ្ណសន្យារ៉ាប់រងនេះ រួមទាំងថ្លៃរដ្ឋបាលផងដែរ។

(vi) បណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបានលុបចោលដោយក្រុមហ៊ុន ដោយសារតែការក្លែងបន្លំ ឬការផ្តល់ព័ត៌មានមិនពិតដោយអ្នក ឬព្រោះតែសមាជិកអ្នកត្រូវបានជានារ៉ាប់រងមានចេតនាផ្តល់ព័ត៌មានមិនពិតដល់ក្រុមហ៊ុន។ ក្រុមហ៊ុន មានសិទ្ធិលុបចោលការជានារ៉ាប់រងនេះគិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។

(vii) ការទូទាត់ ឬការទទួលយកបុព្វលាភធានារ៉ាប់រងណាមួយបន្ទាប់ពីការលុបចោលបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ នឹងមិនបង្កើតជាទំនួលខុសត្រូវរបស់ក្រុមហ៊ុនណាមួយឡើយ ប៉ុន្តែក្រុមហ៊ុននឹងបង្វិលបុព្វលាភធានារ៉ាប់រងនេះត្រលប់ជូនវិញដោយពុំមានការប្រាក់។

**2. ករណីមិនអាចជំទាស់បាន**

ទោះបីជាមានករណីណាដែលកើតឡើងខុសពី ខ និងលក្ខខណ្ឌដែលបានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះក៏ដោយ បណ្ណសន្យារ៉ាប់រងនេះ នឹងមិនអាចជំទាស់បានទេ លុះត្រាតែមិនមានការបង់បុព្វលាភធានារ៉ាប់រង ឬធ្វើឡើងដើម្បីក្លែងបន្លំ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងនេះចូលជាធរមានបានរយៈពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង។ ការធានារ៉ាប់រងដើមរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ និងការបន្ថែមធានារ៉ាប់រងនឹងមិនអាចជំទាស់បានទេ លុះត្រាតែមិនមានការបង់បុព្វលាភធានារ៉ាប់រង ឬមានការក្លែងបន្លំ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងនេះចូលជាធរមានបាន រយៈពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង និងកាលបរិច្ឆេទនៃសុពលភាពនៃការបន្ថែមធានារ៉ាប់រងនោះ ជាបន្តបន្ទាប់។

**3. ការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និង/ឬ ភេទ**

(i) ក្នុងករណីមានការផ្តល់ព័ត៌មានមិនពិតអំពីអាយុ និង/ឬ ភេទ បុព្វលាភធានារ៉ាប់រង និង/ឬ អត្ថប្រយោជន៍ដែលត្រូវបង់ នឹងត្រូវកែសម្រួលដោយយោងទៅតាមអាយុ និង/ឬ ភេទពិតប្រាកដរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។

(ii) នៅពេលដែលការផ្តល់ព័ត៌មានមិនពិតអំពីអាយុ ឬអង្គហេតុពាក់ព័ន្ធផ្សេងទៀតបានធ្វើឱ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងអាចទទួលបានការធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ នៅខណៈពេលដែលគាត់មិនមានសិទ្ធិទទួលបានការធានារ៉ាប់រងណាមួយ ឬក្នុងករណីដែលការផ្តល់ព័ត៌មានមិនពិតបែបនេះធ្វើឱ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងនៅតែអាចបន្តទទួលបានការធានារ៉ាប់រង នៅខណៈពេលដែលគាត់ត្រូវអស់សិទ្ធិស្របតាមលក្ខខណ្ឌ និងកម្រិតនៃបណ្ណសន្យារ៉ាប់រងនេះ ការធានារ៉ាប់រងទាំងស្រុងរបស់គាត់នឹងត្រូវចាត់ទុកជាមោឃៈ ហើយបុព្វលាភធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងរូបនោះនឹងត្រូវបានបង្វិលត្រលប់ឱ្យវិញ លើកលែងតែមានការក្លែងបន្លំដោយអ្នក ឬសមាជិកអ្នកត្រូវបានធានារ៉ាប់រង នោះបុព្វលាភធានារ៉ាប់រងនឹងមិនត្រូវបានបង្វិលត្រលប់ឱ្យវិញឡើយ។

## XIII. ការទាមទារសំណង

**1. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង**

អ្នកដាក់ពាក្យស្នើសុំទាមទារសំណងអាចជា ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផល ម្នាក់ ឬច្រើននាក់ ដែលត្រូវបានកំណត់ដោយម្ចាស់បណ្ណសន្យារ៉ាបរង។ អ្នកទាមទារសំណងត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។

**2. និតិវិធីនៃការផ្តល់ព័ត៌មាន**

(i) សេចក្តីជូនដំណឹងអំពីការទាមទារសំណង ត្រូវប្រគល់ជូនក្រុមហ៊ុនក្នុងរយៈពេល 90 (កៅសិប) ថ្ងៃបន្ទាប់ពីថ្ងៃដែលព្រឹត្តិការណ៍ណាមួយបានកើតឡើង ដែលបង្កឱ្យមានការទាមទារសំណងក្រោមបណ្ណសន្យារ៉ាប់រងនេះ។ ប្រសិនបើ អ្នកទាមទារសំណងខកខានក្នុងការជូនដំណឹង 90 (កៅសិប) ថ្ងៃ ក្រុមហ៊ុននឹងមិនបដិសេធការ

ទាមទារណាមួយឡើយ ប្រសិនបើ ក្រុមហ៊ុនត្រូវបានបង្ហាញថាអ្នកទាមទារសំណងពុំមានលទ្ធភាពក្នុងការផ្តល់សេចក្តីជូនដំណឹង តាមដែលអាចធ្វើបាន ហើយអ្នកទាមទារសំណងបានព្យាយាមធ្វើការជូនដំណឹងនេះលឿនបំផុតតាមដែលអាចធ្វើបាន។

(ii) អ្នកអាចជូនដំណឹងអំពីការទាមទារសំណងដោយផ្ទាល់នៅទីស្នាក់ការរបស់ក្រុមហ៊ុន ឬជូនដំណឹងទៅកាន់ការិយាល័យសេវាបម្រើអតិថិជនតាមរយៈលេខទូរស័ព្ទ (855) 86 999 242 ឬទៅទំនាក់ទំនងទៅកាន់ទីប្រឹក្សាផែនការជីវិតរបស់អ្នក ឬអ៊ីមែលទៅកាន់ Kh.claim@aia.com។

**3. ការផ្តល់ឯកសារ ឬភស្តុតាងក្នុងការដោះស្រាយសំណង**

**(i) ភស្តុតាងបញ្ជាក់អំពីមរណភាព**

ខណៈពេលដែលបានទទួលការជូនដំណឹងនេះ ក្រុមហ៊ុននឹងប្រគល់ជូនអ្នកទាមទារសំណង នូវទម្រង់បែបបទទាមទារសំណង ដើម្បីបំពេញ និងដាក់ភស្តុតាងបញ្ជាក់អំពីមរណភាពមកកាន់ក្រុមហ៊ុន។ ប្រសិនបើ ក្រុមហ៊ុនមិនបានប្រគល់ទម្រង់បែបបទទាមទារសំណងជូន ក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងនេះទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថាបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនតាម ខ និងលក្ខខណ្ឌ ដោយអ្នកទាមទារសំណងត្រូវបញ្ជាក់ជាមួយភស្តុតាងជាលាយលក្ខណ៍អក្សរអំពីព្រឹត្តិការណ៍ និងស្ថានភាពដែលបានកើតឡើងដែលជាមូលហេតុនៃមរណភាពនេះ។

**(ii) ភស្តុតាងបញ្ជាក់អំពីពិការភាព**

នៅពេលបានទទួលសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុននឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីពិការភាព។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ឱ្យក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថាបានអនុវត្តតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សររៀបរាប់ពីព្រឹត្តិការណ៍ និងកាលៈទេសៈនៃការពិការភាព។

ភស្តុតាងបញ្ជាក់អំពីពិការភាពត្រូវដាក់ជូនក្រុមហ៊ុន ដែលក្រុមហ៊ុនជាអ្នកមានសិទ្ធិក្នុងការសម្រេចថាពិការភាពនោះ គ្រប់លក្ខខណ្ឌដូចបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ ក្រុមហ៊ុនមានសិទ្ធិស្នើឱ្យមានការពិនិត្យសមាជិកអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ពិនិត្យលើភស្តុតាងបង្ហាញពីមូលហេតុដែលនាំអោយឈានដល់ពិការភាពនោះ ដោយបុគ្គលដែលជ្រើសរើសដោយក្រុមហ៊ុន។

**(iii) ភស្តុតាងបញ្ជាក់អំពីមរណភាព ការរងរបួស និងការរលាកដោយគ្រោះថ្នាក់ចៃដន្យ**

នៅពេលបានទទួលសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុននឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំសម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីមរណភាព ពិការភាព និងការរលាកដោយគ្រោះថ្នាក់ចៃដន្យ។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបានប្រគល់ឱ្យក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថាបានអនុវត្តតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សររៀបរាប់ពីព្រឹត្តិការណ៍ និងកាលៈទេសៈនៃមរណភាព ពិការភាពនិងការរលាកដោយគ្រោះថ្នាក់ចៃដន្យ។

ក្រុមហ៊ុននឹងកំណត់ថា ភស្តុតាងបញ្ជាក់អំពីមរណភាព ពិការភាព និងការរលាកដោយគ្រោះថ្នាក់ចៃដន្យដែល បានដាក់ជូនក្រុមហ៊ុនគ្រប់លក្ខខណ្ឌដូចបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុនមានសិទ្ធិស្នើឱ្យ មានការពិនិត្យសមាជិកអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ពិនិត្យលើភស្តុតាងបង្ហាញពីមូលហេតុដែលនាំអោយ ឈានដល់មរណភាព ពិការភាព និងការរលាកដោយគ្រោះថ្នាក់ចៃដន្យនោះ ដោយបុគ្គលដែលជ្រើសរើស ដោយក្រុមហ៊ុន។

**(iv) ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ**

នៅពេលទទួលបានការជូនដំណឹងនេះ ក្រុមហ៊ុននឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំ សម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ។ ប្រសិនបើទម្រង់ពាក្យស្នើសុំមិនត្រូវបាន ប្រគល់ឱ្យក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃក្រោយពីទទួលបានលិខិតជូនដំណឹងនេះទេ អ្នកទាមទារសំណង ត្រូវបានចាត់ទុកថាបានអនុលោមតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាង ជាលាយលក្ខណ៍អក្សរស្តីពីការកើតមានលក្ខណៈ និងកម្រិតនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានធ្វើការទាមទារ សំណងនោះ។ ភស្តុតាងបញ្ជាក់អំពីអាការៈជំងឺធ្ងន់ធ្ងរ ត្រូវប្រគល់ឱ្យក្រុមហ៊ុនក្នុងកំឡុងពេលរស់រានមានជីវិត របស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង និងក្នុងរយៈពេល 6 (ប្រាំមួយ) ខែបន្ទាប់ពីការធ្វើរោគវិនិច្ឆ័យនៃអាការៈ ជំងឺធ្ងន់ធ្ងរនេះ។

**(v) ភស្តុតាងបញ្ជាក់អំពីការសម្រាកក្នុងមន្ទីរពេទ្យ**

នៅពេលបានទទួលសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុននឹងប្រគល់ជូនអ្នកទាមទារសំណងនូវទម្រង់ពាក្យស្នើសុំ សម្រាប់បំពេញដើម្បីជាភស្តុតាងបញ្ជាក់អំពីការសម្រាកក្នុងមន្ទីរពេទ្យ និង/ឬ ការវះកាត់។ ប្រសិនបើទម្រង់ ពាក្យស្នើសុំមិនត្រូវបានប្រគល់ឱ្យក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃទេ អ្នកទាមទារសំណងត្រូវបានចាត់ទុកថា បានអនុវត្តតាមការតម្រូវនៃ ខ និងលក្ខខណ្ឌនេះ ប្រសិនបើគាត់បានផ្តល់នូវភស្តុតាងជាលាយលក្ខណ៍អក្សរ រៀបរាប់ពីព្រឹត្តិការណ៍ និងកាលៈទេសៈនៃការសម្រាកក្នុងមន្ទីរពេទ្យ និង/ឬ ការវះកាត់។

ក្រុមហ៊ុននឹងកំណត់ថា ភស្តុតាងបញ្ជាក់អំពីការសម្រាកក្នុងមន្ទីរពេទ្យ និង/ឬ ការវះកាត់ដែលបានដាក់ជូន ក្រុមហ៊ុនគ្រប់លក្ខខណ្ឌ ដូចបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុនមានសិទ្ធិស្នើឱ្យមានការពិនិត្យ សមាជិកអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ពិនិត្យលើភស្តុតាងបង្ហាញពីមូលហេតុដែលនាំអោយឈានដល់ការ សម្រាកក្នុងមន្ទីរពេទ្យ និង/ឬ ការវះកាត់នោះ ដោយបុគ្គលដែលជ្រើសរើសដោយក្រុមហ៊ុន។

ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការស្នើសុំឯកសារដែលចាំបាច់បន្ថែម សម្រាប់គោលបំណងនៃដំណើរការការទាមទារ សំណងរបស់អ្នក។

## 4. រយៈពេលអតិបរមានៃការទូទាត់សំណងជូនអតិថិជន

ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការពិចារណាលើសំណុំឯកសារ និងការសម្រេច លើការផ្តល់សំណងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលឯកសារពេញលេញអំពីបណ្តឹងទាមទារសំណង។

5. **របៀបទូទាត់សំណង**

ក្រុមហ៊ុននឹងទូទាត់សំណងតាមរយៈគណនីធនាគាររបស់អ្នកទាមទារសំណង ដែលបានដាក់ជូនមកក្រុមហ៊ុន ដោយយោងតាមឯកសារបញ្ជាក់ពីគណនីធនាគាររបស់អ្នកទាមទារសំណង ។

6. **ករណីកុមារជាអ្នកត្រូវបានធានារ៉ាប់រង**

ដោយមិនយោងតាមទឹកប្រាក់ធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាព មុនមានអាយុគ្រប់ 4 (បួន) ឆ្នាំ ដោយផ្អែកលើថ្ងៃកំណើតចុងក្រោយ នោះប្រាក់សំណងដែលត្រូវ ផ្តល់ជូននឹងត្រូវកំណត់ដូចខាងក្រោមនេះ៖

| អាយុខណៈពេលទទួលមរណភាព ឬពិការភាព (គិតត្រឹមខួបកំណើតចុងក្រោយ) | ភាគរយនៃអត្ថប្រយោជន៍ដែលនឹងផ្តល់ជូន |
|---|---|
| ក្រោម 1 ឆ្នាំ | 20% នៃទឹកប្រាក់ធានារ៉ាប់រង |
| 1 ឆ្នាំ | 40% នៃទឹកប្រាក់ធានារ៉ាប់រង |
| 2 ឆ្នាំ | 60% នៃទឹកប្រាក់ធានារ៉ាប់រង |
| 3 ឆ្នាំ | 80% នៃទឹកប្រាក់ធានារ៉ាប់រង |
| 4 ឆ្នាំ ឬលើសពី 4 ឆ្នាំ | 100% នៃទឹកប្រាក់ធានារ៉ាប់រង |

ការកំណត់ខាងលើ ក៏ត្រូវបានអនុវត្តសម្រាប់ការបង់ប្រាក់នៃអត្ថប្រយោជន៍ណាមួយ ក្រោមអត្ថប្រយោជន៍ការពារគ្រួសារ អត្ថប្រយោជន៍លើការស្តារនីតិសម្បទា អត្ថប្រយោជន៍លើមរណភាព និងការរងរបួសដោយគ្រោះថ្នាក់ចៃដន្យ ហើយដែលជាលទ្ធផលនៃមរណភាព ឬពិការភាពដោយផ្នែក ឬទាំងស្រុងនៃសមាជិកអ្នកត្រូវបានធានារ៉ាប់រង ដោយហេតុផលណាមួយក៏ដោយ។

## XIV. ការរក្សាការព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឱ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឱ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

## XV. ការផ្សះផ្សាវិវាទ

1. **នីតិវិធីដោះស្រាយបណ្តឹងអតិថិជន**

រាល់វិវាទដែលក្រុមហ៊ុនបានទទួល នឹងត្រូវលើកឡើងសម្រាប់ដោះស្រាយ និងវិភាគក្នុងរយៈពេលដែលសមរម្យ ដើម្បីកំណត់ពីមូលហេតុ និងវិធានការដែលនឹងត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមនីតិវិធីស្តង់ដាររបស់ក្រុមហ៊ុន។ អ្នកអាចជូនដំណឹងទៅក្រុមហ៊ុន តាមរយៈអ៊ីមែល Kh.care@aia.com និងលេខទូរស័ព្ទ (855) 86 999 242។

## 2. នីតិវិធីនៃការផ្សះផ្សាវិវាទ

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជា ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សារវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

# XVI. ដែនយុត្តាធិការ

កិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវអនុវត្តក្រោមដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

# XVII. ខ និងលក្ខខណ្ឌផ្សេងៗ

1. បទប្បញ្ញត្តិលើទិន្នន័យដែលតម្រូវ

(i) អ្នកត្រូវផ្តល់ជូនក្រុមហ៊ុននូវព័ត៌មានទាក់ទងនឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រងអនាគត និងការបញ្ចប់ការធានារ៉ាប់រងសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រងបច្ចុប្បន្ន ដែលក្រុមហ៊ុនអាចតម្រូវឱ្យរៀបចំការធានារ៉ាប់រង។ តាមការស្នើសុំរបស់ក្រុមហ៊ុន អ្នកត្រូវផ្តល់ជូនក្រុមហ៊ុននូវរបាយការណ៍ដែលបញ្ជាក់ពីថ្ងៃខែឆ្នាំកំណើតមុខរបរ និងទិន្នន័យដទៃទៀតដែលពាក់ព័ន្ធនឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលត្រូវបានចាត់ទុកថាមានផលប៉ះពាល់ដល់ការផ្តល់ការធានារ៉ាប់រង និងលើការកំណត់អត្រាបុព្វលាភធានារ៉ាប់រងនាពេលអនាគតមិនលើសពីម្តងក្នុងមួយឆ្នាំ។ ទិន្នន័យ និងកំណត់ត្រាបែបនេះ ត្រូវផ្តល់ជូនបានសម្រាប់ការត្រួតពិនិត្យរបស់ក្រុមហ៊ុននៅពេលដែលសមហេតុផលណាមួយ។

(ii) អ្នកត្រូវរក្សាទុកកំណត់ត្រាដែលទាក់ទងនឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ក្រោមបណ្ណសន្យារ៉ាប់រងនេះ ដោយបង្ហាញពីឈ្មោះ ភេទ អាយុ ឬថ្ងៃខែឆ្នាំកំណើត ទឹកប្រាក់ធានារ៉ាប់រង កាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង កាលបរិច្ឆេទការបញ្ចប់បណ្ណសន្យារ៉ាប់រង ការផ្លាស់ប្តូរចំណាត់ថ្នាក់សមាជិក អ្នកទទួលផល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់ ដើម្បីអនុវត្តតាម ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ។

(iii) កំហុសក្នុងការរក្សាទុកកំណត់ត្រា នឹងមិនធ្វើឱ្យការធានារ៉ាប់រងក្លាយជាមោឃៈនោះទេ ប៉ុន្តែនៅពេលកំហុសក្នុងការរក្សាទុកកំណត់ត្រានេះត្រូវបានរកឃើញ ការកែសម្រួលលើបុព្វលាភធានារ៉ាប់រង និងអត្ថប្រយោជន៍នឹងត្រូវធ្វើឡើងតាមភាពចាំបាច់។

(iv) អ្នកត្រូវផ្តល់ជូនក្រុមហ៊ុននូវរាល់ព័ត៌មាន និងភស្តុតាងដែលក្រុមហ៊ុនស្នើសុំយ៉ាងសមហេតុផល អំពីបញ្ហាទាំងឡាយណាដែលទាក់ទងនឹងបណ្ណសន្យារ៉ាប់រងនេះ។ រាល់ឯកសារដែលបានប្រគល់ជូនអ្នកដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រងណាម្នាក់ ដែលមានជាប់ទាក់ទងនឹងការធានារ៉ាប់រង និងកំណត់ត្រាផ្សេងទៀតដែលអាចមានទាក់ទងនឹងការធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបង្ហាញឱ្យក្រុមហ៊ុនធ្វើការត្រួតពិនិត្យ នៅពេលដែលសមហេតុផលណាមួយ។

(v) រាល់ព័ត៌មានផ្ទាល់ខ្លួនដែលក្រុមហ៊ុនបានប្រមូល ឬកាន់កាប់ដែលទាក់ទងនឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ក្រោមបណ្ណសន្យារ៉ាប់រងនេះ អាចនឹងត្រូវបានប្រើប្រាស់ និងបង្ហាញដោយក្រុមហ៊ុនចំពោះបុគ្គល ឬអង្គ

ការដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនសម្រាប់បញ្ហាដែលទាក់ទងនឹងការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។

(vi) វាគឺជាទំនួលខុសត្រូវរបស់អ្នក ក្នុងការធានាថាព័ត៌មានផ្ទាល់ខ្លួនដែលបានផ្តល់ជូនក្រុមហ៊ុនត្រូវមានភាពត្រឹមត្រូវច្បាស់លាស់។ អ្នកត្រូវសងសំណង និងបន្តការសងសំណងទៅកាន់ក្រុមហ៊ុន ចំពោះរាល់ការខាតបង់ ថ្លៃសេវា ការចំណាយ សកម្មភាពនានាដែលក្រុមហ៊ុនបានទទួលរងគ្រោះ ដែលជាលទ្ធផលនៃការធ្វេសប្រហែសរបស់អ្នកក្នុងការអនុវត្តតាមលក្ខខណ្ឌខាងលើ។

2. ការបំពានលើច្បាប់ ការអស់សុពលភាព ឬភាពមិនអាចអនុវត្តបាននៃប្រការណាមួយក្នុងបណ្ណសន្យារ៉ាប់រងនេះ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នឹងមិនត្រូវប៉ះពាល់ដល់ប្រសិទ្ធិភាពនៃច្បាប់ ឬភាពដែលអាចអនុវត្តបាននៃខ និងលក្ខខណ្ឌផ្សេងទៀតក្នុងបណ្ណសន្យារ៉ាប់រងនេះឡើយ។
3. បញ្ជីឯកសារ និង/ឬ គណនីរបស់ក្រុមហ៊ុន គឺជាភស្តុតាងចុងក្រោយអំពីស្ថានភាពគណនី រវាងគូភាគីក្នុងបណ្ណសន្យារ៉ាប់រងនេះ។ ការបញ្ជាក់ណាមួយរបស់បុគ្គលិកក្រុមហ៊ុនពាក់ព័ន្ធនឹងទឹកប្រាក់ ឬការទទួលខុសត្រូវនាពេលបច្ចុប្បន្ន ដែលមិនទាន់បានបង់ ឬនៅសល់ ដែលក្រុមហ៊ុនបានចំណាយសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ត្រូវជាប់ជាកាតព្វកិច្ច និងចាត់ទុកជាភស្តុតាងសំខាន់ និងចុងក្រោយសម្រាប់អ្នកត្រូវបានធានារ៉ាប់រងក្នុងតុលាការគ្រប់ជាន់ថ្នាក់ និងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។
4. ប្រសិនបើ ក្រុមហ៊ុនពន្យារពេល ឬខកខានក្នុងការអនុវត្តសិទ្ធិ/ដំណោះស្រាយតាមផ្លូវច្បាប់ណាមួយក្រោមបណ្ណសន្យារ៉ាប់រងនេះ នឹងមិនត្រូវចាត់ទុកជាការលះបង់សិទ្ធិឡើយ។ ការអនុវត្តសិទ្ធិ/ដំណោះស្រាយផ្លូវច្បាប់តែមួយ/ដោយផ្នែក មិនអាចរារាំងក្រុមហ៊ុន ពីការអនុវត្តសិទ្ធិ/ដំណោះស្រាយតាមផ្លូវច្បាប់ណាផ្សេងបានឡើយ។ សិទ្ធិ/ដំណោះស្រាយតាមផ្លូវច្បាប់ ដែលផ្តល់ឱ្យក្នុងបណ្ណសន្យារ៉ាប់រងនេះ ត្រូវបូកបន្ថែម និងរាប់បញ្ចូលទាំងសិទ្ធិ/ដំណោះស្រាយតាមផ្លូវច្បាប់ផ្សេងទៀត (មិនថាផ្តល់ឱ្យដោយច្បាប់ ឬផ្សេងពីនេះ)។
5. បណ្ណសន្យារ៉ាប់រងនេះ ត្រូវបន្តមានសុពលភាព និងចងភ្ជាប់ជាកាតព្វកិច្ចសម្រាប់រាល់មូលដ្ឋានបំណងទាំងអស់ ទោះមានការផ្លាស់ប្តូរណាមួយដូចជាការរំលាយបញ្ចូលគ្នា ការផ្លាស់ប្តូរឈ្មោះ ការស្ថាបនាឡើងវិញ ឬផ្សេងពីនេះ ដែលអាចនឹងត្រូវបានធ្វើឡើងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។
6. ខ និងលក្ខខណ្ឌដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ បង្កើតបានជា ខ និងលក្ខខណ្ឌទាំងមូលរបស់បណ្ណសន្យារ៉ាប់រងនេះ។ ពុំមានការធានាអះអាង ឬសេចក្តីថ្លែងការណ៍ណាមួយពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រង ដែលមានអត្ថន័យខុសពីនេះបានធ្វើឡើងពីមុនមក ទោះដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ត្រូវបានចាត់ទុកជាផ្នែកនៃបណ្ណសន្យារ៉ាប់រងនេះឡើយ។
7. ក្រុមហ៊ុន រក្សាសិទ្ធិក្នុងការកែប្រែខសន្យានៃបណ្ណសន្យារ៉ាប់រងនេះ តាមវិធីដែលក្រុមហ៊ុន គិតថាមានភាពសមរម្យ ក្នុងករណីមានការផ្លាស់ប្តូរណាមួយក្នុងច្បាប់ ឬក្នុងគោលការណ៍នៃការប្រមូលពន្ធដែលត្រូវអនុវត្តចំពោះក្រុមហ៊ុន ឬចំពោះបណ្ណសន្យារ៉ាប់រងនេះ។
8. ការធានារ៉ាប់រងដែលមាននៅក្នុងបណ្ណសន្យារ៉ាប់រងនេះ និងអត្ថប្រយោជន៍ដែលត្រូវបង់ គឺមិនអាចផ្ទេរសិទ្ធិបានទេ។
9. បណ្ណសន្យារ៉ាប់រងនេះត្រូវរៀបចំជាភាសាខ្មែរ ហើយក្នុងករណីមានការបកប្រែជាភាសាបរទេស នោះឯកសារជាភាសាខ្មែរនឹងត្រូវយកជាគោល។

## ឧបសម្ព័ន្ធ I – តារាង Lund និង Browder

ភាគរយការរលាកត្រូវបានកំណត់ដូចតារាង Lund និង Browder ខាងក្រោម៖




| ផ្នែកនៃរូបរាងកាយ | ភាគរយការរលាក |
|---|---|
| A = ពាក់ កណ្ដាលនៃក្បាល | 3.5% - 9.5% |
| B = ពាក់កណ្ដាលនៃភ្លៅមួយ | 2.75% - 4.75% |
| C = ពាក់កណ្ដាលនៃកំភួនជើងមួយ | 2.5% - 3.5% |

តារាង Lund និង Browder ត្រូវបានប្រើប្រាស់ និងទទួលស្គាល់ដោយអន្តរជាតិ ដើម្បីគណនាចំនួនភាគរយនៃការរលាកលើរូបរាងកាយ ដែលអាចប្រែប្រួលទៅតាមអាយុ នៅពេលទទួលបានការជានារ៉ាប់រង។

## ឧបសម្ព័ន្ធ II – តារាងជំងឺធ្ងន់ធ្ងរ

**1. បញ្ជីនៃអាការ:ជំងឺ ឬការវះកាត់ក្រុមទី 1**

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការ:ជំងឺធ្ងន់ធ្ងរ |
|---|---|---|
| 1. | ជំងឺមហារីក | **ជាលិកាមហារីកកកើតនៅទីតាំងដើម (CIS)**<br><br>ជាលិកាមហារីកដែលកកើតនៅទីតាំងដើម (CIS) មានន័យថាការរីវឌ្ឍន៍កើតឡើងដោយឯកឯង នៃកោសិកាមហារីកដែលឋិតនៅកោសិកាទីតាំងដើមរបស់វា តែពុំទាន់រាលដាល ឬបំផ្លាញជាលិកាដែលនៅជុំវិញ។ ការរាតត្បាតមានន័យថាការចូលស៊ី ឬបំផ្លាញជាលិកាធម្មតាយ៉ាងសកម្មហួសភ្នាសគ្រឹះខាងក្នុងនៃជាលិកា។ ការបញ្ជាក់រោគវិនិច្ឆ័យជាលិកាមហារីក ដែលកកើតនៅទីតាំងដើម (CIS) ដាច់ខាតត្រូវតែយោងតាមរបាយការណ៍វិភាគកោសិកាមហារីក។ ការបញ្ជាក់រោគវិនិច្ឆ័យជាលិកាមហារីកដែលកកើតនៅទីតាំងដើម (CIS) ត្រូវតែរកឃើញថា មានសញ្ញាវិជ្ជមានតាមរយៈការច្រឹបសាច់មកពិនិត្យ តាមមីក្រូទស្សន៍លើជាលិកាដែលមានបញ្ហាទាំងនោះ (biopsy) ។ លទ្ធផលតាមរោគសញ្ញាគ្លីនិកផ្សេងៗ មិនអាចយកជាការបានទេ។<br><br>ក្នុងករណីពាក់ព័ន្ធនឹងមាត់ស្បូនវិញ តេស្ត Pap smear តែមួយមិនអាចយកជាការបានទេ ចាំបាច់ត្រូវភ្ជាប់ជាមួយការច្រឹបយកសាច់ខាងក្រៅ ឬខាងក្នុងមាត់ស្បូនមកវិភាគ (cone biopsy ឬ colposcopy with cervical biopsy)។ លទ្ធផលតាមរោគសញ្ញាគ្លីនិក ឬការចាត់ថ្នាក់កម្រិតកោសិកា (Cervical Intraepithelial Neoplasia-CIN) ដែលមានបីដំណាក់កាល CIN I, CIN II, CIN III (កោសិកាដែលមានរូបរាងមិនធម្មតា តែមិនមែនជាកោសិកាមហារីក កកើតទីតាំងដើម - severe dysplasia without carcinoma in situ) មិនត្រូវបានរាប់បញ្ចូលនោះទេ។ មហារីកស្បែក Non-Melanoma CIS ក៏មិនត្រូវរាប់បញ្ចូលដែរ។<br><br>ការធានារ៉ាប់រងនេះ គឺសម្រាប់តែជាលិកាមហារីក ដែលកកើតនៅទីតាំងដើម (CIS) លើកដំបូងប៉ុណ្ណោះ ឬ<br><br>**មហារីកក្រពេញប្រូស្តាតដំណាក់កាលដំបូង**<br>មហារីកក្រពេញប្រូស្តាតដែលត្រូវបានធ្វើការវិភាគសាច់ តាមរយ:ចំណាត់ |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | ថ្នាក់ TNM ដែលមាន៖ T1a ឬT1b ឬT1c ឬក៏ចំណាត់ថ្នាក់មហារីកក្រពេញប្រូស្តាតដែលសមមូល នឹងចំណាត់ថ្នាក់ TNM នេះ ឬ<br><br>**មហារីកក្រពេញទីរ៉ូអ៊ីតដំណាក់កាលដំបូង**<br>មហារីកក្រពេញទីរ៉ូអ៊ីត ដែលត្រូវបានការធ្វើការវិភាគសាច់ តាមរយៈចំណាត់ថ្នាក់ TNM ដែលមាន៖ T1NOMO Papillary Microcarcinoma នៃក្រពេញទីរ៉ូអ៊ីតដែលដុំសាច់នោះ មានទំហំវិជ្ឈមាត្រតូចជាងមួយសង់ទីម៉ែត្រ ឬ<br>**មហារីកប្លោកនោមដំណាក់កាលដំបូង**<br>មហារីកប្លោកនោមដែលត្រូវបានការធ្វើការវិភាគសាច់ តាមរយៈចំណាត់ថ្នាក់ TNM ដែលមាន៖ T1NOMO រួមមាន Papillary carcinoma នៃប្លោកនោម (TaNOMO) ឬ<br>**មហារីកគ្រាប់ឈាមសពុំរ៉ៃដំណាក់កាលដំបូង**<br>មហារីកគ្រាប់ឈាមសពុំរ៉ៃដំណាក់កាលដំបូង (CLL) RAI ដំណាក់កាលទី 1 ឬទី 2 ។ CLL RAI ដំណាក់ទី 0 ឬទាបជាងនេះមិនត្រូវបានរាប់បញ្ចូលឡើយ។ |
| 2. | ជំងឺបេះដូង និង ប្រព័ន្ធសរសៃឈាម | **ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬឧបករណ៍ភ្លោចបេះដូង**<br>ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬឧបករណ៍ភ្លោចបេះដូងដែលតម្រូវចាំបាច់ដោយសារតែបញ្ហាចង្វាក់បេះដូងមិនប្រក្រតីធ្ងន់ធ្ងរ ដែលមិនអាចព្យាបាលតាមមធ្យោបាយផ្សេងបាន។ ដំណើរការវះកាត់ត្រូវតែមានការបញ្ជាក់ថាចាំបាច់ជាដាច់ខាតដោយវេជ្ជបណ្ឌិតជំនាញឯកទេសផ្នែកបេះដូងដែលបានចុះបញ្ជី (Registered Medical Practitioner)។<br><br>**ការវះកាត់ព្យាបាលសរសៃឈាម Coronary**<br>មានន័យថាការទទួលយកការវះកាត់ជាក់ស្តែង ជាលើកដំបូងនៃសរសៃឈាម Coronary ដូចជា៖ ការវះកាត់ព្យាបាលដោយប្រើឧបករណ៍ Balloon ការកាត់យកសរសៃឈាម Coronary ចេញ ការព្យាបាលតាមកាំរស្មី laser ឬការដាក់បញ្ចូលបំពង់ Stent ដើម្បីឱ្យមានលំហូរឈាមវិញនៅត្រង់សរសៃចង្អៀត ឬសរសៃឈាម Coronary មួយ ឬច្រើនដែលស្ទះដូចដែលបានបង្ហាញដោយលទ្ធផលការពិនិត្យសរសៃឈាមតាមកាំរស្មីអ៊ិច។ |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | ដំណើរការធ្វើរោគវិនិច្ឆ័យនៅក្នុងសរសៃឈាម មិនត្រូវបានរាប់បញ្ចូលឡើយ។<br><br>**ការវះកាត់ផ្នែកតូចតាចនៃរូបរាងកាយដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅសរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ**<br><br>ការវះកាត់ផ្នែកតូចតាចនៃរូបរាងកាយ ឬចោះបញ្ចូលដោយប្រើឧបករណ៍តាមសរសៃឈាមដើម្បីព្យាបាល ឬកែតម្រូវ ការរីកប៉ោងសរសៃឈាម Aorta ការស្ទះសរសៃឈាម Aorta ឬការរហែកសរសៃឈាម Aorta ដែលត្រូវបានបញ្ជាក់តាមរយៈតេស្តវិនិច្ឆ័យជាក់លាក់ និងវេជ្ជបណ្ឌិតជំនាញ។ ក្នុងនិយមន័យនេះ សរសៃឈាម Aorta មានន័យថា សរសៃឈាម Aorta នៃប្រអប់ទ្រូង និងប្រអប់ពោះ តែមិនរាប់បញ្ចូលមែកធាងសរសៃឈាមរបស់វា។ ដំណើរការធ្វើរោគវិនិច្ឆ័យនៅក្នុងសរសៃឈាម មិនត្រូវបានរាប់បញ្ចូលឡើយ។ |
| 3. | ជំងឺខួរក្បាល | **ការដាក់បំពង់បង្ហូរសារធាតុរាវចេញពីខួរក្បាល (ឧបករណ៍ Shunt)**<br><br>ការវះកាត់ដាក់ឧបករណ៍ shunt ពី ventricles នៃខួរក្បាលដើម្បីបន្ថយសម្ពាធដែលកើនឡើងនៅក្នុងទឹកស្រោមខួរក្បាល។ តម្រូវការដាក់បញ្ចូលឧបករណ៍ Shunt ត្រូវតែមានការបញ្ជាក់ថាចាំបាច់ជាដាច់ខាតដោយវេជ្ជបណ្ឌិតជំនាញឯកទេសផ្នែកប្រព័ន្ធប្រសាទដែលបានចុះបញ្ជី (Registered Medical Practitioner)។ |
| 4. | ជំងឺសួត | **ការវះកាត់យកសួតមួយចេញ (ក្នុងចំណោមសួតពីរ)**<br><br>ការវះកាត់យកសួតខាងស្តាំ ឬឆ្វេងទាំងមូលចេញរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងដែលបណ្តាលមកពីជំងឺ ឬមកពីគ្រោះថ្នាក់។ ការវះកាត់យកផ្នែកខ្លះនៃសួតមិនត្រូវបានរាប់បញ្ចូលក្នុងអត្ថប្រយោជន៍នេះទេ។ |
| 5. | ជំងឺថ្លើម | **ការវះកាត់យកថ្លើមយ៉ាងតិចមួយខ្នែបចេញ (ក្នុងចំណោមប្រាំបីខ្នែប)**<br><br>ការវះកាត់យកថ្លើមយ៉ាងតិច 1 (មួយ) ខ្នែបចេញពីថ្លើមទាំងមូលរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងដែលបណ្តាលមកពីជំងឺ ឬគ្រោះថ្នាក់ ហើយការវះកាត់នេះត្រូវបានបញ្ជាក់ថាចាំបាច់ ។<br><br>ការវះកាត់ថ្លើមដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនហួសកម្រិត និងការបរិច្ចាគថ្លើមគឺមិនត្រូវបានរាប់បញ្ចូលឡើយ។ |
| 6. | ជំងឺតម្រងនោម | **ការវះកាត់យកតម្រងនោមមួយចេញ (ក្នុងចំណោមតម្រងនោមពីរ)** |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | ការវះកាត់យកតម្រងនោមមួយចេញ (ក្នុងចំណោមតម្រងនោមពីរ) ដោយសារជំងឺ ឬគ្រោះថ្នាក់ចៃដន្យ។ ការវះកាត់យកចេញតម្រងនោមនេះ ត្រូវតែមានការបញ្ជាក់ថាចាំបាច់ជាដាច់ខាត ដោយវេជ្ជបណ្ឌិតជំនាញ។ ការវះកាត់យកផ្នែកណាមួយនៃតម្រងនោម និងការបរិច្ចាគតម្រងនោម មិនត្រូវបានរាប់បញ្ចូលឡើយ។ |
| 7. | ការផ្លាស់ប្តូរសរីរាង្គ | **ការផ្លាស់ប្តូរពោះវៀនតូច (ចាប់ពីមួយម៉ែត្រឡើងទៅ)**<br><br>ការផ្លាស់ប្តូរពោះវៀនតូចដែលខូច រួមទាំងសរសៃឈាមដែលចិញ្ចឹមពោះវៀននោះ (ចាប់ពីមួយម៉ែត្រឡើងទៅ) តាមរយៈការវះបើកប្រអប់ពោះទាំងស្រុង។ |

## 2. បញ្ជីនៃអាការៈជំងឺ ឬការវះកាត់ក្រុមទី 2

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| 1. | ជំងឺមហារីក | **ជំងឺមហារីក - កម្រិតធ្ងន់ធ្ងរដោយមិនរាប់បញ្ចូលជំងឺមហារីកដំណាក់កាលដំបូង**<br><br>រាល់ដុំសាច់មហារីកដែលត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា មានសញ្ញាវិជ្ជមានដែលកំណត់ដោយការវិភាគសាច់ និងឃើញមានការរីករាលដាលនៃកោសិកាមហារីកដែលមិនអាចគ្រប់គ្រងបាន។ និយមន័យពាក្យដុំសាច់មហារីករួមមាន មហារីកឈាម ស lymphoma និង sarcoma។<br>ចំពោះនិយមន័យខាងលើ មិនរួមបញ្ចូលអាការៈខាងក្រោមនេះទេ៖<br>(i) រាល់ជំងឺមហារីកដែលត្រូវបានចាត់ថ្នាក់តាមការវិភាគសាច់ដូចខាងក្រោម៖<br>- ដុំសាច់ដែលមិនទាន់ក្លាយជាដុំសាច់មហារីក<br>- ដែលមិនរាតត្បាត/រាលដាល<br>- ជាលិកាមហារីកកកើតនៅទីតាំងដើម<br>- ដុំសាច់ដែលជិតក្លាយជាដុំសាច់មហារីក<br>- ដុំសាច់ដែលនឹងក្លាយជាដុំសាច់មហារីក<br>(ii) រាល់ដុំសាច់មហារីកក្រពេញប្រូស្តាតដែលត្រូវបានចាត់ថ្នាក់ជា T1N0M0 តាមការវិភាគសាច់ (តាមចំណាត់ថ្នាក់ TNM)<br>(iii) រាល់ដុំសាច់មហារីកក្រពេញទីរ៉ូអ៊ីតដែលត្រូវបានចាត់ថ្នាក់ជា T1N0M0 តាមការវិភាគសាច់ (តាមចំណាត់ថ្នាក់ TNM) |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | (iv) រាល់ដុំសាច់មហារីកប្លោកនោមដែលត្រូវបានចាត់ថ្នាក់ជា T1N0M0 តាមការវិភាគសាច់ (តាមចំណាត់ថ្នាក់ TNM)<br>(v) មហារីកគ្រាប់ឈាមសរ៉ាំរ៉ៃប្រភេទ (CLL) ទាបជាងកម្រិត RAI Stage 3<br>(vi) ជំងឺមហារីកទាំងអស់ដែលបណ្តាលមកពីមេរោគអេដស៍<br>(vii) ជំងឺមហារីកស្បែកទាំងអស់លើកលែងតែមហារីក malignant melanoma។ |
| 2. | ជំងឺបេះដូង និង ប្រព័ន្ធសរសៃឈាម | **ជំងឺគាំងបេះដូង - នៃកម្រិតធ្ងន់ធ្ងរជាក់លាក់**<br><br>ការស្លាប់សាច់ដុំបេះដូងដោយកង្វះការផ្គត់ផ្គង់ឈាម ដែលបង្កឱ្យមានរោគសញ្ញានៃជំងឺស្លោកសាច់ដុំបេះដូងស្រួចស្រាល (acute myocardial infarction) ដូចខាងក្រោម៖<br>(i) ការឈឺទ្រូងជាប្រចាំពីមុនមក និង<br>(ii) សញ្ញាផ្លាស់ប្តូរ electrocardiographic របស់បេះដូងរួមជាមួយការកើតមានឡើងនៃសញ្ញានដូចតទៅនេះ៖ ST elevation or depression, T wave inversion, pathological Q waves or left bundle branch block និង<br>(iii) ការកើនឡើងនៃសារជាតុ cardiac biomarkers រួមមាន អង់ស៊ីម CPK-MB លើសពីកម្រិតមធ្យមដែលកំណត់ដោយមន្ទីរពិសោធន៍ ឬ សារជាតុ Troponins ដែលបានកំណត់នៅកម្រិតដូចតទៅនេះ ឬ ខ្ពស់ជាងនេះតាមរយៈតេស្តឈាម៖ Cardiac Troponin T or Cardiac Troponin I > / = 0.5 ng/ml និង<br><br>លទ្ធផល ត្រូវតែបង្ហាញពីការកើតរោគសញ្ញានៃជំងឺស្លោកសាច់ដុំបេះដូងស្រួចស្រាល (acute myocardial infarction) ដែលបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញឯកទេសខាងបេះដូង ឬវេជ្ជបណ្ឌិតជំងឺទូទៅ។<br><br>ចំពោះនិយមន័យខាងលើ រោគសញ្ញាខាងក្រោមមិនត្រូវបានរាប់បញ្ចូលឡើយ៖<br>- ការកើតរោគសញ្ញា acute coronary syndrome រួមបញ្ចូល តែមិនកំណត់ត្រឹម unstable angina |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | - ការកើនឡើងនៃសារជាតុ cardiac biomarkers ដែលបង្កមកពីដំណើរការ percutaneous ដើម្បីព្យាបាល Coronary Artery Disease (CAD)។<br><br>**ការវះកាត់បង្វៀងផ្លូវសរសៃឈាម Coronary Artery**<br><br>សំដៅទៅការវះកាត់បើកប្រអប់ទ្រូងដើម្បីកែតម្រូវ ឬព្យាបាល Coronary Artery Disease (CAD)តាមវិធីវះកាត់បង្វៀងផ្លូវសរសៃឈាម Coronary Artery។<br>ចំពោះនិយមន័យខាងលើវិធីសាស្ត្រព្យាបាលខាងក្រោម មិនត្រូវបានរាប់បញ្ចូលឡើយៈ<br><br>(i) ការវះកាត់ព្យាបាលសរសៃឈាម<br>(ii) បច្ចេកទេសផ្សេងៗនៃការចោះបញ្ចូលឧបករណ៍តាមសរសៃឈាម Arteria ឬ ដាក់បំពង់ទុយោ<br>(iii) ការវះកាត់ដោយចោះ<br>(iv) ការព្យាបាលដោយបាញ់កាំរស្មី (Laser)<br><br>**ការវះកាត់ប្រអប់ទ្រូង ឬប្រអប់ពោះដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅ សរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ**<br><br>ការវះកាត់តាមរយៈការបើកប្រអប់ទ្រូង ឬប្រអប់ពោះដើម្បីព្យាបាល ឬកែតម្រូវការរីកប៉ោងសរសៃឈាម Aorta ការស្ទះសរសៃឈាម Aorta ឬការរហែក Aorta។<br><br>ក្នុងនិយមន័យនេះ សរសៃឈាម Aorta មានន័យថា សរសៃឈាម Aorta នៃប្រអប់ទ្រូង និងប្រអប់ពោះ តែមិនរាប់បញ្ចូលសរសៃឈាមមែកធាងរបស់វាទេ។<br><br>សម្រាប់និយមន័យខាងលើ មិនបានរាប់បញ្ចូលវិធីសាស្ត្រព្យាបាលខាងក្រោមនេះឡើយៈ<br>(i) ការវះកាត់ព្យាបាលសរសៃឈាម<br>(ii) បច្ចេកទេសផ្សេងៗនៃការចោះបញ្ចូលឧបករណ៍តាមសរសៃឈាម Arteria ឬ ដាក់បំពង់ទុយោ<br>(iii) ការវះកាត់ដោយចោះ |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | (iv) ការព្យាបាលដោយបាញ់កាំរស្មី (Laser) |
| 3. | ជំងឺខួរក្បាល | **ជំងឺដាច់សរសៃឈាមខួរក្បាល - ដែលបណ្តាលឱ្យមានការខូចខាតប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងការបន្តនៃរោគសញ្ញាគ្លីនិក**<br><br>ការងាប់ជាលិកាខួរក្បាលដោយសារការខ្វះឈាម ការហូរឈាមក្នុងលលាដ៍ក្បាល ឬមានហើមដុំឈាមទៅបិទសរសៃឈាមមិនប្រក្រតីពីប្រភពខាងក្រៅលលាដ៍ក្បាល ដែលបណ្តាលឱ្យមានការខូចខាតប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងការបន្តនៃរោគសញ្ញាគ្លីនិក។ ការធ្វើរោគវិនិច្ឆ័យត្រូវផ្អែកលើការប្តូរដែលរកឃើញតាមរយៈ ស៊ីធីស្កេន (CT Scan) ឬការថត អ៊ឹមអរអាយ (MRI) និងត្រូវបានបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញឯកទេសខាងផ្នែកប្រព័ន្ធប្រសាទ ដែលបានចុះបញ្ជី។ ការវាយតម្លៃនេះត្រូវមានរយៈពេលវាយតម្លៃ 3 (បី) ខែ។<br><br>ចំពោះនិយមន័យខាងលើ ជំងឺខាងក្រោមមិនត្រូវបានរាប់បញ្ចូលឡើយ៖<br>(i) ការស្ទះសរសៃឈាមខួរក្បាលមួយរំពេច<br>(ii) អាការៈរោគខួរក្បាលដោយសាររោគប្រកាំង<br>(iii) ការរងរបួសដែលបណ្តាលឱ្យប៉ះពាល់ ដល់ជាលិកា ឬសរសៃឈាមខួរក្បាល<br>(iv) ជំងឺសរសៃឈាមដែលប៉ះពាល់ដល់ភ្នែក ឬសរសៃបាតភ្នែក ឬមុខនាទីទប់លំនឹង។ |
| 4. | ជំងឺសួត | **ជំងឺសួតដំណាក់កាលចុងក្រោយ**<br><br>ជំងឺសួតដំណាក់កាលចុងក្រោយបង្កឱ្យមានការខូចខាតប្រព័ន្ធដង្ហើមរ៉ុាំរ៉ៃ។ ត្រូវតែមានលក្ខណៈវិនិច្ឆ័យទាំងអស់ដូចខាងក្រោម៖<br><br>(i) ការបញ្ចូលអុកស៊ីសែនជាប្រចាំ<br>(ii) ការចុះខ្សោយជាអចិន្ត្រៃយ៍នៃមុខងារសួត ដែលការវាស់កម្រិតដង្ហើមចេញ មានកម្រិតថេរ ហើយតិចជាង 1 លីត្រខ្យល់ក្នុងរយៈពេលមួយវិនាទីដំបូង<br>(iii) ការដកដង្ហើមញាប់នៅពេលសម្រាក និង<br>(iv) ការធ្វើវិភាគកម្រិតឧស្ម័នក្នុងសរសៃឈាម Artery ជាមួយនឹងសម្ពាធអុកស៊ីសែនដែលមានកម្រិត 55mmHg ឬតិចជាងនេះ។ |
| 5. | ជំងឺថ្លើម | **ការខូចថ្លើមដំណាក់កាលចុងក្រោយ**<br><br>ការខូចថ្លើមដំណាក់កាលចុងក្រោយមានអាការៈទាំងអស់ដូចខាងក្រោម៖ |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| | | (i) ខាន់លឿងជាអចិន្ត្រៃយ៍<br>(ii) ទាចទឹក (ទឹកច្រើនលើសកម្រិតនៅក្នុងស្រោមពោះ) និង<br>(iii) ការចុះខ្សោយមុខងារខួរក្បាលដោយសារជំងឺថ្លើមធ្ងន់ធ្ងរ។<br><br>ការខូចថ្លើមដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនមិនត្រូវបានរាប់បញ្ចូលឡើយ។ |
| 6. | ជំងឺតម្រងនោម | **ការខូចតម្រងនោមដំណាក់កាលចុងក្រោយ**<br><br>ការខូចតម្រងនោមដំណាក់កាលចុងក្រោយ ត្រូវបានគេកំណត់ថាជាការបាត់បង់មុខងារតម្រងនោមទាំងសងខាងដ៏រ៉ាំរ៉ៃ ដែលមិនអាចជាមកសភាពដើមបាន ដែលតម្រូវឱ្យមានការលាងឈាមជាទៀងទាត់ ឬធ្វើការផ្លាស់ប្តូរតម្រងនោម។ |

| លេខ | ប្រភេទជំងឺធ្ងន់ធ្ងរ | អាការៈជំងឺធ្ងន់ធ្ងរ |
|---|---|---|
| 7. | ការផ្លាស់ប្តូរសរីរាង្គ | **ការផ្លាស់ប្តូរបេះដូង**<br>ការផ្លាស់ប្តូរបេះដូង ដែលបណ្តាលមកពីការខូចខាតបេះដូងដំណាក់កាលចុងក្រោយ និងមិនអាចជាសះស្បើយបាន។<br>ការផ្លាស់ប្តូរកោសិកាដើម ការផ្លាស់ប្តូរកោសិកា islet របស់បេះដូង និងការផ្លាស់ប្តូរផ្នែកណាមួយនៃបេះដូងមិនត្រូវបានរាប់បញ្ចូលឡើយ។<br>**ការផ្លាស់ប្តូរសួត**<br>ការផ្លាស់ប្តូរសួត ដែលបណ្តាលមកពីការខូចខាតសួតដំណាក់កាលចុងក្រោយ និងមិនអាចជាសះស្បើយបាន។<br>ការផ្លាស់ប្តូរកោសិកាដើម ការផ្លាស់ប្តូរកោសិកា islet របស់សួត និង ការផ្លាស់ប្តូរផ្នែកណាមួយនៃសួតមិនត្រូវបានរាប់បញ្ចូលឡើយ។<br>**ការផ្លាស់ប្តូរថ្លើម**<br>ការផ្លាស់ប្តូរថ្លើម ដែលបណ្តាលមកពីការខូចខាតថ្លើមដំណាក់កាលចុងក្រោយ និងមិនអាចជាសះស្បើយបាន។<br>ការផ្លាស់ប្តូរកោសិកាដើម ការផ្លាស់ប្តូរកោសិកា islet របស់ថ្លើម និងការផ្លាស់ប្តូរផ្នែកណាមួយរបស់ថ្លើមមិនត្រូវបានរាប់បញ្ចូលឡើយ។<br>**ការផ្លាស់ប្តូរតម្រងនោម**<br>ការផ្លាស់ប្តូរតម្រងនោម ដែលបណ្តាលមកពីការខូចខាតតម្រងនោមដំណាក់កាលចុងក្រោយ និងមិនអាចជាសះស្បើយបាន។<br>ការផ្លាស់ប្តូរកោសិកាដើម ការផ្លាស់ប្តូរកោសិកា islet របស់តម្រងនោម និងការផ្លាស់ប្តូរផ្នែកណាមួយនៃតម្រងនោមមិនត្រូវបានរាប់បញ្ចូលឡើយ។<br>**ការផ្លាស់ប្តូរលំពែង**<br>ការផ្លាស់ប្តូរលំពែង ដែលបណ្តាលមកពីការខូចខាតលំពែងដំណាក់កាលចុងក្រោយ និងមិនអាចជាសះស្បើយបាន។<br>ការផ្លាស់ប្តូរកោសិកាដើម ការផ្លាស់ប្តូរកោសិកា islet របស់លំពែង និងការផ្លាស់ប្តូរផ្នែកណាមួយនៃលំពែងមិនត្រូវបានរាប់បញ្ចូលឡើយ។ |

# បណ្ណសន្យារ៉ាប់រង
# ផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare

## តារាងមាតិកា


បណ្ណសន្យារ៉ាប់រង ..... 1

I. និយមន័យ ..... 1

II. កម្មវត្ថុនៃការធានា ..... 5

III. វិសាលភាពធានារ៉ាប់រង ..... 5

IV. អត្ថប្រយោជន៍ធានារ៉ាប់រង ..... 10

V. ការបង់បុព្វលាភធានារ៉ាប់រង ..... 12

VI. ករណីមិនធានា ..... 12

VII. ទីតាំងភូមិសាស្ត្រនៃការធានា ..... 15

VIII. លក្ខណៈសម្បត្តិរបស់អ្នកទទួលផល ..... 15

IX. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង ..... 16

X. ការបន្តកិច្ចសន្យាធានារ៉ាប់រង ..... 16

XI. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ..... 16

XII. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង ..... 17

XIII. ការទាមទារសំណង ..... 17

1. ការស្នើសុំការអនុញ្ញាតជាមុន ..... 17
2. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង ..... 17
3. និតិវិធីនៃការផ្តល់ព័ត៌មាន ..... 18
4. រយៈពេលអតិបរមានៃការទូទាត់សំណងជូនអតិថិជន ..... 18
5. របៀបទូទាត់សំណង ..... 18
6. សិទ្ធិត្រួតពិនិត្យ ..... 18

XIV. ការរក្សាការព័ត៌មានសម្ងាត់ ..... 18

XV. ការផ្សះផ្សាវិវាទ ..... 19

1. នីតិវិធីដោះស្រាយបណ្តឹងអតិថិជន ..... 19
2. នីតិវិធីនៃការផ្សះផ្សាវិវាទ ..... 19

XVI. ដែនយុត្តាធិការ ..... 19

# បណ្ណសន្យារ៉ាប់រង
# ផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare

## I. និយមន័យ

ពាក្យ និងឃ្លាខាងក្រោមនេះនឹងត្រូវបានកំណត់អត្ថន័យសម្រាប់ផលិតផលធានារ៉ាប់រងបន្ថែម **AIA MedCare** (“**ផលិតផលធានារ៉ាប់រងបន្ថែមនេះ**”) លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ ពាក្យ និងឃ្លាដែលបានប្រើប្រាស់ក្នុងផលិត ផលធានារ៉ាប់រងបន្ថែមនេះ ប៉ុន្តែមិនត្រូវបានកំណត់ខាងក្រោម ត្រូវអនុលោមតាមអត្ថន័យដែលបានកំណត់ក្រោមបណ្ណសន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រងមូលដ្ឋាន។ ក្នុងករណីមានភាពមិនស៊ីសង្វាក់គ្នារវាង ខ និងលក្ខខណ្ឌនៃបណ្ណ សន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រងមូលដ្ឋាន និងបណ្ណសន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម នោះ ខ និងលក្ខខណ្ឌនៃផលិតផលធានារ៉ាប់រងបន្ថែមត្រូវយកជាគោល។

1. **គ្រោះថ្នាក់ចៃដន្យ** សំដៅលើ ហេតុការណ៍ដែលកើតឡើងភ្លាមៗ ដោយអចេតនា ដោយចៃដន្យ ខុសជម្មតា និងជាព្រឹត្តិការណ៍ជាក់លាក់មួយដែលបានកើតឡើងនៅពេលវេលា និងទីកន្លែងមួយដែលអាចកំណត់បាន និងមិនពាក់ព័ន្ធនឹងមូលហេតុដទៃផ្សេងទៀត ដែលជាមូលហេតុតែមួយគត់ដែលបង្កឱ្យមានរបួសរូបរាងកាយនេះ។
2. **រថយន្តគិលានសង្គ្រោះបន្ទាន់** សំដៅលើ យានយន្តបើកបរលើផ្លូវ ដែលដំណើរការដោយសេវាកម្មដែលមានអាជ្ញា បណ្ណ ហើយផ្តល់ជូន និងបំពាក់គ្រឿងបរិក្ខារសម្រាប់ការដឹកជញ្ជូន និងការព្យាបាលសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។
3. **គ្រឿងបរិក្ខារ** សំដៅលើ ឧបករណ៍ និងបរិក្ខារនានា ដែលត្រូវបានប្រើប្រាស់ដោយវេជ្ជបណ្ឌិតជំនាញឯកទេស ឬអ្នកជំនាញនៅក្នុងដំណើរការវះកាត់។
4. **បណ្ណសន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រងមូលដ្ឋាន** សំដៅលើ ខ និងលក្ខខណ្ឌនៃផលិតផលធានារ៉ាប់រងមូលដ្ឋាន ដែលផលិតផលធានារ៉ាប់រងបន្ថែមនេះភ្ជាប់ជាមួយ និងត្រូវបានចាត់បញ្ចូលជាផ្នែកមួយនៃបណ្ណសន្យារ៉ាប់រងនោះ។
5. **អត្ថប្រយោជន៍** សំដៅលើ ការធានារ៉ាប់រងដែលផ្តល់ជូនក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ដូចដែលបានបង្ហាញលើវិញ្ញាបនបត្រធានារ៉ាប់រង និង/ឬតារាងអត្ថប្រយោជន៍។
6. **តារាងអត្ថប្រយោជន៍** សំដៅលើ តារាងដែលបានបង្ហាញអត្ថប្រយោជន៍អតិបរមា ដែលក្រុមហ៊ុននឹងផ្តល់ជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រងក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ។
7. **របួសរូបរាងកាយ** សំដៅលើ លក្ខណៈមិនប្រក្រតីនៃរូបរាងកាយដែលកើតមានឡើងក្នុងកំឡុងពេលដែលផលិតផលធានារ៉ាប់រងបន្ថែមនេះមានសុពលភាព និងបានកើតឡើងដោយផ្ទាល់ និងឯករាជ្យពីមូលហេតុទាំងឡាយដូចជា ដោយអំពើហិង្សា ពីខាងក្រៅ អាចមើលឃើញ និងដោយចៃដន្យតែប៉ុណ្ណោះ ហើយមិនមែនបណ្តាលមកពីជំងឺ ឬមេរោគណាមួយឡើយ។
8. **ការចូលរួមចំណែកនៃការចំណាយ ឬ ចំណែកនៃចំណាយដែលត្រូវបង់** សំដៅលើ ភាគរយនៃចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងនឹងត្រូវទទួលខុសត្រូវលើសំណងណាមួយដូចដែលបានកំណត់លើតារាងអត្ថប្រយោជន៍។ ចំពោះកម្រិតអត្ថប្រយោជន៍ដែលនៅសល់ នឹងត្រូវផ្តល់ជូន ដោយយកចំណែកនៃ

ចំណាយដែលត្រូវបង់ កាត់ចេញពីតម្លៃសុទ្ធនៃចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ ចំនួនភាគរយនៃចំណែកនៃចំណាយដែលត្រូវបង់ មាន 2 របៀបផ្សេងគ្នា នៅលើតារាងអត្ថប្រយោជន៍៖

(i) ការចូលរួមចំណែកនៃការចំណាយក្នុងបណ្តាញមន្ទីរពេទ្យដៃគូ អនុវត្តនៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅមន្ទីរពេទ្យ ឬអ្នកផ្តល់សេវា ដែលជាមន្ទីរពេទ្យក្នុងបណ្តាញដៃគូ។

(ii) ការចូលរួមចំណែកនៃការចំណាយក្រៅបណ្តាញមន្ទីរពេទ្យដៃគូ អនុវត្តនៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅមន្ទីរពេទ្យ ឬអ្នកផ្តល់សេវា ដែលមិនមែនជាមន្ទីរពេទ្យក្នុងបណ្តាញដៃគូ។

នៅពេលដែលការចូលរួមចំណែកនៃការចំណាយដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដូចដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍ សមាជិកអ្នកត្រូវបានធានារ៉ាប់រងនឹងមិនតម្រូវឱ្យទទួលខុសត្រូវលើចំណែកនៃចំណាយដែលត្រូវបង់ណាមួយ នៅក្នុងបណ្តាញមន្ទីរពេទ្យដៃគូទៀតឡើយ រហូតដល់ចុងបញ្ចប់នៃឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

9. **ទន្តពេទ្យ** សំដៅលើ បុគ្គលដែលត្រូវបានផ្តល់អាជ្ញាបណ្ណ ឬចុះបញ្ជីត្រឹមត្រូវក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យទន្តសាស្ត្រនៅក្នុងទីតាំងភូមិសាស្ត្រនៃការធានា ប៉ុន្តែមិនរាប់បញ្ចូលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។

10. **វេជ្ជបណ្ឌិតជំងឺទូទៅ ឬ វេជ្ជបណ្ឌិតវះកាត់** សំដៅលើ វេជ្ជបណ្ឌិតជំនាញឯកទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវបានផ្តល់អាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈពេទ្យតាមបែបបស្ចឹមប្រទេស និងអ្នកដែលប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណរបស់ខ្លួន និងបានទទួលការបណ្តុះបណ្តាលក្នុងទីតាំងភូមិសាស្ត្រនៃការធានា ប៉ុន្តែមិនរាប់បញ្ចូលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។

11. **ឱសថ សម្ភារៈរុំរបួស និងចំណាយលើសម្ភារៈប្រើប្រាស់ផ្សេងៗ** សំដៅលើ ឱសថ និងសម្ភារៈរុំរបួសចាំបាច់នានា ដែលចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិតជំនាញឯកទេស ឬអ្នកជំនាញ និងដែលទទួលស្គាល់ដោយក្រុមហ៊ុនថាចាំបាច់សម្រាប់ការព្យាបាលស្ថានភាពជំងឺដែលមានលក្ខខណ្ឌគ្រប់គ្រាន់។

12. **ដែលមានលក្ខខណ្ឌគ្រប់គ្រាន់** សំដៅលើ ការព្យាបាល និងចំណាយទាំងឡាយណាដែលត្រូវបានធានាដោយផលិតផលធានារ៉ាប់រងបន្ថែមនេះ។ ដើម្បីកំណត់ថាការព្យាបាល ឬចំណាយណាមួយត្រូវបានធានា អ្នកត្រូវអានគ្រប់ផ្នែកនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ និងអនុលោមទៅតាមខសន្យា អត្ថប្រយោជន៍ និងករណីមិនធានា ដែលកំណត់ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ។ ក្នុងករណីដែលមានការមិនព្រមព្រៀងគ្នារវាងក្រុមហ៊ុន សមាជិកអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង គូភាគីត្រូវស្នើសុំយោបល់ពីតតិយភាគី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអាចទទួលយកបាន។

13. **សង្គ្រោះបន្ទាន់** សំដៅលើ ការព្យាបាលដែលតម្រូវឱ្យមានភ្លាមៗ ក្នុងកំឡុងពេល 24 (ម្ភៃបួន) ម៉ោង សម្រាប់របួស ជំងឺ ឬរោគសញ្ញាណាមួយ ដែលកើតឡើងភ្លាមៗ និងមានសភាពធ្ងន់ធ្ងរ ហើយអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត (ឧទាហរណ៍ គ្រោះថ្នាក់ចៃដន្យ និងអាការៈគាំងបេះដូង) ឬអាចនាំឱ្យសុខភាពធ្លាក់ចុះទ្រុឌទ្រោម។

14. **ការព្យាបាលសាកល្បង ឬជកពិសោធន៍** សំដៅលើ ការព្យាបាលណាមួយដែលមិនបានទទួលការអនុម័ត និងអាជ្ញា បណ្ណពីអាជ្ញាធរសុខាភិបាលដែលគ្រប់គ្រងលើការព្យាបាលសុខភាព (រួមបញ្ចូលទាំងឱសថ) ក្នុងតំបន់ដែលទទួលការព្យាបាល។

15. **ការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ** សំដៅលើ មន្ទីរសុខភាពមួយដែលផ្តល់ការមើលថែទាំអ្នកជំងឺ ដែលជាការព្យាបាល ឬផ្តល់ការប្រឹក្សាយោបល់ជាក់លាក់ណាមួយ សម្រាប់គោលបំណងក្នុងការបន្ថយអាការៈឈឺចាប់ និងមិនមែនជាការព្យាបាលជាដាច់។
16. **មន្ទីរពេទ្យ** សំដៅទៅស្ថាប័នវេជ្ជសាស្ត្រដែលទទួលបានអាជ្ញាបណ្ណស្របច្បាប់ជាមន្ទីរពេទ្យព្យាបាលជំងឺ ឬមន្ទីរពេទ្យវះកាត់ ក្រោមច្បាប់នៃប្រទេសដែលមន្ទីរពេទ្យនោះតាំងនៅ ហើយដែលទទួលស្គាល់ដោយក្រុមហ៊ុនថាជាមន្ទីរពេទ្យដែលអាចផ្តល់ការព្យាបាលក្នុងតម្លៃសមហេតុផល។
17. **មន្ទីរពេទ្យក្នុងបណ្តាញដៃគូ** (មានតែនៅក្នុងប្រទេសមួយចំនួនប៉ុណ្ណោះ) សំដៅលើ អ្នកផ្តល់សេវាផ្នែកវេជ្ជសាស្ត្រដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងអាចទទួលបានការព្យាបាល សម្រាប់ស្ថានភាពជំងឺដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ សមាជិកអ្នកត្រូវបានធានារ៉ាប់រងនៅតែត្រូវទទួលខុសត្រូវចំពោះការចូលរួមចំណែកនៃការចំណាយណាមួយដែលត្រូវតែទូទាត់ដោយផ្ទាល់ជាមួយអ្នកផ្តល់សេវាផ្នែកវេជ្ជសាស្ត្រនៅខណៈពេលនៃការព្យាបាល។
18. **ជំងឺ** សំដៅលើ ស្ថានភាពរូបរាងកាយ ឬផ្លូវចិត្ត ដែលប្រែប្រួលពីស្ថានភាពសុខភាពធម្មតាដោយរោគសាស្ត្រ។
19. **កម្រិតអតិបរមាប្រចាំឆ្នាំសម្រាប់ការព្យាបាលពីជំងឺ** សំដៅលើ ចំនួនអតិបរមាដែលនឹងបង់ជូនប្រចាំឆ្នាំនៃបណ្ណសន្យារ៉ាប់រង សម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនីមួយៗ លើចំណាយសេវាវេជ្ជសាស្ត្រដែលកើតឡើងសម្រាប់ការព្យាបាលដែលបង្កឡើងពីជំងឺ។
20. **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ** សំដៅលើ សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលមានភាពចាំបាច់ក្នុងការព្យាបាលនៅមន្ទីរពេទ្យលើសពី 06 (ប្រាំមួយ) ម៉ោងជាប់គ្នាឡើងទៅ។
21. **បន្ទប់សង្គ្រោះបន្ទាន់** (ICU) សំដៅលើ ផ្នែកមួយនៅក្នុងមន្ទីរពេទ្យ ដែលរៀបចំឡើងដើម្បីផ្តល់ការថែទាំ និងព្យាបាលសង្គ្រោះបន្ទាន់ ដោយមន្ទីរពេទ្យ និងបើកដំណើរការ 24 (ម្ភៃបួន) ម៉ោង រៀងរាល់ថ្ងៃ សម្រាប់ការព្យាបាលអ្នកជំងឺដែលស្ថានភាពធ្ងន់ធ្ងរតែប៉ុណ្ណោះ ហើយត្រូវបានបំពាក់ឧបករណ៍ដើម្បីផ្តល់នូវការថែទាំបែបពិសេស និងសេវាវេជ្ជសាស្ត្រដែលពុំមានផ្តល់ជូននៅទីកន្លែងផ្សេងក្នុងមន្ទីរពេទ្យនោះ។
22. **ស្ថានភាពជំងឺ** សំដៅលើ របួស ជំងឺ ឬមេរោគណាមួយដែលត្រូវបានធានានៅក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ។
23. **ភាពចាំបាច់ក្នុងការព្យាបាល** សំដៅលើ ការព្យាបាល សេវាកម្ម ឬដំណើរការដែលវេជ្ជបណ្ឌិតជំនាញឯកទេសគិតថាសាកសម ស្របនឹងរោគវិនិច្ឆ័យ និងបទដ្ឋានទូទៅ។
24. **វេជ្ជបណ្ឌិតជំនាញឯកទេស** សំដៅលើ បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការព្យាបាលតាមវេជ្ជសាស្ត្រលោកខាងលិច ដែលត្រូវបានចុះបញ្ជីការជាមួយគណកម្មការវេជ្ជសាស្ត្រក្នុងប្រទេសដែលគាត់ផ្តល់សេវាវេជ្ជសាស្ត្រ ឬវះកាត់នោះ និងជាអ្នកដែលប្រកបវិជ្ជាជីវៈក្នុងទំហំវិសាលភាពនៃអាជ្ញាបណ្ណ និងការបណ្តុះបណ្តាលក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ ប៉ុន្តែមិនរាប់បញ្ចូលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។
25. **អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ** សំដៅលើ សមាជិកអ្នកត្រូវបានធានារ៉ាប់រងដែលទទួលការព្យាបាលនៅមន្ទីរពេទ្យដែលត្រូវបានទទួលស្គាល់ ប៉ុន្តែមិនបានចូលសម្រាកព្យាបាលលើគ្រែនៅមន្ទីរពេទ្យក្នុងនាមជាអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យនោះឡើយ។
26. **កម្រិតអតិបរមាប្រចាំឆ្នាំសរុប** សំដៅលើ ចំនួនអតិបរមាដែលនឹងបង់ជូនទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនីមួយៗក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

27. **កម្រិតអតិបរមាសរុបក្នុងមួយជីវិត** សំដៅលើ ចំនួនអតិបរមាដែលនឹងបង់ជូនទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនីមួយៗសម្រាប់មួយជីវិតនៃបណ្ណសន្យារ៉ាប់រង។
28. **វេជ្ជបណ្ឌិតផ្នែកចលនាសាស្ត្រ** សំដៅលើ បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងទទួលបានអាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈជាវេជ្ជបណ្ឌិតផ្នែកចលនាសាស្ត្រ នៅកន្លែងដែលការព្យាបាលត្រូវបានផ្តល់ជូន ហើយដែលទទួលស្គាល់ដោយក្រុមហ៊ុនថាជាវេជ្ជបណ្ឌិតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអាចផ្តល់ការព្យាបាលក្នុងកម្រិតតម្លៃដែលសមហេតុផល។
29. **ស្ថានភាពមុនពេលធានារ៉ាប់រង** សំដៅលើ ជំងឺដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានដឹងអំពីវា។ សមាជិកអ្នកត្រូវបានធានារ៉ាប់រង អាចត្រូវបានចាត់ទុកថាបានដឹងអំពីស្ថានភាពមុនពេលធានារ៉ាប់រង ដែលស្ថានភាពនេះជាស្ថានភាពមួយដែល៖
    (v) សមាជិកអ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលបានការព្យាបាល ឬ
    (vi) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំជូនអ្នក ឬ
    (vii) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
    (viii) វត្តមាននៃស្ថានភាពនោះ អាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈមួយ។
30. **អ្នកផ្តល់សេវា** សំដៅលើ មន្ទីរសុខភាពមួយ ដែលបានទទួលអាជ្ញាបណ្ណស្របច្បាប់ក្នុងការផ្តល់ជូនការព្យាបាលជំងឺ និងការព្យាបាលដោយការវះកាត់នៅក្នុងប្រទេសដែលអ្នកផ្តល់សេវាស្ថិតនៅ ហើយទទួលស្គាល់ដោយក្រុមហ៊ុនថាជាអ្នកផ្តល់សេវាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាចផ្តល់ការព្យាបាលក្នុងកម្រិតសមហេតុផល។
31. **សមហេតុផល** សំដៅលើ ចំណាយ ឬសាហ៊ុយណាមួយ ដែលត្រូវបានគិតថ្លៃសម្រាប់ការព្យាបាល ការផ្គត់ផ្គង់លើ សម្ភារៈប្រើប្រាស់ ឬសេវាវេជ្ជសាស្ត្រ ដែលមានភាពចាំបាច់ក្នុងការព្យាបាលស្ថានភាពសុខភាព និងដែលអនុលោមតាមស្តង់ដារនៃការអនុវត្តផ្នែកវេជ្ជសាស្ត្រដ៏ល្អ សម្រាប់ការថែទាំអ្នករបួស ឬអ្នកជំងឺ ក្រោមការត្រួតពិនិត្យ ឬវេជ្ជបញ្ជាពីវេជ្ជបណ្ឌិតជំងឺទូទៅ ឬអ្នកជំនាញ ហើយដែលតាមគំនិតរបស់ក្រុមហ៊ុន ឬទីប្រឹក្សាវេជ្ជសាស្ត្ររបស់ក្រុមហ៊ុនថា៖
    (i) មិនលើសពីកម្រិតធម្មតានៃតម្លៃសម្រាប់ការព្យាបាល ការផ្គត់ផ្គង់លើសម្ភារៈប្រើប្រាស់ ឬសេវាវេជ្ជសាស្ត្រដែលស្រដៀងគ្នា ឬ
    (ii) មិនបូកបញ្ចូលចំណាយ ឬសាហ៊ុយណាមួយដែលមិនត្រូវបានបូកបញ្ចូល ប្រសិនបើគ្មានបណ្ណសន្យារ៉ាប់រង ឬ
    (iii) មិនលើសពីតម្លៃប្រៀបធៀប ដែលបានណែនាំដោយរដ្ឋាភិបាល និងក្រសួងសុខាភិបាលនៅក្នុងប្រទេស ឬ
    (iv) មិនលើសពីតម្លៃប្រៀបធៀបរបស់ក្រុមហ៊ុន សម្រាប់ការព្យាបាលសម្រាប់ការធ្វើរោគវិនិច្ឆ័យ ឬដំណើរការការព្យាបាលស្រដៀងគ្នា។
32. **អ្នកជំនាញ** សំដៅលើ វេជ្ជបណ្ឌិតជំនាញឯកទេស ឬអ្នកជំនាញផ្នែកទន្តសាស្ត្រ ដែលបានចុះបញ្ជីការ និងទទួលបានអាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈ តាមវេជ្ជសាស្ត្រលោកខាងលិចនៅក្នុងទីតាំងភូមិសាស្ត្រនៃការប្រកបវិជ្ជាជីវៈរបស់គាត់នៅក្នុងប្រទេសដែលការព្យាបាលនោះស្ថិតនៅ ហើយដែលត្រូវបានចាត់តាំងដោយអាជ្ញាធរផ្នែកសុខា ភិបាលសមស្របថាជាបុគ្គលដែលមានជំនាញខ្ពស់ និងឯកទេសជំនាញពិសេសក្នុងវិស័យវេជ្ជសាស្ត្រ ឬទន្តសាស្ត្រណាមួយជាក់លាក់ ប៉ុន្តែមិនរាប់បញ្ចូលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ប្តី ឬប្រពន្ធ ឬក្រុមគ្រួសាររបស់បុគ្គលទាំងនោះ។
33. **ជំងឺជាក់លាក់** សំដៅលើស្ថានភាពជំងឺ និងផលលំបាកដែលពាក់ព័ន្ធ៖
    (i) ជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម និងជំងឺប្រព័ន្ធសរសៃឈាមបេះដូង

(ii) ដុំសាច់ ជំងឺមហារីក ដុំគីស ដុំពក ដុំសាច់ដុះ គ្រួសក្នុងតម្រងនោម និងគ្រួសក្នុងប្រព័ន្ធថង់ទឹកប្រម៉ាត់ផ្សេងៗ
(iii) បញ្ហាផ្សេងៗនៃត្រចៀក ច្រមុះ និងបំពង់ក
(iv) ជំងឺក្លូន ឬសដូងបាត បូស ដុំទឹក រីកសរសៃវ៉ែន
(v) ជំងឺ Endometriosis រួមបញ្ចូលទាំងជំងឺប្រព័ន្ធបន្តពូជ
(vi) ជំងឺឆ្អឹងកងខ្នង និងឆ្អឹងខ្នង និងបញ្ហាជង្គង់។

34. **ការវះកាត់** សំដៅលើ ការព្យាបាលតាមបែបវេជ្ជសាស្ត្រណាមួយដូចលក្ខខណ្ឌខាងក្រោមនេះ៖
(v) ការវះ ឬកាត់យកចេញដោយប្រើកាំបិតវះកាត់ ឬដោយវិធី electrocautery ទៅលើសិរីរាង្គ ឬផ្នែកណាមួយនៃរូបរាងកាយ លើកលែងតែផ្នែកទន្តសាស្ត្រ
(vi) វិធីព្យាបាលដោយការវះកាត់ ការស្តារឡើងវិញនូវសរីរាង្គ ឬផ្នែកណាមួយនៃរាង្គកាយ តាមរយៈវិធី invasive technique
(vii) កាត់បន្ថយដោយកែសម្រួលការបាក់ឆ្អឹង ឬការថ្លោះគ្រេចឆ្អឹង ឬ
(viii) ការប្រើប្រាស់វិធី endoscopy ដើម្បីយកដុំគ្រួស ឬវត្ថុផ្សេងៗចេញពីបំពង់សម្លេង ទងសួត បំពង់ខ្យល់ បំពង់អាហារ ក្រពះពោះវៀន តម្រងនោម ឬបំពង់បង្ហូរនោម។

35. **ការព្យាបាល** សំដៅលើ ការវះកាត់ ដំណើរការផ្នែកវេជ្ជសាស្ត្រ ឬ ដំណើរការផ្សេងៗនៃផ្នែកវេជ្ជសាស្ត្រ ក្នុងគោលបំណងនៃការព្យាបាល ឬបន្ថយអាការៈ ក្នុងពេលវេលាដ៏សមហេតុផលមួយ នៃស្ថានភាពសុខភាពដែលមានលក្ខខណ្ឌគ្រប់គ្រាន់មួយ។

36. **រយៈពេលនៃការរងចាំ** សំដៅលើ រយៈពេលមួយដែលត្រូវបានកំណត់ជាចំនួននៃថ្ងៃ ឬខែ និងរាប់ចាប់ផ្តើមពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង និងក្នុងកំឡុងពេលដែលការព្យាបាលមិនត្រូវបានធានាក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ។

## II. កម្មវត្ថុនៃការធានា

ផលិតផលធានារ៉ាប់រងបន្ថែមនេះមានកម្មវត្ថុនៃការធានាលើរូបរាងកាយ (សុខភាព)។

## III. វិសាលភាពធានារ៉ាប់រង

### A. អត្ថប្រយោជន៍គោល

1. **អត្ថប្រយោជន៍លើតម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃ** ផ្តល់សំណងលើចំណាយសម្រាប់ថ្លៃស្នាក់នៅ រួមបញ្ចូលទាំង ថ្លៃអាហារ ខណៈពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងចូលសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យក្នុងនាមជាអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូនប្រចាំថ្ងៃ គឺរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញនៅលើតារាងអត្ថប្រយោជន៍។

   ប្រសិនបើ តម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃជាក់ស្តែង មានចំនួនលើសពីកម្រិតអតិបរមានៃតម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង នោះសមាជិកអ្នកត្រូវបានធានារ៉ាប់រងនឹងត្រូវបង់ចំនួនដែលខុសគ្នារវាងតម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃជាក់ស្តែង និងកម្រិតអតិបរមាប្រចាំថ្ងៃ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ សម្រាប់រយៈពេលស្នាក់នៅក្នុងមន្ទីរពេទ្យ។

2. **អត្ថប្រយោជន៍លើការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ** ក្នុងករណីដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវចូលសម្រាកនៅក្នុងសាល ឬបន្ទប់មន្ទីរពេទ្យមួយ ក្រុមហ៊ុននឹងផ្តល់សំណងលើចំណាយផ្នែកវេជ្ជសាស្ត្រ ដែលមានភាពចាំបាច់ក្នុងការព្យាបាលជំងឺ ដូចជា៖

   (i) ថ្លៃសេវាវេជ្ជបណ្ឌិតវះកាត់ និងវេជ្ជបណ្ឌិតចាក់ថ្នាំសណ្តំ
   (ii) ថ្លៃបន្ទប់វះកាត់
   (iii) ថ្លៃបន្ទប់សង្គ្រោះបន្ទាន់ និងថ្លៃបន្ទប់ព្យាបាលផ្នែកពិសេសផ្សេងទៀតដែលស្រដៀងគ្នា
   (iv) ថ្លៃឱសថ សម្ភារៈរុំរបួស និងចំណាយលើសម្ភារៈប្រើប្រាស់ផ្សេងៗ
   (v) ថ្លៃវេជ្ជបណ្ឌិតទូទៅ និងអ្នកជំនាញមកពិនិត្យ រហូតដល់ 03 (បី) ដង ក្នុងមួយថ្ងៃ សម្រាប់វេជ្ជបណ្ឌិតទូទៅ ឬអ្នកជំនាញម្នាក់
   (vi) ការថែទាំមូលដ្ឋាន
   (vii) ថ្លៃសេវាការបណ្តុះសរីរាង្គ ឬការប្តូរសរីរាង្គ
   (viii) ថ្លៃធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានជំងឺ រួមបញ្ចូលទាំងការតេស្តពិសោធន៍នានា
   (ix) ថ្លៃធ្វើរោគវិនិច្ឆ័យដោយ ការថត អ៊ឺមអរអោយ (MRI) ឬស៊ីធីស្កែន (CT Scan) ឬភីអ៊ីធីស្កែន (PET Scan)
   (x) ថ្លៃសេវាសម្រាប់ការដាក់អបឆ្អឹងខ្នង ការដាក់រណបជង្គង់ ឬការដាក់ឧបករណ៍រណបដៃ ឬជើង ប្រសិនបើវាជាផ្នែកនៃដំណើរការវះកាត់ និងការព្យាបាល
   (xi) ថ្លៃសេវាព្យាបាលដោយចលនា ដែលផ្តល់ជូនដោយវេជ្ជបណ្ឌិតផ្នែកចលនាសាស្ត្រ ដែលមានអាជ្ញាបណ្ណ ខណៈពេលសម្រាកព្យាបាលក្នុងមន្ទីពេទ្យ
   (xii) ថ្លៃសេវាសម្រាប់ការលាងឈាម
   (xiii) ថ្លៃសេវាសម្រាប់ការព្យាបាលជំងឺមហារីក
   (xiv) ថ្លៃសេវាសម្រាប់ការព្យាបាល ដែលផ្តល់ជូនក្នុងគោលបំណងនៃបំបាត់រោគសញ្ញា នៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវបានវិនិច្ឆ័យថាមានជំងឺដំណាក់កាលចុងក្រោយ
   (xv) ថ្លៃឱសថតាមវេជ្ជបញ្ជាសម្រាប់យកទៅផ្ទះ រហូតដល់ 07 (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុញ្ញាតចេញពីមន្ទីរពេទ្យ និងជាផ្នែកនៃការព្យាបាលបន្តបន្ទាប់សម្រាប់ស្ថានភាពជំងឺដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានសម្រាកព្យាបាល។

   ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

3. **អត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីកដែលមិនសម្រាកក្នុងមន្ទីរពេទ្យ** ផ្តល់សំណងលើ ការព្យាបាលជំងឺដោយការចាក់គីមី និងការព្យាបាលដោយវិទ្យុសកម្ម សម្រាប់ជំងឺដែលបានធានា ខណៈពេលជាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូលទាំង ការប្រឹក្សាយោបល់ ឱសថ ការធ្វើតេស្តដើម្បីធ្វើរោគវិនិច្ឆ័យ សម្រាប់ និង កំឡុងធ្វើការព្យាបាលជំងឺមហារីកនេះ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

4. **អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការលាងឈាមដែលមិនសម្រាកក្នុងមន្ទីរពេទ្យ** ផ្តល់សំណងលើការព្យាបាលជំងឺដោយការលាងឈាម និងការប្រឹក្សាយោបល់ ខណៈពេលជាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

5. **អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការវះកាត់ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ** ផ្តល់សំណងលើថ្លៃសេវាប្រឹក្សាយោបល់ និងថ្លៃសេវានៃដំណើរការផ្សេងៗសម្រាប់ការព្យាបាលជំងឺដោយការវះកាត់ ខណៈពេលជាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ រួមបញ្ចូលទាំង ថ្លៃសេវាប្រឹក្សាយោបល់មុនពេលធ្វើការវះកាត់ និងក្រោយពេលធ្វើការវះកាត់ និងការពិនិត្យតាមដានជំងឺ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

6. **អត្ថប្រយោជន៍លើការព្យាបាលជំងឺមុន និងក្រោយពេលសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ** មុនពេលការចូលសម្រាកព្យាបាលជំងឺ និងបន្ទាប់ពីទទួលបានការអនុញ្ញាតចេញពីមន្ទីរពេទ្យ សមាជិកអ្នកត្រូវបានធានារ៉ាប់រងអាចតម្រូវឱ្យឆ្លងកាត់ការមកពិនិត្យមុនពេលចូលសម្រាកព្យាបាលជំងឺ ឬបន្ទាប់ពីទទួលបានការអនុញ្ញាតចេញពីមន្ទីរពេទ្យ ដើម្បីទទួលបានការតាមដានជំងឺដោយការប្រឹក្សាយោបល់ ឬការព្យាបាលជំងឺ។ ក្រុមហ៊ុននឹងផ្តល់សំណងលើ ចំណាយសេវាប្រឹក្សាយោបល់ ថ្លៃឱសថតាមវេជ្ជបញ្ជា ការធ្វើតេស្តដើម្បីធ្វើរោគវិនិច្ឆ័យ និងការត្រួតពិនិត្យរកជំងឺ ការព្យាបាលជំងឺដោយចលនា ការព្យាបាលជំងឺពុកឆ្អឹង និងការព្យាបាលបែប chiropractic ដែលទាំងនេះពាក់ព័ន្ធនឹងស្ថានភាពជំងឺដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ដែលលោកអ្នកបានសម្រាកព្យាបាល ហើយកើតឡើងក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃ មុនពេល និងបន្ទាប់ពីសមាជិកអ្នកត្រូវបានធានារ៉ាប់រងចូលសម្រាកក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូនទាំងអស់ សម្រាប់ការចូលសម្រាកក្នុងមន្ទីរពេទ្យ 1 ដង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

7. **អត្ថប្រយោជន៍លើរថយន្តគិលានសង្គ្រោះបន្ទាន់** ផ្តល់សំណងលើ ការដឹកជញ្ជូនដោយរថយន្តគិលានសង្គ្រោះបន្ទាន់ទៅកាន់ និងរវាងមន្ទីរពេទ្យ ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងត្រូវចូលសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យដោយសារករណីបន្ទាន់ណាមួយ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ការចូលសម្រាកក្នុងមន្ទីរពេទ្យក្នុង 1 ដង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

8. **អត្ថប្រយោជន៍លើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ** ផ្តល់សំណងលើ ថ្លៃសេវាប្រឹក្សាយោបល់ ការត្រួតពិនិត្យរកជំងឺ និងការព្យាបាល នៅក្នុងផ្នែកគ្រោះថ្នាក់ចៃដន្យ និងសង្គ្រោះបន្ទាន់ (ឬផ្នែកដែលប្រហាក់ប្រហែល) បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យ ដោយការព្យាបាលត្រូវកើតឡើងក្នុងកំឡុងពេល 72 (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យនោះ។ ចំណាយលើបង់រុំរបួស និងបង់រុំព្យួរ នឹងត្រូវបានធានាជូន ប៉ុន្តែចំណាយសម្រាប់ឧបករណ៍ដែលប្រើប្រាស់បានរយៈពេលយូរ និងឧបករណ៍ជំនួយផ្សេងទៀត មិនត្រូវបានធានានោះឡើយ។ អត្ថប្រយោជន៍នេះ រួមបញ្ចូលទាំង ការពិនិត្យតាមដានជំងឺ ក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃ បន្ទាប់ពីគ្រោះថ្នាក់ចៃដន្យនោះបានកើតឡើង។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

អត្ថប្រយោជន៍នេះ រួមបញ្ចូលទាំង ចំណាយលើការព្យាបាលធ្មេញកំណើតដែលខូចខាតបង្កឡើងពីគ្រោះថ្នាក់ ចៃដន្យ។ ក្រុមហ៊ុន នឹងផ្តល់សំណងលើ ថ្លៃសេវាប្រឹក្សាយោបល់ ការត្រួតពិនិត្យរកជំងឺ និងការព្យាបាល នៅក្នុងផ្នែកសង្គ្រោះបន្ទាន់ ដើម្បីរក្សាស្ថានភាព សម្អាតមុខរបួស ឬដកចេញនូវកម្ទេចធ្មេញណាមួយ។ ក្រុមហ៊ុន នឹងផ្តល់ការធានាលើការព្យាបាលធ្មេញ នៅពេលដែលមានការខូចខាតដែលប៉ះពាល់ផ្នែកខាងក្រៅនៃមាត់ ឬថ្គាម ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ ណាមួយខាងក្រោម៖

(i) ការជំនួសការស្រោបធ្មេញដែលមានតម្លៃសមហេតុផល

(ii) ការដាំបង្គោលធ្មេញដែលចាំបាច់តាមមូលហេតុវេជ្ជសាស្ត្រ (មិនមែនជាការកែសម្ផស្ស)

ក្រុមហ៊ុន នឹងផ្តល់សំណងលើថ្លៃព្យាបាល ប្រសិនបើ ការខូចខាតនោះបានជូនដំណឹងក្នុងកំឡុងពេល 07 (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីការខូចខាតបង្កឡើងពីគ្រោះថ្នាក់ចៃដន្យបានកើតឡើង និងការព្យាបាលនោះកើតឡើងក្នុង កំឡុងពេល 90 (កៅសិប) ថ្ងៃតែប៉ុណ្ណោះ។ ប៉ុន្តែ ថ្លៃព្យាបាលលើការខូចខាតបង្កឡើងពីមូលហេតុណាមួយខាងក្រោមនឹងមិនត្រូវបានធានាឡើយ៖

(i) ការសឹករិចរិលតាមធម្មជាតិ

(ii) ការបរិភោគ ឬទំពារ ចំណីដែលមានវត្ថុធាតុដែលពុំអាចបរិភោគបាន (foreign body)

(iii) ការប្រដាល់ ឬលេងកីឡាបាល់ឱបដោយមិនបានពាក់ឧបករណ៍ការពារមាត់ធ្មេញបានត្រឹមត្រូវ

(iv) ការដុសធ្មេញ ឬដំណើរការការរក្សាអនាម័យមាត់ធ្មេញណាមួយផ្សេងទៀត។

9. **អត្ថប្រយោជន៍លើសំណងបន្ទាប់បន្សំ** នឹងត្រូវបានផ្តល់ជូន ប្រសិនបើ សំណងដែលមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់អត្ថប្រយោជន៍លើតម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃ ឬអត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីកដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ត្រូវបានផ្តល់សំណងដោយបណ្ណសន្យារ៉ាប់រង ឬគម្រោងដទៃ។ សម្រាប់ការស្នាក់នៅមន្ទីរពេទ្យប្រចាំថ្ងៃ ឬការដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលជំងឺមហារីក ខណៈពេលជាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ ក្រុមហ៊ុននឹងទូទាត់សំណងជូនជាកញ្ចប់ទឹកប្រាក់ ដូចដែលបានបង្ហាញនៅលើតារាងអត្ថប្រយោជន៍។ អត្ថប្រយោជន៍នេះ នឹងផ្តល់ជូន រហូតដល់ 15 (ដប់ប្រាំ) ថ្ងៃ ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រងប៉ុណ្ណោះ។ នៅពេលដែលអត្ថប្រយោជន៍នេះត្រូវបានបង់ជូនរួច នោះនឹងពុំមានអត្ថប្រយោជន៍ដទៃទៀតអាចផ្តល់ជូនសម្រាប់ការព្យាបាលដូចគ្នានោះឡើយ។

**B. ជម្រើសអត្ថប្រយោជន៍បន្ថែម**

ម្ចាស់បណ្ណសន្យារ៉ាប់រង អាចទិញជម្រើសអត្ថប្រយោជន៍បន្ថែមមួយ ឬលើសពីនេះ សម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ជាការការពារបន្ថែមលើអត្ថប្រយោជន៍គោល។ សូមមើលតារាងអត្ថប្រយោជន៍របស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនីមួយៗ សម្រាប់ព័ត៌មានបន្ថែមអំពីជម្រើសអត្ថប្រយោជន៍បន្ថែម ដែលអនុវត្តចំពោះគម្រោងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង។

10. **ជម្រើសអត្ថប្រយោជន៍លើចំណាយរបស់អ្នកកំដរអ្នកជំងឺ** ផ្តល់ការការពារលើ ចំណាយថ្លៃស្នាក់នៅសម្រាប់អ្នកកំដរអ្នកជំងឺ ខណៈពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ក្នុង 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

11. **ជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ** ផ្តល់សំណងលើ ឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺដែលប្រើប្រាស់បានរយៈពេលយូរ រហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍ ដោយឧបករណ៍ទាំងនោះត្រូវមានលក្ខខណ្ឌគ្រប់គ្រាន់ដូចខាងក្រោម៖

    (i) ជាឧបករណ៍ដែលផ្តល់អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺដល់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដោយសារស្ថានភាពជំងឺ និង/ឬ ជំងឺជាក់លាក់ណាមួយ និង

    (ii) ជាឧបករណ៍ដែលចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិតជំនាញឯកទេស ដែលមានអាជ្ញាបណ្ណ និង

    (iii) ជាឧបករណ៍ដែលមិនត្រូវប្រើប្រាស់សម្រាប់ជាវត្ថុផ្តល់ទំនុកចិត្ត ឬជាការលួងលោមចិត្ត និង

    (iv) ជាឧបករណ៍ដែលមិនមានភាពចាំបាច់ក្នុងការប្រើប្រាស់តាមផ្នែកវេជ្ជសាស្ត្រ។

    ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

12. **ជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ** ផ្តល់សំណងលើ ចំណាយដែលកើតឡើងដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រងទៅលើសេវាប្រឹក្សាយោបល់ ការត្រួតពិនិត្យរកជំងឺ និងការចាក់ថ្នាំបង្ការ សម្រាប់គោលបំណងនៃការបង្ការជំងឺផ្សេងៗ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

13. **ជម្រើសអត្ថប្រយោជន៍លើការព្យាបាលជំងឺដែលមិនសម្រាកក្នុងមន្ទីរពេទ្យ** ផ្តល់សំណងលើ ថ្លៃសេវាប្រឹក្សាយោបល់ ថ្លៃចំណាយលើឱសថតាមវេជ្ជបញ្ជា សម្ភារៈរុំរបួស និងចំណាយលើការត្រួតពិនិត្យរកជំងឺ ដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានទទួល ខណៈពេលជាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូនសម្រាប់ការពិនិត្យក្នុង 1 ដង និងកម្រិតអតិបរមាសម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

14. **ជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញ** ផ្តល់សំណងលើ ចំណាយដែលកើតឡើងដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រងទៅលើសេវាប្រឹក្សាយោបល់ជាមួយទន្តពេទ្យ ការព្យាបាលដោយការដកធ្មេញ ការព្យាបាលដោយការប៉ះធ្មេញ ការព្យាបាលយកសរសៃធ្មេញ ការព្យាបាលអញ្ចាញធ្មេញ ការពិនិត្យសុខភាពមាត់ធ្មេញប្រចាំឆ្នាំ ការព្យាបាលដោយការស្រោបធ្មេញ ការស្រោបធ្មេញជាជួរ និងការពត់ធ្មេញ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

    ម្ចាស់បណ្ណសន្យារ៉ាប់រង អាចទិញជម្រើសអត្ថប្រយោជន៍បន្ថែមនេះបាន លុះត្រាតែម្ចាស់បណ្ណសន្យារ៉ាប់រងបានទិញជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ។

15. **ជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក** ផ្តល់សំណងលើ ចំណាយដែលកើតឡើងដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រងទៅលើកញ្ចក់វ៉ែនតាមីញ៉ូប ដងវ៉ែនតា និងខនជែកលែនស៍មីញ៉ូប (corrective contact lenses) លើកលែងវ៉ែនតាការពារកម្ដៅថ្ងៃ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូនសម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

ម្ចាស់បណ្ណសន្យារ៉ាប់រង អាចទិញជម្រើសអត្ថប្រយោជន៍បន្ថែមនេះបាន លុះត្រាតែគាត់បានទិញជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ។

16. **ជម្រើសអត្ថប្រយោជន៍លើការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ** ផ្តល់សំណងលើ ចំណាយសម្រាប់ថ្លៃស្នាក់នៅ សេវាថែទាំ និងសេវាគិលានុបដ្ឋាយិកា ដែលផ្តល់ជូនដោយមន្ទីរសុខភាពដែលមានអាជ្ញាបណ្ណ ទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងដែលជាអ្នកជំងឺដំណាក់កាលចុងក្រោយ ដោយសារគ្រោះថ្នាក់ចៃដន្យ ឬជំងឺដែលត្រូវបានធានា។ អ្នកជំងឺដំណាក់កាលចុងក្រោយ សំដៅលើ ស្ថានភាពជំងឺដែលវេជ្ជបណ្ឌិតជំនាញឯកទេសដែលមានអាជ្ញាបណ្ណវាយតម្លៃថា សមាជិកអ្នកត្រូវបានធានារ៉ាប់រងនឹងទទួលមរណភាពក្នុងកំឡុងពេល 12 (ដប់ពីរ) ខែ ឬតិចជាងនេះ។ ការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ ត្រូវចេញវេជ្ជបញ្ជា និងបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញឯកទេសដែលបានចុះបញ្ជីត្រឹមត្រូវ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

17. **ជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្ត** ផ្តល់សំណងលើ ចំណាយនៃអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់ការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងមន្ទីរពេទ្យផ្នែកវិកលចរិត ឬសុខភាពផ្លូវចិត្ត ផ្នែក ឬនាយកដ្ឋានខាងផ្នែកវិកលចរិត ឬសុខភាពផ្លូវចិត្តនៃមន្ទីរពេទ្យ ឬសម្រាប់ការថែទាំ ឬការព្យាបាលជំងឺវិកលចរិត ឬផ្លូវចិត្ត ដែលណែនាំដោយអ្នកជំនាញខាងផ្នែកជំងឺវិកលចរិត និងចំណាយនៃអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យទៅលើការធ្វើតេស្ត និងសេវាប្រឹក្សាយោបល់ជាមួយនឹងវេជ្ជបណ្ឌិតខាងផ្នែកជំងឺវិកលចរិត ឬវេជ្ជបណ្ឌិតខាងផ្នែកចិត្តសាស្រ្ត ដែលកើតឡើង 90 (កៅសិប) ថ្ងៃ មុនពេលចូលសម្រាកក្នុងមន្ទីរពេទ្យ និង 90 (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលការអនុញ្ញាតចេញពីមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិតអតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

18. **ជម្រើសអត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន** ផ្តល់សំណងលើចំណាយសម្រាប់ថ្លៃសេវាបន្ទប់ប្រចាំថ្ងៃ ថ្លៃសេវាវេជ្ជបណ្ឌិតវះកាត់ និងវេជ្ជបណ្ឌិតចាក់ថ្នាំសណ្តំ ថ្លៃវេជ្ជបណ្ឌិតទូទៅមកពិនិត្យ ថ្លៃបន្ទប់វះកាត់ ថ្លៃសេវាគិលានុបដ្ឋាយិកា និងគ្រូពេទ្យឆ្មប ថ្លៃសេវាថែទាំ និងថ្នាំបង្ការសម្រាប់ទារកទើបនឹងកើត ដែលកើតឡើងក្នុងមន្ទីរពេទ្យ។ ចំនួនអត្ថប្រយោជន៍ដែលអាចផ្តល់ជូន សម្រាប់ 1 ឆ្នាំនៃបណ្ណសន្យារ៉ាប់រង គឺមានរហូតដល់កម្រិត អតិបរមាដែលបានបង្ហាញលើតារាងអត្ថប្រយោជន៍។

គូភាគីរក្សាសិទ្ធិក្នុងការបន្ថែមអត្ថប្រយោជន៍ផ្សេងៗទៅលើ អត្ថប្រយោជន៍គោល និង ជម្រើសអត្ថប្រយោជន៍បន្ថែមតាមការព្រមព្រៀងគ្នា។

## IV. អត្ថប្រយោជន៍ធានារ៉ាប់រង

អត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រងនេះ រួមមាន៖

| លរ. | ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | ទឹកប្រាក់ធានារ៉ាប់រង |
|---|---|---|
| | **អត្ថប្រយោជន៍គោល** | |

| | | |
|---|---|---|
| 1. | អត្ថប្រយោជន៍លើតម្លៃសេវាបន្ទប់ គ្រែ និង អាហារប្រចាំថ្ងៃ | រហូតដល់កម្រិតអតិបរមាប្រចាំថ្ងៃ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 2. | អត្ថប្រយោជន៍លើការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 3. | អត្ថប្រយោជន៍លើការព្យាបាលជំងឺមហារីក ដែលមិន សម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 4. | អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការលាងឈាម ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 5. | អត្ថប្រយោជន៍លើការព្យាបាលជំងឺដោយការវះកាត់ ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 6. | អត្ថប្រយោជន៍លើការព្យាបាលជំងឺមុន និង ក្រោយពេលសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមា សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យក្នុង 1 ដង ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 7. | អត្ថប្រយោជន៍លើរថយន្តគិលានសង្គ្រោះបន្ទាន់ | រហូតដល់កម្រិតអតិបរមា សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យក្នុង 1 ដង ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 8. | អត្ថប្រយោជន៍លើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ថៃជន្យ | រហូតដល់កម្រិតអតិបរមា សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យក្នុង 1 ដង ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 9. | អត្ថប្រយោជន៍លើសំណងបន្ទាប់បន្សំ | រហូតដល់កម្រិតអតិបរមាប្រចាំថ្ងៃ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| | **ជម្រើសអត្ថប្រយោជន៍បន្ថែម** | |
| 10. | ជម្រើសអត្ថប្រយោជន៍លើចំណាយរបស់អ្នកកំដរអ្នកជំងឺ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 11. | ជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 12. | ជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺ ផ្សេងៗ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 13. | ជម្រើសអត្ថប្រយោជន៍លើការព្យាបាលជំងឺដែលមិនសម្រាកក្នុងមន្ទីរពេទ្យ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 14. | ជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |

| | | |
|---|---|---|
| 15. | ជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 16. | ជម្រើសអត្ថប្រយោជន៍លើការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 17. | ជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្ត | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |
| 18. | ជម្រើសអត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន | រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំ ដែលបានកំណត់លើតារាងអត្ថប្រយោជន៍ |

## V. ការបង់បុព្វលាភធានារ៉ាប់រង

1. ម្ចាស់បណ្ណសន្យារ៉ាប់រងអាចបង់បុព្វលាភធានារ៉ាប់រង តាមមធ្យោបាយផ្សេងៗដែលបានកំណត់ដោយក្រុមហ៊ុន។ លិខិតតម្កល់ប្រាក់ដែលមានសុពលភាព ឬការកាត់បុព្វលាភធានារ៉ាប់រងចេញពីគណនីដែលបង្ហាញក្នុងរបាយការណ៍គណនីរបស់អ្នកត្រូវបានចាត់ទុកថាជាភស្តុតាងនៃការបានបង់ប្រាក់រួច។
2. ចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែម ត្រូវដូចជាមួយនឹងចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងមូលដ្ឋានជានិច្ច។ ចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងរបស់ផលិតផលធានារ៉ាប់រងបន្ថែមនឹងត្រូវផ្លាស់ប្តូរ ប្រសិនបើចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងរបស់ ផលិតផលធានារ៉ាប់រងមូលដ្ឋានត្រូវបានផ្លាស់ប្តូរដោយម្ចាស់បណ្ណសន្យារ៉ាប់រង។
3. ក្រុមហ៊ុនមានសិទ្ធិផ្លាស់ប្តូរអត្រាបុព្វលាភធានារ៉ាប់រងដែលនឹងត្រូវបានគណនា (ក) នៅខួបនៃបណ្ណសន្យារ៉ាប់រងណាមួយ ឬ (ខ) នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងណាមួយ ក្នុងករណីដែលអត្រាបុព្វលាភធានារ៉ាប់រងត្រូវបានគិតនៅពេលនោះមានសុពលភាពយ៉ាងហោចណាស់ 12 (ដប់ពីរ) ខែ ឬ (គ) នៅពេលដែលហានិភ័យដែលបានធានាក្រោមបណ្ណសន្យារ៉ាប់រងនេះ បានកើនឡើង ឬ (ឃ) នៅពេលមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះសមាជិកភាព ដែលប៉ះពាល់ដល់បុព្វលាភធានារ៉ាប់រង ហើយដែលក្រុមហ៊ុនបានជូនដំណឹងដល់អ្នក យ៉ាងហោចណាស់ 30 (សាមសិប) ថ្ងៃ មុនដល់កាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង។

   ការកែសម្រួលបុព្វលាភធានារ៉ាប់រង ដែលពាក់ព័ន្ធជាមួយនឹងការប្រគល់បុព្វលាភធានារ៉ាប់រងដែលមិនទាន់ទទួលស្គាល់ជាចំណូលរបស់ក្រុមហ៊ុន ទៅម្ចាស់បណ្ណសន្យារ៉ាប់រង នឹងត្រូវបានកំណត់ត្រឹមរយៈពេលចាប់ផ្តើមខួបនៃ បណ្ណសន្យារ៉ាប់រងចុងក្រោយ ដែលមានមុនកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានភស្តុតាង ដែលបញ្ជាក់ថាត្រូវមានការកែសម្រួលនេះ។
4. ខ និងលក្ខខណ្ឌនានាដែលពាក់ព័ន្ធនឹងការបង់បុព្វលាភធានារ៉ាប់រង ត្រូវអនុលោមតាមផលិតផលធានារ៉ាប់រងមូលដ្ឋាន។

## VI. ករណីមិនធានា

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើ៖

1. ការវះកាត់ និងការព្យាបាលកែសម្ផស្ស ឬការព្យាបាលដើម្បីកែលម្អរូបរាង ការព្យាបាលដើម្បីជម្រុះរោម ឬសក់ ឬបណ្តុះសក់ ការផ្លាស់ប្តូរពណ៌ស្បែក ឬពណ៌ភ្នែក លើកលែងការវះកាត់កែសម្រួលមុខងារប្រើប្រាស់បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យ ឬការព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ឬ

2. ការព្យាបាលដែលចាំបាច់ដែលបណ្តាលមកពីផលប៉ះពាល់នៃផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារជាតុគីមី ដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង អាចចូលរួមក្នុងទំនាស់ សង្គ្រាម សកម្មភាពរបស់សត្រូវបរទេស ការឈ្លានពាន សង្គ្រាមស៊ីវិល បាតុកម្ម ការបះបោរ កុបកម្ម បដិវត្តន៍ ការផ្តួលរលំរដ្ឋាភិបាលស្របច្បាប់ ការផ្ទុះអាវុធនៃសង្គ្រាម ឬព្រឹត្តិការណ៍ណាមួយដែលប្រហាក់ប្រហែលនឹងព្រឹត្តិការណ៍ដែលបានរៀបរាប់នេះ។ ទាំងនេះរាប់បញ្ចូលទាំងការព្យាបាលទាំងឡាយ ដែលបណ្តាលមកពីការប្រឈមខ្លួនទៅនឹងហានិភ័យរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដូចជា ការទៅកាន់កន្លែងដែលមានចលាចលសង្គម មិនថាក្នុងនាមជាអ្នកឃ្លាំមើល ឬអ្នកទស្សនាក៏ដោយ។ សូមបញ្ជាក់ផងដែរថា ការធានានឹងផ្តល់ជូនសម្រាប់ការព្យាបាលចាំបាច់ដែលបណ្តាលមកពីសកម្មភាពភេរវកម្ម ក្នុងករណីដែលសកម្មភាពនេះ មិនបានបណ្តាលមកពីផលប៉ះពាល់ផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារជាតុគីមី ឬ

3. ការព្យាបាលដែលបណ្តាលមកពីការចូលរួមនៅក្នុងសកម្មភាពកងទ័ព ឬសកម្មភាពកីឡាជាអាជីព ឬ

4. ការប្រើប្រាស់ឱសថដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាព ឬឱសថដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ នេះមានន័យថា ឱសថទាំងនោះត្រូវទទួលបានអាជ្ញាប័ណ្ណដោយភ្នាក់ងារឱសថ អឺរ៉ុប (the European Medicines Agency) ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាល នៅក្នុងសហភាពអឺរ៉ុប ឬពីរដ្ឋបាលផ្នែកឱសថ និងចំណីអាហារនៃសហរដ្ឋអាមេរិក (the US Food and Drug Administration (FDA)) ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅកន្លែងផ្សេងទៀតនៅក្នុងសកលលោក ហើយឱសថនោះត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនោះតែប៉ុណ្ណោះ ឬ

5. ការព្យាបាលដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាព ឬការព្យាបាលដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ សម្រាប់ការព្យាបាលដែលមានការទទួលស្គាល់នេះ មានន័យថា ជាវិធីសាស្ត្រ និងការអនុវត្តនានា ដែលបានឆ្លងកាត់ការសាកល្បង និងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រយ៉ាងត្រឹមត្រូវ និងត្រូវបានផ្តល់ភស្តុតាងយ៉ាងគ្រប់គ្រាន់នៅក្នុងសៀវភៅវេជ្ជសាស្ត្រដែលបានបោះផ្សាយ សម្រាប់គោលដៅជាក់លាក់មួយ ដើម្បីចាត់ទុកថាជាការបង្ហាញពីការព្យាបាលយ៉ាងមានសុវត្ថិភាព និងប្រសិទ្ធភាព ឬ

6. ការព្យាបាលឱ្យមានកូន ការពន្យារកំណើត ឬការបង្អាក់កំណើត ឬគ្រាវ ឬការព្យាបាលក្នុងការពន្យារកំណើត ការកែភេទ អសមត្ថភាពផ្លូវភេទ ឬ

7. ការព្យាបាលដោយបុគ្គលដែលមិនមែនជាគ្រូពេទ្យ ឬគ្រូពេទ្យដែលមិនមានអាជ្ញាបណ្ណវិជ្ជាជីវៈត្រឹមត្រូវ ឬ

8. ការវះកាត់ព្យាបាលគភ៌ ឬទារកនៅក្នុងផ្ទៃ ឬ

9. ចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV) និង/ឬ ជំងឺដែលពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV) ដោយរាប់បញ្ចូលទាំងជំងឺអេដស៍ ឬរោគសញ្ញារបស់ជំងឺអេដស៍ និង/ឬ រោគសញ្ញានានាដែលបំប្លែងពីរោគសញ្ញានៃជំងឺអេដស៍នេះ ដែលកើតឡើងក្នុងកំឡុងពេលមួយឆ្នាំដំបូង រាប់ចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងឬ

10. ចំណាយដែលមិនមែនសម្រាប់ការព្យាបាលជំងឺ ដូចជា ថ្លៃសេវាទូរស័ព្ទ ការជួលទូរទស្សន៍ សារព័ត៌មាន ផលិត ផល ផ្តល់សំណើមស្បែក គ្រីម គ្រឿងប្រដាប់សម្រាប់ងូតទឹក អាហារបំប៉ន និងវីតាមីន ថ្នាំដុសធ្មេញ ឬសាប៊ូ ឬ

11. ចំណាយដែលមិនប្រក្រតី មិនសមហេតុផល ក្នុងតំបន់ដែលទទួលការព្យាបាល ឬ

12. ការព្យាបាលប្រឆាំងនឹងភាពជាត់ រួមមានដោយមិនកំណត់ត្រឹម ការចង ឬការវះកាត់ទាក់ទងនឹងក្រពះ ការយកចេញនូវកោសិកា និងខ្លាញ់ដែលលើស ឬ

13. ការព្យាបាលដែលមិនមានភាពចាំបាច់ក្នុងការព្យាបាល ឬ

14. ការព្យាបាលដែលជាជម្មតាមិនសម្រាកនៅក្នុងមន្ទីរពេទ្យ ដោយរួមបញ្ចូលទាំងឱសថ និងការរុំរបួស ការប្រឹក្សាយោបល់ និងការពិនិត្យតាមដានជំងឺ បូករួមទាំងការពិនិត្យកំឡុងពេល និងក្រោយពេលមានផ្ទៃពោះ លើកលែងតែការព្យាបាលដែលមិនសម្រាកនៅក្នុងមន្ទីរពេទ្យដែលត្រូវបានអនុញ្ញាត ហើយមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ក្រុមហ៊ុននឹងបង់ជូននូវអត្ថប្រយោជន៍ ដែលរាប់បញ្ចូលទាំងឱសថ ការរុំរបួស ការប្រឹក្សាយោបល់ និងការពិនិត្យតាមដានជំងឺ រហូតដល់កម្រិតអតិបរមាដែលបានកំណត់ក្រោមជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ឬ

15. ការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗ ការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានជំងឺក្នុងដំណាក់កាលដំបូងនៃជំងឺដែលគ្មានរោគសញ្ញា យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ ក្រុមហ៊ុននឹងបង់ជូនការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗនោះ រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ ឬ

16. ការចាក់ថ្នាំបង្ការ ក្រៅពីការចាក់ថ្នាំបង្ការដំបូងសម្រាប់ទារកទើបនឹងកើត ដែលត្រូវបានធានានៅក្រោមអត្ថប្រយោជន៍ពេលសម្រាលកូន ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន ឬ

17. ការព្យាបាលជំងឺផ្លូវចិត្ត ទោះបីជាតម្រូវឱ្យចូលសម្រាកក្នុងមន្ទីរពេទ្យក៏ដោយ ដោយឡែក ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្ត ក្រុមហ៊ុននឹងបង់ជូនចំណាយលើការថែទាំជំងឺផ្លូវចិត្ត រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្ត ឬ

18. ការថែរក្សាសុខភាពមាត់ធ្មេញ និងអញ្ចាញ (ឬប្រហាក់ប្រហែល) យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញ ក្រុមហ៊ុននឹងបង់ជូនចំណាយលើសុខភាពមាត់ធ្មេញ និងអញ្ចាញ រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញ ឬ

19. ការព្យាបាលភ្នែក ឬចក្ខុវិញ្ញាណ យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក ក្រុមហ៊ុននឹងបង់ជូនចំណាយលើការថែទាំភ្នែក រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក ឬ

20. ចំណាយសេវាវេជ្ជសាស្ត្រ ដែលកើតឡើងក្នុងរយៈពេលនៃការរងចាំ លើកលែងតែចំណាយសេវាវេជ្ជសាស្ត្រ ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងក្នុងរយៈពេលនៃការរងចាំ ដោយអនុលោមទៅតាមករណីមិនជានាដទៃទៀត ឬ
21. ការជំនួសសរីរាង្គខាងក្រៅ (ឧបករណ៍សិប្បនិម្មិត) និងឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ និងឧបករណ៍ពាក់ព័ន្ធនានា ក្រៅពីឧបករណ៍ទាំងឡាយណាដែលជាផ្នែកនៃការវះកាត់ ឬរួមបញ្ចូលក្នុងការព្យាបាល យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ ក្រុមហ៊ុននឹងបង់ជូនចំណាយលើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ ឬ
22. ចំណាយលើការទទួលសរីរាង្គ ឬជាលិកាពីការបរិច្ចាគ ឬចំណាយរដ្ឋបាលដែលពាក់ព័ន្ធណាមួយ (ដូចជា ចំណាយលើការស្វែងរកការបរិច្ចាគ) ឬ
23. ចំណាយបន្ថែមសម្រាប់ការទទួលបានរបាយការណ៍ពេទ្យ ឬការដាក់ពាក្យស្នើសុំទាមទារសំណង ឬចំណាយរដ្ឋ បាលផ្សេង ៗ ទៀត ឬ
24. ការព្យាបាលការញៀន (ដូចជា ការញៀនគ្រឿងស្រវឹង សារជាតុ ឬថ្នាំញៀន) ឬការប្រើប្រាស់សារជាតុញៀននានាលើសចំណុះ (ដូចជា ការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការប្រើប្រាស់សារជាតុ ឬថ្នាំញៀនលើសចំណុះ) ឬតម្រូវការព្យាបាលព្យាបាលជំងឺ ឬរបួសនានា ដែលបង្កឡើងពីការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការញៀនមិនថាដោយផ្ទាល់ ឬដោយប្រយោលឡើយ។

## VII. ទីតាំងភូមិសាស្ត្រនៃការធានា

បណ្ណសន្យារ៉ាប់រងនេះ ផ្តល់ជម្រើសលើទីតាំងភូមិសាស្ត្រនៃការជានា 04 (បួន) ជម្រើស សម្រាប់អត្ថប្រយោជន៍ទូទះ

1. តំបន់ទី 1៖ ប្រទេសកម្ពុជា ថៃ វៀតណាម ភូមា ឡាវ និងម៉ាឡេស៊ី
2. តំបន់ទី 2៖ ទូទាំងទ្វីបអាស៊ី
3. តំបន់ទី 3៖ ទូទាំងពិភពលោក លើកលែង សហរដ្ឋអាមេរិក
4. តំបន់ទី 4៖ ទូទាំងពិភពលោក

សម្រាប់ករណីសង្គ្រោះបន្ទាន់ បណ្ណសន្យារ៉ាប់រងនេះនឹងផ្តល់ការការពារជូនទូទាំងពិភពលោក។

ទីតាំងភូមិសាស្ត្រនៃការជានា អនុវត្តសម្រាប់ការការពាររបស់សមាជិកជានារ៉ាប់រងនីមួយៗ ត្រូវបានកំណត់នៅលើតារាងអត្ថប្រយោជន៍។

ម្ចាស់បណ្ណសន្យារ៉ាប់រង អាចផ្លាស់ប្តូរទីតាំងភូមិសាស្ត្រនៃការជានានៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រង ដោយផ្ញើជូនក្រុមហ៊ុននូវលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ។

## VIII. លក្ខណៈសម្បត្តិរបស់អ្នកទទួលផល

5. អ្នកទទួលផលនៃផលិតផលជានារ៉ាប់រងបន្ថែមនេះ គឺជាសមាជិកអ្នកត្រូវបានជានារ៉ាប់រង។

6. សមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗ ត្រូវកំណត់បុគ្គលជាអ្នកទទួលផលជាលាយលក្ខណ៍អក្សរ ដែលនឹងទទួលបានអត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ ក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយការកំណត់នេះ ត្រូវរក្សាទុកជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង។
7. ក្នុងករណីនៅពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ហើយពុំមានអ្នកទទួលផលណាម្នាក់ត្រូវបានតែងតាំង ឬអ្នកទទួលផលនោះបានទទួលមរណភាព ទឹកប្រាក់ទាំងនោះអាចនឹងត្រូវបង់ជូនសាច់ញាតិរបស់អ្នកទទួលផលនោះ។ ករណីនេះ នឹងត្រូវអនុវត្តតាមច្បាប់ជាធរមាននាពេលនោះ។
8. ក្នុងកំឡុងពេលនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង គាត់មានសិទ្ធិផ្លាស់ប្តូរអ្នកទទួលផលដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង។ ការផ្លាស់ប្តូរបែបនេះ នឹងចាប់ផ្តើមមាន សុពលភាពនៅពេលម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួលសេចក្តីជូនដំណឹង។

## IX. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើគូភាគីណាមួយ មានបំណងចង់ធ្វើការកែប្រែអត្ថប្រយោជន៍ណាមួយ ឬ ខ និងលក្ខខណ្ឌណាមួយ ដែលមានក្នុងផលិតផលធានារ៉ាប់រងបន្ថែមនេះ ការកែប្រែនោះ ត្រូវធ្វើឡើងដោយការយល់ព្រមរបស់គូភាគីតាមរយៈបដិលេខ។ រាល់បដិលេខទាំងអស់នៃផលិតផលធានារ៉ាប់រងបន្ថែមនេះ នឹងត្រូវចងភ្ជាប់ជាមួយគ្រប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង មុន ឬនៅ ឬក្រោយកាលបរិច្ឆេទនៃសុពលភាពរបស់បដិលេខ។ បដិលេខនេះត្រូវចុះហត្ថលេខាដោយបុគ្គលដែលក្រុមហ៊ុនបានផ្តល់សិទ្ធិ។

## X. ការបន្តកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះត្រូវបានធ្វើឡើងដោយមានរយៈពេលសុពលភាពមួយឆ្នាំ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបន្តសុពលភាពជាថ្មីនៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ តាមការកំណត់បុព្វលាភធានារ៉ាប់រងដោយក្រុមហ៊ុន ប្រសិនបើ ក្រុមហ៊ុនចេញបង្កាន់ដៃជាផ្លូវការទទួលបានការបង់បុព្វលាភធានារ៉ាប់រងពីម្ចាស់បណ្ណសន្យារ៉ាប់រង នៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រង។ ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការកែប្រែ ឬកែតម្រូវអត្រាបុព្វលាភធានារ៉ាប់រង ខ និងលក្ខខណ្ឌ នៅពេលដល់ខួបនៃបណ្ណសន្យារ៉ាប់រងណាមួយ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនពេលជូនម្ចាស់បណ្ណសន្យារ៉ាប់រង។

## XI. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

ផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិនៅពេល៖

(i) ផលិតផលធានារ៉ាប់រងបន្ថែមនេះ ដល់កាលបរិច្ឆេទផុតកំណត់ ត្រូវបានបញ្ចប់ ឬអស់សុពលភាព ឬ

(ii) បណ្ណសន្យារ៉ាប់រងមូលដ្ឋាន ដល់កាលបរិច្ឆេទផុតកំណត់ ត្រូវបានបញ្ចប់ អស់សុពលភាព ឬត្រូវបានបោះបង់

ដោយយកករណីណាមួយដែលកើតឡើងមុនគេ។

ម្ចាស់បណ្ណសន្យារ៉ាប់រងអាចធ្វើការស្នើសុំដើម្បីបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ក្នុងពេលណាមួយក៏បាន ដោយសរសេរជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុន (នៅក្នុងទម្រង់ដែលក្រុមហ៊ុនបានកំណត់ជូន)។ ប្រសិនបើ ម្ចាស់បណ្ណសន្យារ៉ាប់រងស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង នៅកាលបរិច្ឆេទផ្សេងពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង នោះនឹងមិនមានការបង្វិលបុព្វលាភធានារ៉ាប់រងសងវិញត្រូវបានអនុវត្តឡើយ។ ការបញ្ចប់បណ្ណសន្យារ៉ាប់រងត្រូវធ្វើឡើង ដោយមិនត្រូវប៉ះពាល់ដល់ការទាមទារសំណងណាមួយ ដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ។

ការទូទាត់ ឬការទទួលយកបុព្វលាភធានារ៉ាប់រងណាមួយបន្ទាប់ពីការបញ្ចប់ផលិតផលធានារ៉ាប់រងបន្ថែមនេះ នឹងមិនបង្កើតជាទំនួលខុសត្រូវណាមួយរបស់ក្រុមហ៊ុនឡើយ ប៉ុន្តែ ក្រុមហ៊ុននឹងបង់បុព្វលាភធានារ៉ាប់រងនេះជូនវិញដោយពុំមានផ្តល់ជូនការប្រាក់។

## XII. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការលុបចោលផលិតផលធានារ៉ាប់រងបន្ថែមនេះ នៅកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រងណាមួយតាមរយៈ ការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការលុបចោល ទៅកាន់ម្ចាស់បណ្ណសន្យារ៉ាប់រងមុនកាលបរិច្ឆេទផុតកំណត់។ ការលុបចោលបណ្ណសន្យារ៉ាប់រងត្រូវធ្វើឡើង ដោយមិនត្រូវប៉ះពាល់ដល់ការទាមទារសំណងណាមួយដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការលុបចោលផលិតផលធានារ៉ាប់រងបន្ថែមនេះឡើយ។

ការទូទាត់ ឬការទទួលយកបុព្វលាភធានារ៉ាប់រងណាមួយបន្ទាប់ពីការលុបចោលផលិតផលធានារ៉ាប់រងបន្ថែមនេះ នឹងមិនបង្កើតជាទំនួលខុសត្រូវរបស់ក្រុមហ៊ុនឡើយ ប៉ុន្តែក្រុមហ៊ុននឹងបង្វិលបុព្វលាភធានារ៉ាប់រងនេះត្រលប់ជូនវិញដោយពុំមានការប្រាក់។

## XIII. ការទាមទារសំណង

### 1. ការស្នើសុំការអនុញ្ញាតជាមុន

ការស្នើសុំការអនុញ្ញាតជាមុន ជានីតិវិធីដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងតម្រូវឱ្យទទួលការអនុញ្ញាតជាមុនពីក្រុមហ៊ុន មុនពេលទទួលការព្យាបាលសម្រាប់ដំណើរការសេវាវេជ្ជសាស្ត្រជាក់លាក់ណាមួយ ដូចដែលបានបញ្ជាក់នៅលើតារាងអត្ថប្រយោជន៍។ ប្រសិនបើ មិនទាន់បានការទទួលអនុញ្ញាតជាមុន មុនពេលមានដំណើរការផ្នែកវេជ្ជសាស្ត្រ ឬការព្យាបាល ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការត្រួតពិនិត្យមើលលក្ខខណ្ឌគ្រប់គ្រាន់នៃសំណងនោះឡើងវិញ។

សមាជិកអ្នកត្រូវបានធានារ៉ាប់រង ត្រូវដាក់ទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតជាមុនដែលពេញលេញមកកាន់ក្រុមហ៊ុន យ៉ាងហោចណាស់ 5 (ប្រាំ) ថ្ងៃធ្វើការ មុនធ្វើការណាត់ជួបទទួលដំណើរការសេវាវេជ្ជសាស្ត្រ ឬការព្យាបាលនោះ។ ក្រុមហ៊ុន នឹងត្រួតពិនិត្យ ហើយឆ្លើយតបទៅកាន់សមាជិកអ្នកត្រូវបានធានារ៉ាប់រងវិញ ជាលាយលក្ខណ៍អក្សរមុនការចាប់ផ្តើមនៃការព្យាបាលដែលបានស្នើសុំ។

ការទទួលបានការអនុញ្ញាតជាមុន មិនត្រូវបានធានាថាអាចទទួលបានសំណងពេញលេញនោះឡើយ ដោយការចូលរួមចំណែកនៃចំណាយ និងកម្រិតអតិបរមាប្រចាំឆ្នាំអាចត្រូវបានអនុវត្ត។

អត្ថប្រយោជន៍ដែលអាចផ្តល់ជូនក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវអនុលោមតាមសិទ្ធនៃការទទួលបាន ខណៈពេលដែលចំណាយនោះបានកើតឡើងជាក់ស្តែង ហើយត្រូវអនុលោមតាមខសន្យា កម្រិតអតិបរមា និងករណីមិនធានានៃផលិតផលធានារ៉ាប់រងបន្ថែមនេះ។

### 2. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង

អ្នកដាក់ពាក្យស្នើសុំទាមទារសំណងអាចជា សមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល ម្នាក់ ឬច្រើននាក់ (ក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាព)។ អ្នកទាមទារសំណងត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។

3. **និតិវិធីនៃការផ្តល់ព័ត៌មាន**

(i) សេចក្តីជូនដំណឹងអំពីការទាមទារសំណង ត្រូវប្រគល់ជូនក្រុមហ៊ុនក្នុងរយៈពេល 90 (កៅសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលព្រឹត្តិការណ៍ណាមួយបានកើតឡើង ដែលបង្កឱ្យមានការទាមទារសំណងក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ។ ប្រសិនបើ អ្នកទាមទារសំណងខកខានក្នុងការជូនដំណឹង 90 (កៅសិប) ថ្ងៃ ក្រុមហ៊ុននឹងមិនបដិសេធការទាមទារណាមួយឡើយ ប្រសិនបើ ក្រុមហ៊ុនត្រូវបានបង្ហាញថាអ្នកទាមទារសំណងពុំមានលទ្ធភាពក្នុងការផ្តល់សេចក្តីជូនដំណឹង តាមដែលអាចធ្វើបាន ហើយអ្នកទាមទារសំណងបានព្យាយាមធ្វើការជូនដំណឹងនេះលឿនបំផុតតាមដែលអាចធ្វើបាន។

(ii) អ្នកអាចជូនដំណឹងអំពីការទាមទារសំណងដោយផ្ទាល់នៅទីស្នាក់ការរបស់ក្រុមហ៊ុន ឬជូនដំណឹងទៅកាន់ការិយាល័យសេវាបម្រើអតិថិជនតាមរយៈលេខទូរស័ព្ទ (855) 86 999 242 ឬទំនាក់ទំនងទៅកាន់ទីប្រឹក្សាផែនការជីវិតរបស់អ្នក ឬអ៊ីមែលមកកាន់ Kh.claim@aia.com.។

(iii) ឯកសារភស្តុតាង រួមបញ្ចូលតែមិនកំណត់ត្រឹម វិក្កយបត្រច្បាប់ដើម វិញ្ញាបនបត្រវេជ្ជសាស្ត្រ លិខិតអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យ និងរបាយការណ៍វេជ្ជសាស្ត្រណាមួយ ត្រូវដាក់មកជាមួយទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន។ រាល់ឯកសារវេជ្ជសាស្ត្រទាំងអស់ ត្រូវទទួលស្គាល់ពីមន្ទីរវេជ្ជសាស្ត្រដែលមានអាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈនៅប្រទេសនោះ។ ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការទាមទារឯកសារ ឬរបាយការណ៍ផ្សេងៗបន្ថែមទៀត ដែលក្រុមហ៊ុនគិតថាចាំបាច់ក្នុងការដំណើរការការទាមទារសំណងនេះ។

4. **រយៈពេលអតិបរមានៃការទូទាត់សំណងជូនអតិថិជន**

ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការពិចារណាលើសំណុំឯកសារ និងការសម្រេច លើការផ្តល់សំណងក្នុងរយៈពេល 15 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលឯកសារពេញលេញអំពីបណ្តឹងទាមទារសំណង។

5. **របៀបទូទាត់សំណង**

ក្រុមហ៊ុននឹងទូទាត់សំណងតាមរយៈគណនីធនាគាររបស់អ្នកទាមទារសំណង ដែលបានដាក់ជូនមកក្រុមហ៊ុនដោយយោងតាមឯកសារបញ្ជាក់ពីគណនីធនាគាររបស់អ្នកទាមទារសំណង ។

6. **សិទ្ធិត្រួតពិនិត្យ**

ក្នុងករណីមានចម្ងល់ ឬការសង្ស័យទាក់ទងនឹងការទាមទារសំណង ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការជ្រើសតាំង វេជ្ជបណ្ឌិតជំងឺទូទៅ ឬវេជ្ជបណ្ឌិតជំនាញឯកទេសដែលក្រុមហ៊ុនទទួលស្គាល់ ក្នុងការពិនិត្យសុខភាពជូនសមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលជាចំណាយរបស់ក្រុមហ៊ុនផ្ទាល់។

## XIV. ការរក្សាការព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឱ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឱ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

## XV. ការផ្សះផ្សាវិវាទ

### 1. នីតិវិធីដោះស្រាយបណ្តឹងអតិថិជន

រាល់វិវាទដែលក្រុមហ៊ុនបានទទួល នឹងត្រូវលើកឡើងសម្រាប់ដោះស្រាយ និងវិភាគក្នុងរយៈពេលដែលសមរម្យ ដើម្បីកំណត់ពីមូលហេតុ និងវិធានការដែលនឹងត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមនីតិវិធីស្តង់ដាររបស់ក្រុមហ៊ុន។ អ្នកអាចជូនដំណឹងទៅក្រុមហ៊ុន តាមរយៈអ៊ីមែល Kh.care@aia.com និងលេខទូរស័ព្ទ (855) 86 999 242។

### 2. នីតិវិធីនៃការផ្សះផ្សាវិវាទ

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជា ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកា មជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

## XVI. ដែនយុត្តាធិការ

កិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវអនុវត្តក្រោមដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។